ព្រះនគរ
PREAH NOKOR
Journal of Khmer Studies

លេខ ៤, ឆ្នាំ២០២២ / Number 4, 2022 / Numéro 4, 2022

អាជ្ញាធរជាតិអប្សរា
APSARA

ព្រះនគរ
PREAH NOKOR
Journal of Khmer Studies

ចេញផ្សាយប្រចាំឆ្នាំដោយអាជ្ញាធរជាតិអប្សរា
Published annually by The APSARA National Authority

លេខ ៤, ឆ្នាំ២០២២ / Number 4, 2022 / Numéro 4, 2022

សៀមរាប / Siem Reap

អាជ្ញាធរជាតិអប្សរា
A P S A R A
អាជ្ញាធរជាតិអប្សរា
APSARA National Authority

ព្រះនគរ
PREAH NOKOR
Journal of Khmer Studies

ចេញផ្សាយប្រចាំឆ្នាំដោយអាជ្ញាធរជាតិអប្សរា
Published annually by The APSARA National Authority

និពន្ធនាយក / Editor
ហង់ ពៅ / Hang Peou, *APSARA National Authority*

គណកម្មការពិនិត្យ / Editorial Board
ខៀវ ច័ន្ទ / Khieu Chan, *APSARA National Authority*
ជុំ សុភមករា / Chum Sopheakmakara, *APSARA National Authority*
ទិន ទីណា / Tin Tina, *APSARA National Authority*
អ៊ឹម សុខរិទ្ធី / Im Sokrithy, *APSARA National Authority*
អាំង ជូលាន / Ang Chouléan, *Advisor, APSARA National Authority*

អ្នកគ្រប់គ្រងបច្ចេកទេស / Technical Manager
ទិន ទីណា / Tin Tina, *APSARA National Authority*
ម៉ម មាស / Mam Meas, *APSARA National Authority*
វិទូ ភិរម្យ / Vitou Phirom, *APSARA National Authority*

លេខទី៤, ២០២២ / Volume 4, 2022
ចេញផ្សាយប្រចាំឆ្នាំដោយអាជ្ញាធរជាតិអប្សរា
សៀមរាប, ព្រះរាជាណាចក្រកម្ពុជា
COPYRIGHT © 2022 by Preah Nokor, *All Rights Reserved*
ISBN: 9-789924-939405-4

មាតិកា / Contents

ប្រាសាទនាគព័ន្ធ និងការជួសជុលថែទាំ 1
ដោយ ជា សារិទ្ធ

របរដុតកាំបោរនៅភូមិមមាញ 21
ដោយ តូច សុភៈ និង ទិន ទីណា

បទភ្លេង និងទំនុកច្រៀង៖ ភ្លេងមេមត់នៅតំបន់អង្គរ 39
ដោយ ទិន ទីណា, អ៊ូ គន្ធា, សោ ចន្ធា, តូច សុភៈ, ជា សំបូរ, ឆាន់ សុភីនី និង សក្តិ សេដ្ឋា

វត្តអារាមក្នុងតំបន់ការពារនៃឧទ្យានអង្គរ 97
ដោយ អ៊ូ គន្ធា

អាជ្ញាធរជាតិអប្សរា
A P S A R A
អាជ្ញាធរជាតិអប្សរា
APSARA National Authority

9 789924 939405 >

ប្រាសាទនាគព័ន្ធ និងការជួសជុលថែទាំ

ជា សារិទ្ធ

អាជ្ញាធរជាតិអប្សរា

ប្រាសាទរាជស្រីដែលសព្វថ្ងៃហៅថា នាគព័ន្ធ កសាងក្នុងដំណាក់កាលដែលព្រះបាទជ័យវរ្ម័នទី៧ ចាកចេញពីក្រុងជ័យស្រី (ព្រះខ័ន) ទៅរៀបចំរាជធានីអង្គរធំអំឡុងឆ្នាំ១១៩០គ.ស. ហើយព្រះអង្គបានទុក កំពែងក្រុងថ្មដ៏ធំ លម្អដោយចម្លាក់គ្រុឌ (កំពែងទី៤ ប្រាសាទព្រះខ័ន) បារាយណ៍ជ័យតដាកសព្វថ្ងៃគេហៅថា «វាលរាជដាក» (បណ្តោយប្រវែង៣.០០០ម. និងទទឹប្រវែង៩០០ម.) និងក្រុមប្រាសាទនាគព័ន្ធនៅលើកោះតូចមួយនៅកណ្តាលបារាយណ៍នោះ (រូបលេខ១ ដល់លេខ៣) មួយអន្ទើសិន។ ក្រុមប្រាសាទនេះមានស្រះប្រាំអាចបំពេញទឹកឱ្យគ្នាទៅវិញទៅមក ចំណែកស្រះកណ្តាលមានប្រាង្គមួយក្នុងទម្រង់ដូចផ្កាឈូក មាននាគមួយគូព័ទ្ធជុំវិញ មានកន្ទុយត្របាញ់ចូលគ្នា។ ចម្លាក់សេះនៅជ្រុងខាងកើត រឿងនោះនិយាយអំពីអ្នកសំពៅរងគ្រោះនៅលើកោះមួយដោយសារចាញ់បោកយក្ខិណីមួយហ្វូង ហើយព្រះលោកេស្វរជំណែងខ្លួនជាសេះ (បាលាហ៍) ជួយសង្គ្រោះបានរួចរស់ជីវិតផុតពីសេចក្តីស្លាប់។ ប្រាសាទនាគព័ន្ធមានទំនប់ពីរជាន់ ព័ទ្ធជុំវិញការពារពីជំជន់ទឹកបារាយណ៍។ ចំណែកលើទំនប់ខាងក្រោមមានផៃ (ជណ្តើរថ្មបាយក្រៀម) ចំនួនបួនស្ថិតនៅចំអ័ក្សលិចកើត និងជើងត្បូង (រូបលេខ៤) ហើយនៅតាមជ្រុងទាំងបួននៃកោះ មានរូបចម្លាក់សត្វដំរី។ នៅក្នុងឆ្នាំ១៩៣៨ ក្រុមអភិរក្សដ្ឋានអង្គរបានយកចម្លាក់សត្វដំរីចេញពីជ្រុងពាយព្យទៅរក្សាទុកនៅឃ្លាំងអភិរក្សដ្ឋានអង្គរ សព្វថ្ងៃនៅសារមន្ទីរជាតិអង្គរខេត្តសៀមរាប (រូបលេខ៥)។

ក្រោយមកប្រាង្គកណ្តាលប្រាសាទនាគព័ន្ធបានកែទៅជាប្រាសាទព្រះពុទ្ធសាសនាមហាយាន តែនៅរក្សាច្រកទ្វារខាងកើតនៅដដែល ចំណែកទ្វារបីទៀតត្រូវបិទភ្ជិតដោយផ្ទាំងថ្មភក់ និងចម្លាក់ព្រះលោកេស្វរ។ កាលក្នុងដំណាក់កាលទី១ (១១៨៨ គ.ស.) ប្រាង្គកណ្តាលបើកចំហទាំងបួនទិស ដូចគ្នាទៅនឹងប្រាសាទ

មេបុណ្យខាងលិច។ តែមិនយូរប៉ុន្មាន មុខងារប្រាង្គកណ្តាលក្នុងដំណាក់កាលទី១នោះត្រូវបានបញ្ចប់។ ឯកម្រិតកម្ពស់ទឹកក្នុងបារាយណ៍បានបន្ថែមឱ្យខ្ពស់ជាងមុន។ ដូច្នេះបញ្ហាចៀសមិនរួច គឺក្រុមប្រាសាទលើកោះកណ្តាលត្រូវលិចលង់។ បន្ទាប់មកគេបានលើកទំនប់តូចកម្ពស់ប្រហែល១.៥០ម. ដើម្បីការពារសំណង់លើកោះ (រូបលេខ២) ហើយអត្ថន័យទូទៅរបស់ប្រាសាទនាគព័ន្ធក៏ត្រូវផ្លាស់ប្តូរដែរ។ បច្ចុប្បន្នអត្ថន័យពិតប្រាកដនៃប្រាង្គកណ្តាលក្នុងដំណាក់កាលទី១នៅតែពុំទាន់ដឹងនៅឡើយ។ ប៉ុន្តែប្រហែលជាអាចទាក់ទងនឹងការគោរពដល់ព្រហ្មញ្ញសាសនា និកាយព្រះឥសូរ នេះបើយោងតាមស្លាកស្នាមសំណល់វត្ថុផ្សេងៗ ដែលរកឃើញក្នុងស្រះកណ្តាលប្រាសាទនាគព័ន្ធសព្វថ្ងៃ។

ដូច្នេះ ប្រាសាទនាគព័ន្ធទាំងមូលបានប្រែក្លាយទៅជានិមិត្តរូបនៃទន្លេអនវតប្ត: ឬអនោតត្តស្រះ ស្ថិតនៅចំកណ្តាលពិភពលោក ចំណែកស្រះបួនទៀតជានិមិត្តរូបនៃទន្លេធំៗបួន គឺជាប្រភពទឹកផ្តល់ដល់ការធ្វើកសិកម្មលើពិភពលោក។ ទន្លេទាំងបួនមានទបង្ហូរទឹក និងចម្លាក់រូបក្បាលមនុស្ស និងសត្វជានិមិត្តរូបនៃទន្លេទាំងបួន៖

១. ចម្លាក់ក្បាលមនុស្សបែរទៅកើតជានិមិត្តរូបនៃទន្លេគង្គា

២. ក្បាលគោបែរទៅត្បូង និមិត្តរូបនៃទន្លេសិន្ធុ

៣. ក្បាលសេះបែរទៅលិចនិមិត្តរូបនៃទន្លេអមុទរ្យ

៤. ក្បាលដំរីបែរទៅជើងនិមិត្តរូបនៃទន្លេសីតា ។

សិលាចារឹកប្រាសាទព្រះខ័ន (K.៩០៨) រៀបរាប់ពីកាលបរិច្ឆេទនៃការកសាងប្រាសាទនាគព័ន្ធ (១១៩១ គ.ស.) ជាពិសេសត្រង់ល្បះ៤១៖ រៀបរាប់ថា (...) កោះមួយដ៏ពិសិទ្ធ មានទឹកយ៉ាងត្រចះត្រចង់លាងសម្អាតកក់ជ្រាំបាបកម្មរបស់អ្នកដែលបានមកដល់ (...)។ ទាំងអស់នេះបង្ហាញថា ព្រះរាជា គឺព្រះបាទជ័យវរ្ម័នទី៧ បានគិតគូរនិងយកព្រះទ័យទុកដាក់ចំពោះសុខមាលភាព (មន្ទីរព្យាបាលរោគ) របស់ប្រជារាស្ត្រ ហើយព្រះអង្គថែមទាំងបានគិតគូរអំពីការអប់រំចិត្តសាស្ត្រ ដែលបង្ហាញតាមរយ:ការកសាងទបង្ហូរទឹកសម្រាប់លាងបាបនិងមន្ទិលផ្សេងៗដែលយើងឃើញនៅសល់ក្នុងប្រាសាទនាគព័ន្ធរហូតដល់សព្វថ្ងៃ។



រូបលេខ១. ប្លង់ទីតាំងប្រាសាទនាគព័ន្ធ (រូបភាពពី LiDAR ឆ្នាំ២០១២)



កំណត់សម្គាល់៖
គំនូរពុះកាត់ទទឹង (ជើងត្បូង) បារាយណ៍ជ័យតដាក (ខ្នាតកម្ពស់ និងប្រវែងខុសគ្នា)
a. កម្ពស់ដីធម្មជាតិ b.ទំនប់បារាយណ៍ដំណាក់កាលទី១ (ទំនប់ខាងត្បូង) c.កោះកណ្ដាលបារាយណ៍ d.កម្ពស់ទឹកក្នុងបារាយណ៍ដំណាកកាលទី១
e. ទំនប់បារាយណ៍ដំណាក់កាលទី២ f.ទំនប់ការពារសំណង់ប្រាសាទលើកោះ ដំណាក់កាលទី២ g.កម្ពស់ទឹកក្នុងបារាយណ៍ដំណាក់កាលទី២
h. កម្ពស់ទឹកក្នុងស្រះកណ្ដាល ដំណាក់កាលទី១ និងទី២

រូបលេខ២២. ប្លង់ពុះជើងត្បូងបារាយណ៍ជ័យតដាក ដំណាក់កាលទី១ ឆ្នាំ១១៨៨ និងទី២ ឆ្នាំ១១៩១?



កំណត់សម្គាល់៖
- ប្លង់ទីតាំងផែខាងជើង និងទំនប់ខាងក្រៅរុះរើឆ្នាំ១៩៥៦ ហើយជួសជុលឆ្នាំ២០២១
- ប្លង់ទីតាំងទំនប់ខាងក្នុងកាត់ផ្ដាច់ឆ្នាំ១៩៥៦ ហើយជួសជុលឆ្នាំ២០២១
- ផ្លូវកាត់ស្រះខាងជើងកសាងនៅឆ្នាំ១៩៥៦ ហើយកាយចេញនៅឆ្នាំ២០២១

រូបលេខ២៣. ក្រុមប្រាសាទនាគព័ន្ធលើកូនកោះកណ្ដាលបារាយណ៍ជ័យតដាក (រូបភាព LiDAR ២០១២)

១. ការងារដែលមានកន្លងមក

ប្រាសាទនាគព័ន្ធធ្លាប់បានជួសជុលដោយក្រុមអភិរក្សដ្ឋានអង្គរនៃសាលាបារាំងចុងបូព៌ា។ ចាប់ពីឆ្នាំ១៩២២ ដល់ឆ្នាំ១៩២៤ លោក Henri Marchal បានកាប់ឆ្ការព្រៃ សម្អាតកំណាកដីជុំវិញប្រាសាទ ក្នុងស្រះ គូរប្លង់ប្រាសាទ និងដឹកនាំការងារជួសជុលតាមផ្នែកខូចខាតនៃរចនាសម្ព័ន្ធក្រុមប្រាសាទនាគព័ន្ធ។ នៅឆ្នាំ១៩៣៨ ដល់ឆ្នាំ១៩៣៩ លោក Maurice Glaize បានជួសជុលប្រាង្គកណ្តាលដែលខូចខាតបណ្តាលពីខ្យល់ព្យុះបាក់ដើមឈើផុះលើប្រាង្គកណ្តាល (រូបលេខ៦ និង៧)។ នៅឆ្នាំ១៩៥៦ និង១៩៥៩ លោក Jean Laur បានជួសជុលជណ្តើរស្រះកណ្តាល ប៉ុន្តែមុនការជួសជុលលោកបានរៀបចំផ្លូវចូលទៅកោះកណ្តាល បារាយណ៍ជ័យតដាកតាមច្រកចូលខាងជើង ហើយនៅខែធ្នូ ឆ្នាំ១៩៥៦ គាត់បានរើជណ្តើរផែខាងជើង (ជណ្តើរថ្មបាយក្រៀម) ហើយផ្ទៃទំនប់នៅចំអ័ក្សផ្លូវចូលពីជើងទៅត្បូងក៏ត្រូវកាត់ផ្តាច់ ដោយយកដីទៅធ្វើផ្លូវឆ្លងកាត់ស្រះធំខាងជើង (ស្រះនៅចន្លោះទំនប់ខាងក្នុង និងខាងក្រៅ) ដើម្បីយកដងស្ទូច និងសម្ភារៈទៅជួសជុលជណ្តើរស្រះកណ្តាល (រូបលេខ៩ និង៩)។

នៅឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤ ឯកឧត្តម ហង់ ពៅ[១] បានដឹកនាំគម្រោងសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា និងស្ថាបត្យកម្ម សិក្សាពីស្ថានភាពគ្រោះថ្នាក់ និងបញ្ហាប្រឈមនៃរចនាសម្ព័ន្ធប្រាសាទនាគព័ន្ធមុនបញ្ចូលទឹកឡើងវិញ (រូបលេខ១០)។ ដោយឡែក នៅឆ្នាំ២០២១ និង២០២២ អាជ្ញាធរជាតិអប្សរាបានរៀបចំជួសជុលដំបូលទបង្ហូរទឹកខាងត្បូង (ដំបូលនៃចម្លាក់ក្បាលសត្វគោ) ប្រាសាទនាគព័ន្ធ (រូបលេខ១១ និង១២)។



រូបលេខ២៤. ប្លង់ក្រុមប្រាសាទនាគព័ន្ធលើកោះកណ្តាលបារាយណ៍ជ័យតដាក
(Olivier Cunin)

[១] បច្ចុប្បន្ន ឯកឧត្តម ជាអគ្គនាយកអាជ្ញាធរជាតិអប្សរា

រូបលេខ៥. ចម្លាក់សត្វដំរីនៅជ្រុងពាយព្យលើកោះ កណ្តាលបារាយណ៍ជ័យតដាក (EFEO ១៩៣៨)

រូបលេខ៨. ផែខាងជើងមុនពេលរើជណ្តើរ និងផ្តាច់ទំនប់ (EFEO ខែវិច្ឆិកា ១៩៥៦)

រូបលេខ៩. ផែខាងជើងបន្ទាប់ពីរើដណ្តើរ និងផ្តាច់ទំនប់ (EFEO ខែមករា ១៩៥៧)

រូបលេខ១០.បារាយណ៍ជ័យតដាកបន្ទាប់ពីជួសជុល និងបំពេញទឹកឡើងវិញដោយអាជ្ញាធរជាតិអប្សរា
(Thmey Thmey News ២០២១)

រូបលេខ១១.ជ្រុងខាងកើតនៃដំបូលទបង្ហូរទឹកខាងត្បូងមុនជួសជុល (APSARA ២០២១)

រូបលេខ១២.ជ្រុងខាងកើតនៃដំបូលទបង្ហូរទឹកខាងត្បូងបន្ទាប់ពីជួសជុលរួច (APSARA ២០២១)

២. ស្ថានភាពបច្ចុប្បន្ន

ក្រោយពេលលោក Jean Laur រើជណ្ដើរផៃខាងជើង និងកាត់ផ្ដាច់ទំនប់ខាងក្នុង និងខាងក្រៅត្រង់ច្រកចូលខាងជើង ដើម្បីយកដីធ្វើផ្លូវកាត់ស្រះខាងជើងតភ្ជាប់ទៅក្រុមប្រាសាទកណ្ដាល ដើម្បីនាំយកដងសន្ទូច និងសម្ភារៈសម្រាប់ជួសជុលជណ្ដើរស្រះកណ្ដាលរួចមក គាត់ពុំបានរៀបចំជណ្ដើរផៃ បិទទំនប់ និងកាយផ្លូវចេញវិញទេ គឺទុករហូតដល់សព្វថ្ងៃ។ សព្វថ្ងៃរចនាសម្ព័ន្ធជណ្ដើរផៃខាងជើងកំពុងទ្រុឌទ្រោមខ្លាំងប្រឈមនឹងការដួលរលំដោយសារគ្រឹះចុះខ្សោយ រចនាសម្ព័ន្ធថ្មនៅសល់ទ្រេតខ្លាំងថ្មរំកិលចេញពីស្ថានភាពដើមពុកផុយ និងរលុះធ្លាក់ជាបន្តបន្ទាប់ (រូបលេខ១៣ ដល់១៨)។

ចំណែកផ្ទៃទំនប់ត្រង់ចំណុចកាត់ផ្ដាច់នោះ រងការបាក់ស្រុត ទឹកហូរច្រោះដី ហើយទឹកបារាយណ៍ហូរកាត់តាមប្រឡោះទំនប់ដាច់ទាំងពីរ បង្កឱ្យជន់លិចក្រុមប្រាសាទកណ្ដាលនាគព័ន្ធ។ មួយវិញទៀតផ្លូវដីដែលកាត់ចំកណ្ដាលស្រះខាងជើងចូលទៅកាន់ក្រុមប្រាសាទកណ្ដាលរក្សាទុករហូតដល់សព្វថ្ងៃ ដែលនាំឱ្យភ្ញៀវទេសចរភាន់ច្រឡំថា ជាផ្លូវបុរាណ (រូបលេខ១៤)។

រូបលេខ១៣.រចនាសម្ព័ន្ធផៃនៅទំនប់ខាងក្រៅនៅត្រង់ច្រកចូលខាងជើង

រូបលេខ១៤.រចនាសម្ព័ន្ធផៃខាងជើងនៅសល់ពីការរុះរើកំពុងប្រឈមនឹងដួលរលំជាស្ថាពរ (APSARA ២០២១)

រូបលេខ១៥.រចនាសម្ព័ន្ធផែនៅសល់ពីការរុះរើ ហើយកំពុងប្រឈមនឹងដួលរលំ (APSARA ២០២១)



រូបលេខ១៦.ជណ្ដើរផែ និងទំនប់ខាងក្រៅ មុនពេលជួសជុល (Oliver Cunin ២០២២)

រូបលេខ១៧.ស្ថានភាពខូចខាតនៃជណ្តើរផៃ ខាងជើងជ្រុងខាងលិច(APSARA២០២១)

រូបលេខ១៨.ស្ថានភាពទំនប់ខាងក្រៅត្រង់ជ្រុងខាងកើតមុនពេលជួសជុល (APSARA ២០២១)

៣. គោលបំណង

គោលបំណងរបស់គម្រោងនេះ គឺជួសជុលស្ដារឡើងវិញ ជាពិសេសជណ្ដើរផែខាងជើង បិទទំនប់ខាងក្នុង និងខាងក្រៅ និងស្ដារដីផ្លូវចេញពីក្នុងស្រះខាងជើង ហើយរៀបចំអ័ក្សខាងជើងប្រាសាទនាគព័ន្ធត្រឡប់ទៅរកសភាពដើមវិញ។ ទាក់ទងនឹងកិច្ចការនេះ យើងបានសិក្សាស្រាវជ្រាវ និងប្រមូលនូវទិន្នន័យសំខាន់ៗមួយចំនួនមុនកំណត់វិធីសាស្ត្រការអភិរក្ស និងជួសជុល។ គម្រោងនេះផ្ដោតទៅលើតែចំណុចគ្រោះថ្នាក់ ដែលអាចបង្កមហន្តរាយដល់រចនាសម្ព័ន្ធផែខាងជើង ព្រមទាំងផ្នែកខូចខាតតួទំនប់ដែលទ្រុឌទ្រោមខ្លាំង និងការពារប្រាសាទពីការជន់លិច។ គម្រោងជួសជុលផែខាងជើងទំនប់ទាំងពីរ និងស្ដារដីផ្លូវចេញពីស្រះខាងជើង គឺការរៀបចំអក្សខាងជើងប្រាសាទនាគព័ន្ធតាមទម្រង់ដើម (ចុងស.វ.ទី១២ និងដើមទី១៣) ដើម្បីរួមចំណែកបង្កើតវង់ទស្សនាថ្មីទៅក្រុមប្រាសាទលើកោះកណ្ដាលបារាយណ៍ជ័យតដាក។

៤. ការជួសជុល

នៅឆ្នាំ២០២១ ពេលដែលកម្ពស់ទឹកក្នុងបារាយណ៍នេះចុះទាប ជាឱកាសល្អសម្រាប់ឱ្យក្រុមអភិរក្សចូលជួសជុលជណ្ដើរផែខាងជើង និងទំនប់ទាំងពីរ ជាពិសេសការពារទឹកមិនឱ្យលិចក្រុមប្រាសាទកណ្ដាល។ ទោះបីគម្រោងខាងលើនេះពុំមានក្នុងផែនការប្រចាំឆ្នាំរបស់អាជ្ញាធរជាតិអប្សរា និងពុំមានក្នុងកម្មវិធីប្រជុំគណកម្មាធិការសម្របសម្រួលបច្ចេកទេសអន្តរជាតិ តែមុននឹងចាប់ផ្ដើមការងារនេះ យើងបានបង្ហាញគម្រោងដើម្បីសុំយោបល់ពីក្រុមអ្នកបច្ចេកទេសអន្តការយូណេស្កូ។ បន្ថែមពីនេះ ក្រុមបច្ចេកទេសខាងលើនេះ បានជួយជ្រោមជ្រែងឱ្យអាជ្ញាធរជាតិអប្សរារៀបចំគម្រោង និងអនុញ្ញាតឱ្យជួសជុលពង្រឹងជណ្ដើរផែខាងជើង និងបិទទំនប់ទាំងពីរត្រង់ច្រកចូលខាងជើងតាមរចនាសម្ព័ន្ធដើម។ គម្រោងនេះ ចាប់អនុវត្តពីដើមខែកញ្ញាដល់ចុងខែធ្នូ ឆ្នាំ២០២១ ចាប់ផ្ដើមពីការសិក្សាស្រាវជ្រាវរកឯកសារចាស់ៗពាក់ព័ន្ធនឹងការងារមានកន្ទង់មកការចុះបញ្ជីថ្មវាយប៉ាយ រៀបផ្ដុំថ្ម គូរប្លង់ កំណាយពិនិត្យស្ថានភាពគ្រឹះ និងស្វែងរកថ្មបាត់ រើផ្នែករងការខូចខាតជួសជុលគ្រឹះ បិទទំនប់ រៀបផ្ដុំជណ្ដើរផែ និងស្ដារស្រះខាងជើងឡើងវិញ (ជីកយកដីផ្លូវចេញ) អនុវត្តផ្ទាល់ដោយអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរាទាំងអស់។

៤.១. កំណាយ

យើងបានធ្វើកំណាយនៅផ្នែកជុំវិញផែខាងជើង ដើម្បីពិនិត្យ និងស្វែងយល់ពីរចនាសម្ព័ន្ធគ្រឹះ និងរកថ្មដែលបាត់។ ក្រៅពីនេះ មានកំណាយសម្អាតមុខកាត់ទំនប់ទាំងពីរ ដើម្បីសិក្សាស្រទាប់ដី និងប្រភេទដីតួទំនប់។ តាមរយៈលទ្ធផលកំណាយ យើងបានរកឃើញដុំថ្មបាយក្រៀមជាច្រើនដុំនៅតាមរណ្ដៅនីមួយៗ ដែលសុទ្ធសឹងជាគ្រឿងបង្គុំជណ្ដើរផែខាងជើង។ ថ្មបាយក្រៀមមួយភាគធំនៅមានគុណភាពល្អអាចយកទៅប្រើឡើងវិញបាន។ សូមបញ្ជាក់ថា ដុំថ្មបាយក្រៀមដែលមានបង់លេខ គឺជាដុំថ្មដែលគេរើចេញពីជណ្ដើរផែ

(យោងរបាយការណ៍ RCA)[៦] ចំណែកដុំថ្មមួយចំនួនទៀតដែលពុំមានបង់លេខ ជាថ្មក្រាលស្ថិតនៅជាប់នឹងជណ្ដើរផែខាងជើង (រូបលេខ១៩ ដល់២០)។

រូបលេខ១៩.ជណ្ដើរផែខាងជើងរកឃើញពេលកំណាយ ក្នុងខែកញ្ញា ឆ្នាំ២០២២

រូបលេខ២០.ថ្មជណ្ដើរផែដែលមានបង់លេខសម្គាល់ពេលគេរុះរើកាលពីឆ្នាំ១៩៥៦

[៦] Report de la Conservation d’Angkor (RCA)

៤.២. ការបិទទំនប់

យោងតាមលទ្ធផលកំណាយបុរាណវិទ្យា និងការសម្អាតដីផ្ទៃមុខកាត់ទំនប់ត្រង់ចំណុចដែលបានកាត់ផ្ដាច់នៅឆ្នាំ១៩៥៦ យើងបានដឹងថា ផ្នែកខាងក្រោមតួទំនប់សម័យបុរាណ គេបានយកដីឥដ្ឋពណ៌ប្រផេះក្រមៅ ស្អិតខ្លាំង ដែលបានបង្ហាប់យ៉ាងណែនល្អដាក់បំពេញក្រាលធ្វើបាតទំនប់។ ចំណែកផ្នែកកណ្ដាល និងខាងផ្នែកខាងលើតួទំនប់ គឺបំពេញដោយដីខ្សាច់ម៉ដ្ឋពណ៌ផ្កាឈូកស្អិតបន្តិច។ ម្យ៉ាងទៀត បើពិនិត្យលើប្រភេទដី និងពណ៌ដីផ្លូវឆ្លងកាត់ស្រះនោះ ឃើញថា ជាប្រភេទដី និងមានពណ៌ដូចគ្នាទៅនឹងប្រភេទដីទំនប់ព័ទ្ធជុំវិញក្រុមប្រាសាទកណ្ដាល។ ដូច្នេះ ការជួសជុលបំពេញតួទំនប់ត្រង់កន្លែងដែលខូចខាត យើងបានជីកយកដីពីតួផ្លូវក្នុងស្រះខាងជើងមកបំពេញ និងបិទទំនប់ ដើម្បីការពារទឹកបារាយណ៍ជន់លិចក្រុមប្រាសាទលើកោះ (រូបលេខ២១ ដល់២២)។

រូបលេខ២១.ស្ថានភាពទំនប់ខាងក្រោមុនជួសជុល

រូបលេខ២២.ទំនប់ខាងក្រោបន្ទាប់ពីជួសជុលរួច (ខែវិច្ឆិកា២០២១)

៤.៣. ការស្ដារដីផ្លូវក្នុងស្រះខាងជើង

ដីផ្លូវឆ្លងកាត់ស្រះខាងជើងដែលយកពីទំនប់ខាងក្នុង និងខាងក្រៅត្រង់ច្រកចូលខាងជើង ត្រូវបានជីកស្ដារ ហើយយកទៅបំពេញត្រង់ទំនប់ដែលបានកាត់ផ្ដាច់កាលពីអំឡុងខែធ្នូ ឆ្នាំ១៩៥៦។ ចំណែកផ្ទៃស្រះខាងជើងត្រូវបានស្ដារឱ្យមានរូបសណ្ឋានដូចទម្រង់ដើមឡើងវិញ (រូបលេខ២៣ ដល់២៦)។

រូបលេខ២៣.ផ្លូវកាត់ស្រះខាងជើងដែលលើកនៅខែធ្នូ ឆ្នាំ១៩៥៦

រូបលេខ២៤.ស្តារដីផ្លូវក្នុងស្រះខាងជើង(ខែវិច្ឆិកា ឆ្នាំ២០២១)

រូបលេខ២៥.ស្រះខាងជើងក្រោយពេលជីកស្តារដីផ្លូវចេញ កាលពីខែវិច្ឆិកា ឆ្នាំ២០២១

រូបលេខ២៦.ស្រះខាងជើងក្រោយពេលជីកស្តារដីផ្លូវរួច (DCMA ខែមករា ឆ្នាំ២០២២)

៤.៤. ការរៀបដុំផែ

ពាក្យថាផែនៅទីនេះ គឺសំដៅលើជណ្តើរថ្មបាយក្រៀម ដោយរាប់ចាប់ពីផ្នែកគ្រឹះរហូតដល់ផ្នែកខាងលើបង្អស់របស់ផែ រួមមាន៖ គ្រឹះ ជើងតាង ខឿន (ជញ្ជាំងអមសងខាងជណ្តើរ) ជណ្តើរ កម្រាល និងទម្រង់រូបចម្លាក់សត្វតោនៅលើបំផុត។ គ្រឹះផែសង់ពីថ្មបាយក្រៀម និងដីខ្សាច់ម៉ដ្ឋបុកបង្ហាប់លាយកម្ទេចថ្មភ្នំ ជាស្រទាប់ក្រោមបង្អស់។ សព្វថ្ងៃគ្រឹះនេះពុកផុយ និងស្រុតខ្លាំងដោយសារឫសឈើចាក់រំលើងថ្ម ហើយទឹកជ្រាបចូល។ ក្នុងការជួសជុលពង្រឹងគ្រឹះ យើងបានយកឫសឈើចេញ និងដីស្អុយ (ដីភក់ល្បាប់) ចាប់ពីបាតក្រោមថ្មជើងតាងចុះដល់ស្រទាប់ដីខ្សាច់គ្រឹះ ដែលនៅមានគុណភាពល្អ (ជម្រៅចាប់ពី១០ ដល់២០ស.ម.)។ ដីស្អុយដែលយកចេញ ត្រូវបំពេញជំនួសវិញដោយដីខ្សាច់ថ្មី និងរៀបដុំថ្មបាយក្រៀមពីលើ (ថ្មជើងតាង)។

៤.៤.១. ជើងតាង

ជើងតាង ជាស្រទាប់ទី២ដែលស្ថិតនៅលើដីខ្សាច់គ្រឹះ ជាស្រទាប់ថ្មបាយក្រៀមដែលមានតួនាទីទ្រថ្មជណ្ដើរផៃ។ ថ្មមួយដុំៗមានទំហំពី ៤០ស.ម.x៣០ស.ម.x២០ស.ម. ដល់៦៥ស.ម.x៣៥ស.ម.x២៥ស.ម.។ ក្នុងការជួសជុលយើងបានពង្រីកជើងតាងធំជាងមុនបន្តិច ពោលគឺ ត្រូវបន្ថែមថ្មថ្មី និងឱ្យលយចេញពីជើងតាងចាស់៣០ស.ម. ត្រង់កន្លែងណាដែលខូចខាត និងស្រុត។ កន្លែងដែលថ្មនៅល្អ យើងរក្សាទុកដដែល។ សូមបញ្ជាក់ថា ថ្មបាយក្រៀមថ្មីយកមកជួសជុល និងប្ដូរជើងតាងត្រូវមានទំហំធំ ហើយក្រាស់ជាងថ្មចាស់ ព្រោះត្រូវលើកជើងតាងឱ្យស្មើកម្ពស់ដើមវិញ។

៤.៤.២. ខឿន

ខឿនជាស្រទាប់ទី៣រៀបពីលើថ្មជើងតាងហើយមានទីតាំងនៅអមសងខាងជណ្ដើរ។ ខឿនម្ខាងៗមានបណ្ដោយប្រវែង២៦៥ស.ម. ទទឹងប្រវែង២៣៥ស.ម. និងកម្ពស់១៧៣ស.ម.។ ដូចបានរៀបរាប់ពីខាងដើមរួចម្ដងមកហើយ ខឿនអមសងខាងជណ្ដើរផៃ មានផ្នែកខ្វះទ្រុឌទ្រោម ស្រុត និងបាក់ធ្លាក់ថ្មបាត់អស់មួយចំនួន។ ដូច្នេះ ការជួសជុលយើងត្រូវពង្រឹងផ្នែកដែលនៅសល់ និងខូចខាត ហើយបំពេញថ្មថ្មីតាមទីតាំង ដែលចាំបាច់ ដើម្បីការពារលំនឹងរចនាសម្ព័ន្ធផៃឱ្យជាប់មាំយូរអង្វែង ចំណែកកន្លែងដែលថ្មមានគុណភាពល្អនៅរក្សាទុកដដែល។

៤.៤.៣. ជណ្ដើរ

ជណ្ដើរជាផ្នែកមួយនៅចន្លោះខឿនទាំងសងខាងដែលរៀបជាថ្នាក់ៗហើយកាំនីមួយៗមានបណ្ដោយប្រវែង២៣៥ស.ម. ទទឹងប្រវែង៣១ស.ម. កម្ពស់២៤ស.ម. ហើយមានចំនួន៩កាំ។ ថ្មជណ្ដើរទាំងអស់បានរុះរើចេញនៅចុងឆ្នាំ១៩៩៦។ នៅឆ្នាំ២០២១ តាមរយៈការធ្វើកំណាយ យើងបានរកឃើញថ្មជណ្ដើរស្ទើរទាំងអស់ ដែលមានបង់លេខសម្គាល់ទីតាំងដើមថ្មជណ្ដើរនីមួយៗ អាចឱ្យយើងអាចយកទៅដាក់តាមទីតាំងដើមវិញបានងាយស្រួល។ ប៉ុន្តែមានថ្មខ្វះពុកផុយពុំអាចប្រើការបាន ដូច្នេះពេលជួសជុលយើងបានសម្រេចដាក់ជំនួសដោយថ្មបាយក្រៀមថ្មីដែលមានទំហំប៉ុនថ្មចាស់ដដែល។

៤.៤.៤. កម្រាល

កម្រាល ជារចនាសម្ព័ន្ធផ្សេងមួយទៀតនៅលើខឿន សង់ពីថ្មបាយក្រៀមដូចគ្នា រៀបជាកម្រាលមានផ្ទៃរាបស្មើ។ នៅលើថ្មកម្រាលឃើញនៅសល់ថ្មភក់១ដុំមានបណ្ដោយប្រវែង៩៩ស.ម. ទទឹងប្រវែង៦៤ស.ម. និងកម្ពស់៣១ស.ម. ប្រហែលជាទម្រូវបចម្លាក់សត្វតោ ចំណែកម្ខាងទៀតបាត់រកមិនឃើញ (រូបលេខ២៧ ដល់៣៣)។

រូបលេខ២៧.វិធីសាស្ត្រជួសជុលជណ្តើរផែខាងជើង និងទំនប់ខាងក្រៅប្រាសាទនាគព័ន្ធ

រូបលេខ៣០.ជណ្តើរផែ និងទំនប់បន្ទាប់ពីជួសជុលរួចនៅ ខែធ្នូ ឆ្នាំ២០២១

រូបលេខ៣១.ជណ្តើរផែ និងទំនប់បន្ទាប់ពីជួសជុលរួចនៅ ខែធ្នូ ឆ្នាំ២០២១

រូបលេខ៣២.ជណ្តើរផែ និងទំនប់បន្ទាប់ពីជួសជុលរួច (APSARA ២០២២)

រូបលេខ៣៣.ជណ្ដើរផែ និងទំនប់បន្ទាប់ពីជួសជុលរួចនៅ ខែធ្នូ ឆ្នាំ២០២១

ឯកសារពិគ្រោះ

លឹមស្រ៊ូ(២០០៩-២០១០)"ប្រាសាទនាគព័ន្ធនិងជំនឿក្នុងការព្យាបាលជម្ងឺ", បណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២៥, ទំ. ២៨-៣២.

ស៊ីយ៉ុនសុភារិទ្ធ (២០០៩) "ប្រាសាទនាគព័ន្ធ៖ តីថ៌ ជម្រះមន្ទិលបាបកម្ម", ឧធ័យ, លេខ ១០, ទំ. ១-២៣.

Rapports de la Conservation d'Angkor. Siem Reap 1908-72, École française d'Extrême-Orient

DAGENS, B. (2002), 'Cambodian Architecture - Eight to Thirteenth Centuries', Edited by J. Dumarçay, P. Royère, and M. Smithies, *Arts Asiatiques*. 57, pp. 236–239.

PARMENTIER, H. (1935) 'Complément A L'art Khmèr Primitif', *BEFEO*, 35(1), pp. 1–115.

របរដុតកាំបោរនៅភូមិមមាញ

តូច សុភៈ និង ទិន ទីណា

ពីមុនមក រហូតដល់សព្វថ្ងៃ នៅក្នុងសង្គមខ្មែរមនុស្សដែលមានវ័យចំណាស់ភាគច្រើនមិនថាតែមនុស្សស្រី ឬប្រុសឡើយតែងទទួលទានស្លាម្លូជាទម្លាប់ទៅហើយ។ ទោះជាចាស់ៗតែងនិយាយថា ស៊ីស្លាក៏ពិតមែន តែមិនមែនស៊ីតែស្លាមួយមុខទេ ពោលគឺមានគ្រឿងផ្សំផ្សេងៗទៀតដូចជា៖ ម្លូ កំបោរ និង សម្បកឈើ។ ស្លា ម្លូ កំបោរ នេះជាការពេញនិយម តាំងពីប្រជារាស្ត្រទូទៅអ្នកមានបុណ្យស័ក្តិខ្ពង់ខ្ពស់ ព្រះសង្ឃ រហូតដល់ព្រះមហាក្សត្រផង ដែលទទួលទាន ធាន់ និងសោយពុំសូវដាច់មាត់។ យកតែរឿងជនញ្ជ័យដែលជារឿងប្រឌិតពីបុរាណ ដែលមានប្រជាប្រិយសម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅកាលពីមុន ក៏គង់ឃើញសេដ្ឋីប្រាប់ឱ្យអាជ័យទៅយកថង់ស្លាម្លូមកហូបនៅក្នុងរោងជំនុំដែរ។ ដូច្នេះមិនថានៅតាមផ្ទះ សូម្បីតែពេលចាកចេញពីផ្ទះក៏តែងតែមានស្លាម្លូតិច ឬច្រើនជានិច្ចដាក់តាមខ្លួន។ កំបោរជាវត្ថុដែលមានសាច់ផុសផង់មានពណ៌សកើតពីថ្មម៉្យាង ឬពីសម្បកលៀស, គ្រុំជាដើម ដែលគេដុតឱ្យសុស មានដូចជាកំបោរថ្ម, កំបោរលៀស។[១] ក្រៅពីនេះកំបោរក៏ត្រូវបានយកមកប្រើក្នុងវិស័យស្ថាបត្យកម្មខ្មែរសម័យបុរាណដែរ ពោលគឺយកមកលាយជាមួយខ្សាច់ហ្មត់ ឬខ្សាច់គ្រើមបន្ថែមប្រភេទសរីរាង្គដទៃទៀត ដូចជាស្ករត្នោត ឬជ័របានពីរុក្ខជាតិផ្សេងៗធ្វើជាកំបោរបាយអដើម្បីប្រើជាគ្រឿងលម្អស្ថាបត្យកម្មជាពិសេសសម្រាប់ប្រាសាទឥដ្ឋ (តាន់ សុផល ២០១៩)។ កំបោរបាយអមានការនិយមប្រើប្រាស់ខ្លាំងក្នុងវិស័យស្ថាបត្យកម្មខ្មែរតាំងពីស.វ.ទី៧ (គ.ស៦១៦-៦៣៥) ក្នុងរាជ្យព្រះបាទឥសានវរ្ម័នទី១។ ចំពោះកំបោរដែលធ្វើពីថ្មកំបោរ ត្រូវដុតនៅក្នុងឡដែលមានទំហំធំៗ មានកម្តៅខ្ពស់ ប្រើពេលយូរ និងទទួលបានផលច្រើនពេលដុតម្តងៗ។ កំបោរប្រភេទនេះ អាចប្រើបានក្នុងវិស័យសំណង់ និងអាចហូបជាមួយម្លូស្លាដែរ។ ដោយឡែក ចំពោះកំបោរដុតពីសម្បកលៀស ឬគ្រុំ គេពុំដុតក្នុងឡទេ គឺគេដុតក្នុងចង្ក្រាន ឬដុតជាមួយអាចម៍គោនៅកណ្តាលវាលស្រែ។ អ្នកស្រាវជ្រាវ បានដឹងយូរមកហើយថាការប្រើប្រាស់កំបោរនៅក្នុងសង្គមខ្មែរមានតាំងពីសម័យហ្វូណន ដោយយកមកសូនជារូប(យី សុថា ២០១៦)។ ក្រៅពីនេះ នៅ

[១] សូមមើលវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិតភាគទី១ បោះពុម្ពឡើងវិញនៅប្រទេសជប៉ុន ឆ្នាំ១៩៨៩, ទំព័រ៨១។

សម័យមុនអង្គរក៏ឃើញមានការប្រើប្រាស់កំបោរបាយអនៅក្នុងវិស័យសំណង់ដែរ ដើម្បីបូកពាសជញ្ជាំង និងធ្វើជាគ្រឿងលម្អលើប្រាសាទសាងសង់ពីឥដ្ឋជាច្រើន ដូចជាក្រុមប្រាសាទនៅសម្បូរព្រៃគុក ដោយបានបង្ហាញពីក្បាច់តុបតែងលម្អធ្វើពីកំបោរបាយអនៅលើប្រាសាទឥដ្ឋ (រូបលេខ២១)។ ប៉ុន្តែស្ទើរតែគ្រប់កន្លែងទាំងអស់នៃប្រាសាទ កំបោរបាយអបានបាត់បង់អស់គ្មានសល់ (លី វណ្ណា ១៩៩៣)។ ចំពោះប្រាសាទដែលមានគ្រឿងលម្អធ្វើពីកំបោរបាយអ ដែលចាស់ជាងគេ ហើយរក្សាបានល្អរហូតដល់សព្វថ្ងៃ គឺប្រាសាទ«ភូមិប្រាសាទ» (រូបលេខ២២) ដែលសាងសង់ឡើងក្នុងអំឡុងឆ្នាំ៧០៦ គ.ស.(លី វណ្ណា ១៩៩៣:៤)។[២] ក្រៅពីនេះ មានប្រាសាទឥដ្ឋមួយចំនួនទៀតនៅតំបន់អង្គរដែលបានប្រើកំបោរបាយអ ដើម្បីបូកពាសជញ្ជាំង និងធ្វើជាគ្រឿងលម្អ ដូចជា៖ ប្រាសាទត្រពាំងផុង (ឆ្នាំ៨៧៥គ.ស.) ប្រាសាទព្រះគោ (ឆ្នាំ៨៧៩គ.ស.) ប្រាសាទមេបុណ្យ (ឆ្នាំ៩៥២គ.ស.) និងប្រាសាទប្រែរូប (ឆ្នាំ៩៦១គ.ស.) ដែលទាំងនេះ បង្ហាញពីភាពរុងរឿងខ្លាំងក្នុងការប្រើប្រាស់កំបោរបាយអក្នុងវិស័យសំណង់នាសម័យអង្គរ(រូបលេខ២៣-៦)។ ក្រោយមក ទោះបីជាកំបោរបាយអពុំសូវមានការនិយមប្រើដូចមុនមួយរយៈពេលខ្លីក៏ពិតមែន ប៉ុន្តែនៅចុងសម័យអង្គរក៏ចាប់ផ្តើមមានការនិយមប្រើឡើងវិញរហូតដល់សម័យក្រោយអង្គរដោយគេនិយមយកកំបោរបាយអទៅលម្អលើរូបចម្លាក់ធ្វើពីថ្មភក់ លើក្បាច់ចម្លាក់ និងប្រាសាទខ្លះទៀតផង(យី សុថា ២០១៦)។ ប៉ុន្តែ ទោះជាយ៉ាងណាក៏យើងពុំសូវមានព័ត៌មានពីការធ្វើកំបោរ និងកំបោរបាយអកាលពីសម័យបុរាណច្រើនឡើយ។

រូបលេខ២១. ក្រុមត្រពាំងរពាក់ ផ្នែកខាងត្បូងតួប៉ម Z1(ប្រភព៖ សេង ចន្ថា)



រូបលេខ២២. ប្រាសាទភូមិប្រាសាទ (ប្រភព៖ ម៉ង់ វ៉ាលី)

រូបលេខ២៣. ប្រាសាទត្រពាំងផុង

[២] ប្រាសាទភូមិប្រាសាទ ស្ថិតនៅក្នុងបរិវេណវត្តប្រាសាទ ក្នុងភូមិសាស្ត្រភូមិប្រាសាទ ឃុំប្រាសាទ ស្រុកកន្ទុក។ ទីតាំងនេះមានចម្ងាយ ១៣៤គ.ម. ពីរាជធានីភ្នំពេញទៅខេត្តកំពង់ធំ តាមផ្លូវជាតិលេខ៦ និងស្ថិតនៅខាងលិចផ្លូវជាតិ ចន្លោះទីប្រជុំជនពីរ គឺ៧គ.ម. ពីខាងជើងផ្សារកំពង់ថ្ម និង៣គ.ម.ខាងត្បូងផ្សារតាំងក្រសាំង ព្រមទាំងប្រហែល៣០គ.ម. ភាគខាងត្បូងទីរួមខេត្តកំពង់ធំ។

រូបលេខ២៨. ប្រាសាទព្រះគោ (ប្រភព៖ ជា វណ្ណៈ)

រូបលេខ២៩. ប្រាសាទប្រែរូប (ប្រភព៖ ជា វណ្ណៈ)

រូបលេខ៦. ប្រាសាទមេបុណ្យខាងកើត (ប្រភព៖ ជា វណ្ណ:)

១. ការស្រាវជ្រាវកន្លងមក

កន្លងមក មានអ្នកសិក្សាស្រាវជ្រាវពីការដុតកំបោរខ្លះៗរួចមកហើយ ដូចជា៖ លោក គង់ វីរ: បានសិក្សាពីការផលិតកំបោរថ្ម នៅស្រុកបន្ទាយមាស ខេត្តកំពត ហើយបានចុះផ្សាយក្នុងកម្រងអត្ថបទបណ្ដាញព័ត៌មានវប្បធម៌ខ្មែរជំពូក១ លេខរៀងទី៤៩។ លោក យី សុថា ក៏បានសិក្សាពីរបរដុតកំបោររបស់អ្នកភូមិទូកមាស នៅស្រុកបន្ទាយមាស ខេត្តកំពត ដើម្បីសរសេរសារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាក្នុងឆ្នាំ២០១៦។ ក្រៅពីនេះ នៅមានការសិក្សាដោយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ដើម្បីរៀបចំរបាយការណ៍ស្តីពីទីតាំងឡដុតកំបោរចាស់ៗធ្វើនៅសម័យបារាំងដែលស្ថិតនៅក្នុងភូមិសាស្ត្រស្រុកកំពង់ត្រាច ខេត្តកំពតដែលអ្នកស្រុកហៅថា "ឡដប់" ។ ការសិក្សាខាងលើ បង្ហាញថាអ្នកស្រាវជ្រាវបានផ្តោតលើសិប្បកម្មដុតកំបោរពីថ្មនៅក្នុងឡ

នៅស្រុកបន្ទាយមាស ខេត្តកំពតតែប៉ុណ្ណោះ។ ក្រៅពីការសិក្សាខាងលើ យើងឃើញមានការសិក្សាពីចម្ងាក់កំបោរបាយអខ្មែរពីស.វ.ទី៩ ដល់ស.វ.ទី១០ ដោយលោកលី វណ្ណា ដើម្បីសរសេរសារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាក្នុងឆ្នាំ១៩៩៣-១៩៩៤។ ទោះជាការសិក្សានេះ ពុំផ្តោតលើការដុតកំបោរក៏ពិតមែន ប៉ុន្តែអាចឱ្យយើងដឹងព័ត៌មានមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការយកកំបោរមកលាយធ្វើជាកំបោរបាយអ ដើម្បីបូកពាសជញ្ជាំង ធ្វើក្បាច់ចម្លាក់សម្អប្រាសាទ។ល។ ចំពោះអត្ថបទដែលយើងខ្ញុំនឹងលើកយកមកបង្ហាញនៅទីនេះ មិននិយាយពីការធ្វើកំបោរដូចខាងលើនេះទេ គឺលើកយករបរដុតកំបោរពីសម្បកលៀស ដែលជាមុខរបរប្រចាំគ្រួសារមួយនៅក្នុងភូមិមមាញ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលធ្វើសម្រាប់តែលក់ឱ្យអ្នកប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ដូចជាសម្រាប់ទទួលទានស្លាម្លូ ពោលពុំមែនប្រើប្រាស់ក្នុងវិស័យសំណង់ទេ។ះ

២. ប្រវត្តិដុតកំបោរ

ភូមិមមាញស្ថិតនៅក្នុងភូមិសាស្ត្រឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ អ្នករស់នៅក្នុងភូមិមមាញ ភាគច្រើនមានរបរធ្វើស្រែចម្ការ និងមានរបរបន្ទាប់បន្សំផ្សេងទៀតដូចជា៖ ដាំបន្លែ ចិញ្ចឹមសត្វ ធ្វើគោមលក់ លក់ចាប់ហួយ និងធ្វើកម្មករសំណង់។ល។ ដើម្បីយកកម្រៃទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។ ដោយឡែកក្នុងនោះមានតែគ្រួសារលោកប៊ិន មី តែមួយប៉ុណ្ណោះ ដែលប្រកបរបរដុតកំបោរលៀសជារបរប្រចាំគ្រួសារ។ លោកប៊ិន មី អាយុ៥៥ឆ្នាំ បានប្រកបរបរដុតកំបោរតាំងពីអំឡុងឆ្នាំ២០០០ រហូតដល់សព្វថ្ងៃ មានរយៈពេល២៣ឆ្នាំមកហើយ។ គាត់ចេះដុតកំបោរពីលោកស្រីណាន អាយុ៥៣ឆ្នាំ ត្រូវជាបងប្អូនខាងប្រពន្ធ កាលពីគាត់រស់នៅភូមិស្វាយជ័យ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង (រូបលេខ៧)។ លោកស្រីណាន ចេះដុតកំបោរសម្បកលៀសនេះពីម្តាយគាត់ តាំងពីមានអាយុ១៦ឆ្នាំមកម្ល៉េះ។ កាលពីមុន នៅភូមិស្វាយជ័យមានអ្នកប្រកបរបរដុតកំបោរប្រហែល៨ ទៅ៩គ្រួសារដែរ ប៉ុន្តែសព្វថ្ងៃនេះ នៅសល់តែ៣គ្រួសារតែប៉ុណ្ណោះដែលនៅបន្តរបរដុតកំបោរ ក្រៅពីនេះ ពួកគាត់ទៅប្រកបរបរផ្សេងៗទៀតអស់ហើយ។ សព្វថ្ងៃនេះ យើងពុំដែលឃើញនៅតាមភូមិមួយចំនួនក្នុងតំបន់អង្គរមានអ្នកដុតសម្បកខ្យង ខ្ចៅ លៀស ឬគ្រុំធ្វើកំបោរដូចភូមិទាំងពីរខាងលើនេះទេ។ របរដុតកំបោរក្នុងភូមិទាំងពីរខាងលើនេះ មានទំនាក់ទំនងជាមួយនឹងបរិស្ថាននៃភូមិស្រុកផ្ទាល់តែម្តង។ បើយើងសង្កេតជារួម ភូមិសាស្ត្រភូមិទាំងពីរនេះ នៅមិនឆ្ងាយប៉ុន្មានពីទន្លេសាបទេ គឺប្រហែល ១៤គ.ម. ដែលសម្បូណ៌ទៅដោយលៀស។ល។ ហើយនៅក្នុងភូមិស្រុកទៀតសោតក៏អាចរកអង្កាមដែលជាវត្ថុធាតុសំខាន់សម្រាប់ដុតកំបោរបានដោយងាយស្រួលផង។



រូបលេខ២៧. ទីតាំងភូមិមមាញ និងភូមិស្វាយជ័យ

៣. លៀស

លៀសជាវត្ថុធាតុដើមសំខាន់មួយក្នុងចំណោមវត្ថុធាតុផ្សេងទៀតសម្រាប់យកមកដុតធ្វើជាកំបោរ។ អ្នកដុតកំបោរនៅភូមិទាំងពីរខាងលើទៅរកទិញសម្បកលៀសពីអ្នកលក់នៅភ្នំក្រោម និងខ្លះទៀតទៅទិញពីកន្លែងលក់លៀសបោះដុំនៅផ្លូវ៦០ម៉ែត្រ (រូបលេខ២៨-៩) ដែលទិញពីទន្លេសាប។[៣] ពីមុនដើម្បីឱ្យកំបោរដែលដុតបានមានគុណភាពល្អ និងបានបរិមាណច្រើន អ្នកដុតត្រូវរើសសម្បកលៀសណាដែលមានទំហំធំ ហើយក្រាស់ ព្រោះពេលដុតវាមិនសូវខ្ទូច ឬស្អុយ។ ប៉ុន្តែសព្វថ្ងៃនេះ សម្បកលៀសដែលមានទំហំធំ ហើយក្រាស់ពិបាករក ដូច្នេះសម្បកលៀសតូចៗក៏យកមកដុតបានដែរ។ សម្បកលៀសដែលត្រូវយកមកដុតធ្វើកំបោរនោះ ពុំចាំបាច់លាងសម្អាតយកដីចេញទេ។

[៣] ផ្លូវ៦០ម៉ែត្រ បានស្ថាបនានៅឆ្នាំ២០០២ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារបារាំង (ADF)។ ផ្លូវនេះមានពីរខ្សែ៖ ខ្សែទី១ចាប់ពីចំណុចកែងមុខមន្ទីរពេទ្យគន្ធបុប្ផាទៅដល់ទីស្នាក់ការអាជ្ញាធរជាតិអប្សរា ហើយខ្សែទី២ ភ្ជាប់ពីចំណុចកែងផ្លូវជាតិលេខ៦ ទៅដល់ផ្លូវវង់តូចក្បែរប្រាសាទក្រវាន់។ សព្វថ្ងៃផ្លូវខ្សែទី១ មានឈ្មោះថា «វិថីសម្តេចវិបុលបញ្ញា សុខ អាន»។

រូបលេខ៨-៩. សម្បកលៀសទិញពីផ្លូវ៦០ម.

៤. អង្កាម

លោក ប៊ិន មី ពុំបានប្រើឧស ធ្យូង អគ្គិសនី ឧស្ម័ន ឬប្រេងឥន្ធនៈ ដើម្បីដុតកំបោរទេ គាត់នៅតែបន្ត ប្រើរបៀបបុរាណ ដែលបានរៀនពីអ្នកភូមិស្វាយជ័យ គឺប្រើអង្កាមដុតក្នុងចង្ក្រានតែប៉ុណ្ណោះ ព្រោះត្រឹមតែ របរជាលក្ខណៈគ្រួសារផលិតកំបោរបានបរិមាណតិចតួចប៉ុណ្ណោះ។ អង្កាមជាវត្ថុធាតុមួយសំខាន់ ដើម្បីដុត យកកម្ដៅធ្វើឱ្យឆេះសម្បកលៀសសុសផុសក្លាយជាកំបោរ និងងាយរកបាននៅក្នុងភូមិដោយពុំចាំបាច់ទិញ ពោលគឺសុំពីរោងកិនស្រូវនៅក្បែរផ្ទះតែប៉ុណ្ណោះ(រូបលេខ១០-១១)។

រូបលេខ១០. រោងម៉ាស៊ីនកិនស្រូវក្នុងភូមិ និងរូបលេខ១១. ពំនូកអង្កាម

៤. ចង្ក្រាន

ជាទូទៅការដុតកំបោរពីថ្មក្នុងបរិមាណច្រើនៗ គេតែងដុតនៅក្នុងឡដោយប្រើឧស ដូចឃើញមាននៅក្នុងស្រុកបន្ទាយមាស ខេត្តកំពតសព្វថ្ងៃនេះ។ ឡមានជញ្ជាំងរៀបឥដ្ឋឱ្យមានកម្រាស់ក្រាស់ ដោយទុកផ្នែកខាងក្នុងជាបន្ទប់មួយ រីកផ្នែកខាងលើបន្តិចត្រង់កន្ទ្រៃងមានល្បាក់មួយ ហើយទុកមាត់ចំហឥតមានដំបូល។ ឡនេះមានសណ្ឋានប្រហែលគ្នានឹងឡដុតឥដ្ឋសព្វថ្ងៃនេះដែរ តែមានទំហំតូចជាង ហើយមាត់លើបើកចំហមើលទៅដូចជាគុកស្ករដ៏ធំមួយ ហើយផ្នែកខាងក្រោមមានច្រកធំល្មមសម្រាប់បញ្ចូលឧស (គង់ វីរៈ ២០១១-២០១២)។ ដោយឡែក ការដុតកំបោរពីសម្បកលៀសនៅភូមិមមាញពុំប្រើឡទេ គឺគេប្រើចង្ក្រាន។ ដោយសារចង្ក្រានដែលពោលមកនេះ ដំណើរការជាលក្ខណៈគ្រួសារ ហើយអាចដុតសម្បកលៀសបានទម្ងន់តែប្រហែល៣០គីឡូក្រាមតែប៉ុណ្ណោះ ដូច្នេះទំហំក៏មិនសូវធំពេកទេ ពោលគឺមាត់លើមានមុខកាត់១,៥០ស.ម. កម្ពស់ប្រមាណ១ម.។ ចង្ក្រាននេះ មានរាងមូល កឡើងដោយរៀបឥដ្ឋជារង្វង់ ហើយបូកដីឥដ្ឋពីខាងក្រៅ និងមានមាត់រីកផ្នែកខាងលើ។ ផ្នែកខាងក្រោមរៀបឥដ្ឋឱ្យមានសណ្ឋានដូចជាបាតខ្ទះ ដោយមានក្រាលចន្ទាសដែកកម្ពស់៥ស.ម. ពីបាតចង្ក្រាន ដើម្បីឱ្យខ្យល់ចេញចូលពេលដុត និងទុកឱ្យអង្កាមដែលឆេះសុសធ្លាក់ទៅបាតចង្ក្រានផង។ នៅលើចន្ទាសមានទ្រនាប់ធ្វើពីដែកធុងសាំងមានចោះរន្ធតូចៗមួយជាន់ទៀត ដើម្បីឱ្យខ្យល់ចេញចូលធ្វើឱ្យមានចំហេះល្អនៅពេលដុត និងទ្រអង្កាម និងសម្បកលៀសកុំឲ្យធ្លាក់ទៅបាតធ្វើឱ្យស្ទះរន្ធខ្យល់។ នៅខាងមុខចង្ក្រានមានចោះប្រហោងធំមួយ ដើម្បីដាក់កង្ហារអគ្គិសនីសម្រាប់បឺតខ្យល់ជួយបង្កើនសំពាធខ្យល់ក្នុងករណីពុំមានខ្យល់ចូលដល់ក្នុងចង្ក្រាន។ ចង្ក្រាននេះពុំមានបំពង់ផ្សែងទេ ហើយអាចដុតបានកម្តៅប្រហែល១១០អង្សាសេ (រូបលេខ១២-១៦)។

រូបលេខ១២. ចង្ក្រានដុតកំបោរ

រូបលេខ១៣-១៤. ចង្ក្រានដុតកំបោរ



និងរូបលេខ១៥-១៦. គំនូរចង្ក្រាន

៦. របៀបដុត

ជាធម្មតា លោក ប៊ុន មី តែងដុតកំបោរជារៀងរាល់ថ្ងៃ ដោយនៅពេលរសៀលគាត់រៀបចំអង្កាម និងសម្បកលៀសទុកនៅក្បែរចង្ក្រាន លុះដល់ពេលទៀបភ្លឺទើបចាប់ផ្ដើមរៀបចំដុត ដើម្បីកុំឱ្យរំខានដល់អ្នកជិតខាង ព្រោះពេលដុតម្ដងៗមានផ្សែង និងផេះអង្កាមហុយចេញខ្លាំងៗ ដំបូងគាត់រៀបអង្កាមដាក់នៅលើចន្ទាសដែកក្នុងពោះចង្ក្រាន រួចរាចកាយឱ្យស្មើងកម្រាស់ប្រហែលមួយចង្អុលដៃ ទើបចាក់សម្បកលៀសពីលើអង្កាម រួចរាចរីកាយរាយឱ្យស្មើងកម្រាស់ប្រហែលមួយចង្អុលដៃដែរ រួចដុតស្រទាប់អង្កាមនេះឱ្យឆេះ បន្ទាប់មកទៀតយកអង្កាមចាក់លើស្រទាប់សម្បកលៀសមួយជាន់ទៀត ហើយកាយរាយឱ្យស្មើងមានកម្រាស់ប្រហែលគ្នានឹងស្រទាប់ទីមួយដែរ។ គាត់រៀបស្រទាប់អង្កាម និងស្រទាប់សម្បកលៀសឆ្លាស់គ្នារហូតដល់ស្រទាប់ទីមួយៗបានចំនួន៩ស្រទាប់ដូចគ្នា ដោយស្រទាប់នីមួយៗមានកម្រាស់ប្រហែលមួយចង្អុលដៃ ការធ្វើ

បែបនេះ ដើម្បីឱ្យអង្កាមឆេះបានល្អ ជួយបង្កើនកម្ដៅ និងធ្វើឱ្យភ្លើងឆេះធំបានល្អនៅពេលដុត។ ពេលដុតមួយលើកៗ គាត់ត្រូវការសម្បកលៀសចំនួន១បាវ ដែលមានទម្ងន់ប្រហែល៣០គីឡូក្រាម។ ក្នុងអំឡុងពេលដុតមិនត្រូវឱ្យភ្លើងឆេះសន្ធោសន្ធៅខ្លាំងពេកទេ គឺធ្វើយ៉ាងណាថែភ្លើងឱ្យឆេះស្មើធំៗ ដេញពីមួយស្រទាប់ទៅមួយស្រទាប់ទៀតរហូតឆេះអស់ ដោយមិនអាចឱ្យដាច់ភ្លើងបានទេ (រូបលេខ១៧-២០)។ គាត់ប្រើពេលពី២ម៉ោង ទៅ២ម៉ោងកន្លះ ទើបសម្បកលៀសឆេះសុសបានល្អ ហើយផេះអង្កាមខ្លះបានធ្លាក់ទៅបាតចង្ក្រាន ចំណែកសម្បកលៀសដែលឆេះសុសមានពណ៌សនៅលាយឡំជាមួយផេះអង្កាម ធ្លាក់ទៅលើទម្រចន្ទាស។ ប៉ុន្តែពេលខ្លះសម្បកលៀសមិនឆេះសុសទាំងអស់ទេ ព្រោះមានខ្លះនៅរឹង ដោយសារពុំបានប៉ះកម្ដៅភ្លើងគ្រប់គ្រាន់បែបនេះគេហៅថាស្អុយ។

រូបលេខ១៧-២០. ដុតកំបោរ

លុះពេលសម្បកលៀសចុះត្រជាក់ល្មមអាចចាប់កាន់បាន គាត់សម្អាតផេះអង្កាមដែលនៅលាយឡំជាមួយគ្នាចេញ ដោយប្រើកំណាត់មួយផ្ទាំងបក់ផេះអង្កាមឱ្យហុយចេញ ហើយកំបោរដែលទទួលបានក្រោយពី

សម្អាតផេះរួច នេះហៅថា «កំបោរឆៅ»។ កំបោរដែលទទួលបានក្រោយពេលដុតម្តងៗមានទម្ងន់ប្រហែល ពី១៥ ទៅ១៦គីឡូក្រាម គឺអាស្រ័យលើសម្បកលៀសក្រាស់ ឬស្តើង។ តាមធម្មតាសម្បកលៀសទម្ងន់១គីឡូក្រាម ដុតបានកំបោរទម្ងន់០,៥០គីឡូក្រាម (រូបលេខ២១-២៣)។



រូបលេខ២១. ផេះអង្កាម និងសម្បកលៀសឆេះសុស

រូបលេខ២២-២៣. កំបោរឆៅ

ដោយឡែក ក្រោយពីបានកំបោរនៅ ដូចក្នុងរូបលេខ១៨ និង១៩ ហើយគាត់យកទៅបុកលាយជាមួយទឹកស្អាត ដោយដាក់ទឹកលាយឱ្យស្មើសាច់ ដើម្បីកុំឱ្យរឹងពេក ឬជ្រាយពេក ទើបកំបោរស្អិតល្អ។ ល្បាយកំបោរដែលទើបលាយជាមួយទឹករួចនេះ គេហៅថា «កំបោរឆ្អិន» (រូបលេខ២៤-២៦)។ កំបោរនៅទម្ងន់ពី១៥ទៅ១៦គីឡូក្រាម ក្រោយបុកលាយជាមួយទឹកបានជាកំបោរឆ្អិនស្អិតល្អហើយអាចមានទម្ងន់ប្រហែល៣០គីឡូក្រាម។ បន្ទាប់មកគាត់បានយកកំបោរឆ្អិនច្រកដាក់ថង់ ដោយក្នុងមួយថង់ៗមានទម្ងន់១គីឡូក្រាម ដើម្បីយកទៅលក់ឱ្យឈ្មួញនៅតាមផ្សារ ហើយម្យ៉ាងទៀត ដើម្បីការពារកុំឱ្យត្រូវខ្យល់ខ្វាចកំបោរងាប់។ យើងពុំដឹងថា ពីមុនមកមានកិច្ចពិធី ឬត្រណមអ្វីខ្លះទេ ដែលពាក់ព័ន្ធនឹងការដុតកំបោរនេះទេ ប៉ុន្តែសព្វថ្ងៃនេះយើងពុំឃើញគាត់ធ្វើកិច្ចអ្វីនៅមុនពេលដុត ឬក្រោយពេលដុតកំបោរទេ។

រូបលេខ២៤. កំបោរនៅបុកលាយជាមួយទឹក

រូបលេខ២៥. កំបោរឆ្អិន

រូបលេខ២៦. ថង់កំបោរ

៧. លក់ដូរ

ដូចបានជម្រាបជូនពីខាងដើមរួចមកហើយ លោក ប៊ុន មី បានយកការដុតកំបោរជារៀងរាល់ថ្ងៃធ្វើជារបរ ដើម្បីរកកម្រៃមកទ្រទ្រង់ជីវភាពគ្រួសារ។ ចំពោះការលក់ដូរឃើញថាក៏មិនលំបាករកម៉ូយដែរ ព្រោះសព្វថ្ងៃអ្នកប្រកបរបរដុតកំបោរមានចំនួនតិចតួច ពោលគឺគាត់យកកំបោរដែលដុតបានទៅលក់ឱ្យឈ្មួញកណ្ដាលនៅផ្សាររលួស និងផ្សារលើក្នុងក្រុងសៀមរាបរៀងរាល់ពីរថ្ងៃម្ដង។ ឈ្មួញបានលក់កំបោរទាំងនោះបន្តទៅឱ្យអ្នកប្រើប្រាស់តាមតម្រូវការផ្សេងៗទៀតដូចជា៖ ហូបស្លាម្លូ បណ្ដុះសណ្ដែក លាយជាមួយទឹកសម្រាប់ត្រាំលាងម្ជូរ លាងពោះគោ ដោលើថ្នាសក្មេង ដោលើជញ្ជាំងផ្ទះព័ទ្ធសីមា និងលាបលើស្នាមអុជប៉ុយលើរាងកាយមនុស្ស ដើម្បីកែរោគ។ល។ មានពេលខ្លះឈ្មួញមករកទិញដល់ផ្ទះគាត់តែម្ដងក៏មាន (រូបលេខ២៧-៣២)។

រូបលេខ២៧-២៩. អ្នកលក់កំបោរនៅផ្សាររលួស និងរូបលេខ៣០-៣២. អ្នកលក់កំបោរនៅផ្សារលើ

ក្រៅពីលក់ឱ្យឈ្មួញ ដើម្បីចែកចាយបន្តសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ គាត់ក៏បានលក់កំបោរ ឆៅ (សូមមើលរូបលេខ២៤) ទៅឱ្យអ្នកជំនាញអាផ្សាធរជាតិអប្សរា ដែលកំពុងអភិរក្ស និងជួសជុលប្រាសាទ

ឥដ្ឋក្នុងតំបន់អង្គរ និងនៅលើភ្នំគូលែនខ្លះដែរ ដើម្បីធ្វើជាកំបោរបាយអ[៦] ប្រើប្រាស់ក្នុងការជួសជុល ពង្រឹងរចនាសម្ព័ន្ធប្រាសាទឥដ្ឋ ដូចជានៅៈ ប្រាសាទព្រះគោ ប្រាសាទលលៃ ប្រាសាទបាគង ប្រាសាទគោកចក ប្រាសាទភ្នំបាខែង ប្រាសាទប្រែរូប និងប្រាសាទមួយចំនួនទៀតនៅលើភ្នំគូលែន(រូបលេខ៣៣-៣៨)។

រូបលេខ៣៣-៣៨. លាយកំបោរឆៅជាមួយខ្សាច់ កម្ទេចឥដ្ឋ ស្ករត្នោត និងការស្បែកគោ ធ្វើកំបោរបាយអប្រើសម្រាប់ភ្ជាប់ឥដ្ឋ និងឥដ្ឋ

[៦] កំបោរបាយអនេះផ្សំពីកំបោរលៀសលាយជាមួយខ្សាច់ កម្ទេចឥដ្ឋ ស្ករត្នោត និងការស្បែកគោ ប្រើសម្រាប់ភ្ជាប់ឥដ្ឋ និងឥដ្ឋ។

តាមរយៈរបរនេះ លោក ប៊ុន មី អាចរកចំណូលសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ បានគួរសមដែរ ដោយកំបោរឆ្អិន១គីឡូក្រាមលក់បានតម្លៃ៣,០០០រៀល។ ដូច្នេះក្នុងរយៈពេលពីរថ្ងៃគាត់អាចរកប្រាក់បាន ៩០,០០០រៀលដែរ។ ដោយឡែក ចំពោះកំបោរឆៅដែលអ្នកជំនាញខាងអភិរក្ស និងជួសជុលប្រាសាទទិញ ដើម្បីលាយធ្វើកំបោរបាយអសម្រាប់ជួសជុលប្រាសាទឥដ្ឋវិញ អាចលក់បានតម្លៃ៤,៥០០រៀល ក្នុង១គីឡូក្រាម ប៉ុន្តែពុំមែនលក់បានរាល់ថ្ងៃទេ គឺពេលដែលក្រុមគាត់ប្រើអស់ទើបមកទិញថែមទៀត។

ឯកសារយោង

គង់ វីរៈ (២០១១-២០១២). *របរដុតកំបោរនៅស្រុកបន្ទាយមាស ខេត្តកំពត*, បណ្ដាញ ព័ត៌មាន វប្បធម៌ខ្មែរ, លេខ៧, ទំព័រ ១៩-២៤, ភ្នំពេញ

តាន់ សុផល (២០១៩). *កិច្ចការអភិរក្ស និងជួសជុលប៉មឥដ្ឋលេខ៨ ប្រាសាទបាគង*, ព្រះនគរលេខ១ ទំព័រ ៣៣-៤៧, ភ្នំពេញ

ពុទ្ធសាសនបណ្ឌិត (១៩៨៩). *វចនានុក្រមខ្មែរភាគទី១* បោះពុម្ពឡើងវិញនៅប្រទេសជប៉ុន, ទំព័រ៨១, តូក្យូ

យី សុជា (២០១៦). *របរដុតកាំបោរបស់អ្នកភូមិធ្វកមាស ជៅស្រុកបន្ទាយមាស ខេត្តកំពត*, សារណា បុរាណវិទ្យា,ជំនាន់ទី២៤, ភ្នំពេញ

លី វណ្ណា (១៩៩៤). *ចម្លាក់កាំចោរចាយអខ្មែរ*, សារណាបុរាណវិទ្យា, ជំនាន់ទី១, ទំព័រ៧ភ្នំពេញ

បទភ្លេង និងទំនុកច្រៀង៖ ភ្លេងមេមត់នៅតំបន់អង្គរ

ទិន ទីណា, អ៊ូ គង្គា, សោ ចន្ទា, តូច សុកៈ, ជា សំបូរ, ឆាន់ សុភីនី និង សក្តិ សេដ្ឋា

១. សេចក្តីផ្តើម

អង្គរជាមរតកវប្បធម៌ដ៏ខ្ពង់ខ្ពស់នៃប្រជាជាតិខ្មែរ ដែលមានដំណែលពីបុរាណដ៏ច្រើនលើសលប់ បន្តឥតដាច់រហូតបង្កើតបានជាអារ្យធម៌ដ៏ធំធេងមួយ ដែលបានចាក់ឫសគល់ទៅគ្រប់ទិដ្ឋភាពនៃសង្គមខ្មែរ។ បុរាណវត្ថុទាំងឡាយដែលបន្សល់ទុករហូតមកដល់សព្វថ្ងៃនៅលើទឹកដីសៀមរាប-អង្គរ មានប្រាង្គប្រាសាទ ផ្តាំងចម្លាក់ បដិមា សិលាចារឹក (ជាភាសារខ្មែរ និងភាសាសំស្ក្រឹត) ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធស៊ីវិល។ល។ បើយកប្រពៃណីទំនៀមទម្លាប់ពិធីផ្សេងៗមកពោលវិញ គេសង្កេតឃើញថា មានតំណែលបុរាណជាច្រើនត្រូវបានថែរក្សា និងបន្តគោរពប្រតិបត្តិរហូតមកដល់សព្វថ្ងៃ ដូចជា ជំនឿដែលគេហៅថា «ជំនឿជីវចល» ដូចជាជំនឿលើ «មេមត់» ជាដើម ដែលអ្នកស្រុកអង្គរមួយចំនួនធំនៅតែប្រតិបត្តិតរៀងមក។

ជាទូទៅស្រុកឬតំបន់ខ្វះគេហៅថា«អារក្ស» ក៏ប៉ុន្តែនៅតំបន់អង្គរគេនិយមហៅ«មេមត់» មិនសូវព្រប្រើពាក្យអារក្សទេ។ ដូច្នេះហើយបានជាគេច្រើនហៅថា «ភ្លេងមេមត់» «ជាន់មេមត់» និង «លៀងមេមត់»។ មេមត់គឺជាខ្មោចជួរចំបួរប្រចាំត្រកូល ហើយមាន "រូបស្នង" ដែលភាគច្រើនជាមនុស្សស្រី។ «រូបស្នង» ដើរតួនាទីសំខាន់ក្នុងកិច្ចជាន់មេមត់ រកមើលហេតុនៃវិបត្តិតូច ធំដែលកើតឡើងផ្ទាល់ខ្លួន, ក្នុងគ្រួសារ ឬតាមការពឹងពាក់ពីអ្នកស្រុកជិតឆ្ងាយ ដូចជាពេលមានជម្ងឺ ឬក៏បាត់បង់វត្ថុអីមួយ។ល។ ពេលខ្មោច ឬចំបួរចូលមកហើយ គេខ្ចីមាត់មេមត់ប្រាប់ពីដើមចមដែលបណ្តាលឱ្យមានជម្ងឺ ឬវិបត្តិ និងប្រាប់ឱ្យរៀបចំនេះ រៀបចំនោះ ដូចជាពៃ បាយស្រី ឬស្វាធម៌ជាដើម ហើយជួនកាលមេមត់ក៏ព្យាបាលយើង ដោយស្តោះ ផ្លុំទៀតផង។ លុះបានផល ឬជាពីជម្ងឺដោយធ្វើតាមពាក្យខ្មោចប្រាប់ យើងត្រូវលៀងកម្សាន្តឱ្យអមនុស្ស ជាការដឹងគុណដែលប្រាប់ពីហេតុផល និងខំមើលយើងជា។ ពិធីលៀងនេះ គេហៅ «លៀងមេមត់»។ គេជឿថា មនុស្សម្នាក់ៗតែងមានគ្រូកំណើត ឬផ្លូវជាពិសេសអ្នកកើតមកមានជាប់សំណុំសង្វារ (អាំង ជូលាន ២០០៥-២០០៦)។ គ្រូកំណើតអាចទំមនុស្ស

(ឬហៅថាសម្បក) ពីមួយជំនាន់ទៅមួយជំនាន់ ដែលស្ថិតនៅក្នុងសៃស្រឡាយគ្រួសារមានជាប់សាច់ឈាមគ្នា។ អមនុស្សនេះអាចធ្វើឱ្យរូបស្នងនោះឈឺ។ ហេតុនេះ ដើម្បីជៀសវាងកុំឱ្យឈឺត្រូវលៀងមេមត់។ ពាក្យ «លៀង» មានន័យថា រៀបពិធីបូជាលោមអង្វរដល់ខ្មោច ឬចំបូរ ដោយមានបាយចំណីព្រមទាំងលេងភ្លេងផងជូនកាលមានរៀបចំ ឬចំណាយប្រាក់ចាត់ចែងភោជនាហារឱ្យភ្ញៀវបរិភោគ។[១] បើយកពាក្យ «លៀង» មកពិចារណាក៏អាចយល់បានថា ពាក្យនេះសំដៅដល់ការធ្វើឱ្យសប្បាយរីករាយ។ ម៉្លោះហើយទើបមានពាក្យដល់សព្វថ្ងៃថា «ជប់លៀង»។ ដើម្បីឱ្យបរិយាកាសកាន់តែសប្បាយរីករាយ ភ្លេងជាគ្រឿងរណ្តាប់មួយយ៉ាងសំខាន់។ ជាទូទៅតង្វាយ ឬសំណែនដែលសែនទៅអមនុស្សតែងទាក់ទងនឹងញាណទាំង៥ពោលគឺ សោតវិញ្ញាណ (ត្រចៀក) ចក្ខុវិញ្ញាណ (ភ្នែក) ជិវ្ហាវិញ្ញាណ/អណ្តាត (មាត់) ឃាណវិញ្ញាណ (ច្រមុះ) និងអារម្មណ៍។ គ្រឿងរណ្តាប់ទាំងអស់តែងបំពេញញាណទាំង៥ខាងលើនេះ។ ឧទាហរណ៍ បាយម្ហូបសម្រាប់មាត់ ផ្កាសម្រាប់ភ្នែក។ ឯចំពោះត្រចៀកនោះ គឺភ្លេងដែលជារណ្តាប់សំខាន់ក្នុងកិច្ចពិធីនានា។ ចំពោះពិធីលៀងមេមត់ ភ្លេងអាចទាក់ទងត្រចៀកផង និងអារម្មណ៍ផង ដ្បិតត្រូវលេងឱ្យមេមត់រាំលេងសប្បាយ (រូបលេខ១-២)។

រូបលេខ១ និងលេខ២៖ វង់ភ្លេងភូមិថ្នល់បាក់លេងក្នុងពិធីលៀងមេមត់នៅភូមិគោកចាន់

តាមការសិក្សា និងអង្កេតទាក់ទងនឹងកិច្ចពិធីលៀងមេមត់នៅតំបន់អង្គរ យើងឃើញថា កិច្ចពិធីលៀងមេមត់មានរបៀបពីរយ៉ាង៖

១. កិច្ចពិធីលៀងជាលក្ខណៈឯកជន ដោយមានរៀបចំសំណែនជាម្ហូបអាហារ ព្រមទាំងមានភ្លេងមេមត់ផង ដើម្បីជាការដឹងគុណដល់ខ្មោច ឬចំបូរ ដែលខំមើលជម្ងឺជា ឬរកវត្ថុអ្វីមួយដែលបានបាត់បង់ទៅហើយឃើញមកវិញ។ កិច្ចពិធីនេះ ច្រើនចាប់ធ្វើនៅពេលថ្ងៃត្រង់ ឬក៏រសៀល។

---

[១] សូមមើលវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិតភាគទី១ បោះពុម្ពឡើងវិញនៅប្រទេសជប៉ុន ឆ្នាំ១៩៨៩, ទំព័រ១១៤៥។

២. កិច្ចពិធីលៀងមួយទៀតជាលក្ខណៈសហគមន៍ ដែលធ្វើរៀងរាល់ឆ្នាំ ឬអ្នកខ្លះ ភូមិខ្លះទាល់តែពីរ ឬបីឆ្នាំម្តង ទោះជាឈឺ ឬមិនឈឺអីក៏ដោយ គឺត្រូវតែធ្វើពិធីលៀងមេមត់។ កិច្ចពិធីនេះគេចំណាំធ្វើនៅខែមាឃ ឬអាចធ្វើក្នុងបរិបទពិសេសណាមួយនៅពេលមានរូបមេមត់ ឬ«សម្បក» ឈឺធ្ងន់។ អមនុស្សនេះអាចធ្វើឱ្យរូបស្នងនោះឈឺ។ ហេតុនេះ ដើម្បីជៀសវាងកុំឱ្យឈឺ ត្រូវលៀងមេមត់ក្នុងមួយឆ្នាំ ឬពីរឆ្នាំម្តង។ ក្នុងកិច្ចពិធីលៀងនេះ សិស្សគុណដែលធ្លាប់មេមត់រូបហ្នឹងមើលជា ឬធ្លាប់មករកឱ្យជួយមើលពីវិបត្តិតូច ធំដែលកើតឡើងផ្ទាល់ខ្លួន ឬក្នុងគ្រួសារ តែងតែមកជួបជុំគ្នាហើយគេកំសាន្តសប្បាយមួយយប់ គោលបំណងធំ គឺលៀងឱ្យមេមត់ហ្នឹងសប្បាយ។ ប៉ុន្តែ បើអ្នកលេងភ្លេង ឬអ្នកច្រៀងលេងពុំត្រូវចិត្តនោះទេ អមនុស្សក៏មិនចូលសណ្ឋិតដែរ។ ក្នុងពិធីលៀងនេះដែរ រូបស្នងក៏ឆ្លៀតបញ្ជាន់មេមត់ដែលជាគ្រូកំណើត ឬចំបូររបស់ខ្លួន ឡើងរាំតាមចង្វាក់ភ្លេង ហើយអ្នកខ្លះគេឆ្លៀតមករកមើលពីវិបត្តិតូច ធំផ្ទាល់ខ្លួន ឬគ្រួសារ ហើយជួនកាលមេមត់ហ្នឹងក៏ព្យាបាលអ្នកជម្ងឺ ដោយស្តោះព្រួសក្នុងពេលលៀងនោះទៀតផង។

ភ្លេងដែលលេងក្នុងពិធីនេះ ជាទូទៅហៅ «ភ្លេងមេមត់» ឬ«ភ្លេងអារក្ស»។[២] ជាងនេះទៀត ភ្លេងមេមត់ ឬភ្លេងអារក្សនេះអាចលេងនៅពេលឡើងមាយ(អ្នកតា) ក្នុងខែមាឃ និងពិធីសុំទឹកភ្លៀងជាដើម។ លើសពីនេះទៅទៀត បទខ្លះក៏អាចយកមកលេងក្នុងពិធីមង្គលការទៀតផង។

តាមរយៈការចុះអង្កេតក្នុងពិធីលៀងមេមត់នៅតាមភូមិមួយចំនួននៅតំបន់អង្គរ យើងបានចាប់អារម្មណ៍ថាមានបទភ្លេង និងទំនុកច្រៀងមួយចំនួនបានបាត់បង់ ដោយការមិនសូវនិយមលេង ហើយវង់ភ្លេងមេមត់ខ្លះទៀតប្រឈមបាត់បង់ខ្លាំងនៅពេលខាងមុខ ព្រោះសមាជិកវង់ភ្លេងខ្លះមានវ័យចំណាស់ អ្នកជំនាន់ក្រោយមិនចាប់អារម្មណ៍ហាត់រៀន និងខ្លះទៀតបានចាប់យករបរផ្សេងដែលអាចរកកម្រៃបានច្រើន។ ជាធម្មតា មត៌កអរូបីងាយនឹងបាត់បង់ណាស់ ដ្បិតជាចំណេះនៅជាប់នឹងមនុស្ស។ បើមនុស្សនោះស្លាប់ ចំណេះទាំងប៉ុន្មានងាយនឹងបាត់បង់ទៅតាមនោះដែរ។ ជាមួយនឹងការប្រឈមបាត់បង់បែបនេះ យើងបានសិក្សាស្រាវជ្រាវពីភ្លេងមេមត់ ដោយចងក្រងជាអត្ថបទទំនុកច្រៀង និងអាត់សម្លេងពីចង្វាក់ភ្លេង ដែលជាមធ្យោបាយមួយមានសារសំខាន់ក្នុងការអភិរក្ស និងលើកតម្លៃមតកអរូបីក្នុងតំបន់អង្គរ។ ក្រុមភ្លេងនៅភូមិចំនួន៥ត្រូវជ្រើសរើសដើម្បីសិក្សា ក្នុងនោះមាន៖ ភូមិថ្នល់បាក់, ភូមិអូរទទឹង, ភូមិត្នោតជ្រុំ, ភូមិទ្រៀក និងភូមិក្វង់។ ហេតុដែលរើសយកភូមិខាងលើ ព្រោះភូមិនីមួយៗមានទីតាំងនៅឆ្ងាយពីគ្នា ហើយក្រុមភ្លេងទាំងនេះជាក្រុមដែលយើងបានចុះអង្កេតក្នុងពិធីលៀងមេមត់តាមភូមិ ឬឡើងមាយ (អ្នកតា) រួចមកហើយ។ ចំណែកភូមិត្នោតជ្រុំវិញ អ្នកភ្លេងភាគច្រើនមានវ័យចំណាស់អាចចាំបទចាស់ៗបានច្រើន ហើយកំពុងប្រឈមនឹងការបាត់បង់នាពេលខាងមុខដោយសារពុំសូវមានអ្នកចង់រៀនបន្ត (រូបលេខ៣)។

[២] ត្រង់នេះ យើងខ្ញុំសូមបញ្ជាក់បន្ថែមថា នៅតំបន់អង្គរ អារក្ស គឺជាអមនុស្សមួយបែបផ្សេងពីអារក្សដែលគេធ្លាប់សិក្សាកន្លងមកនៅតំបន់សម្បូរព្រៃគុកខេត្តកំពង់ធំ (អាន រស្មី ២០១១)។ នៅអង្គរ អារក្សពុំមានរូប ឬដូរទេ តែគេហាក់ដូចជាយល់ថា អារក្សជាអមនុស្សដែលរស់នៅក្នុងវិស័យព្រៃ ពោលគឺឆ្ងាយពីពិភពមនុស្សដែលគេមិនចង់ឱ្យមកនៅក្បែរមនុស្សឡើយ ឬសូម្បីតែរំពុក។



រូបលេខ៣៖ ទីតាំងភូមិទាំង៥

២. វង់ភ្លេងមេមត់

វង់ភ្លេងមេមត់ ឬអារក្សនៅភូមិទាំង៥ខាងលើ មានឧបករណ៍ភ្លេងច្រើនប្រភេទដូចជា៖ ស្គរ ទ្រអ៊ូ ទ្រសោ ទ្រខ្សែបី ឃឹម ឈឹង តាខេ ប៉ីអ និងចាប៉ីដងវែង ហើយវង់នីមួយៗមានគ្នាពី៥នាក់ រហូតដល់១០នាក់ ដែលខុសប្លែកពីវង់ភ្លេងមេមត់ ឬអារក្ស នៅស្រុកអង្គរជ័យ ខេត្តកំពត ដែលមានឧបករណ៍ភ្លេងតែ២ប្រភេទប៉ុណ្ណោះ គឺទ្រសោ និងស្គរមេមត់ ដោយមានអ្នកលេងទ្រសោម្នាក់ អ្នកលេងស្គរ២នាក់ និងអ្នកច្រៀងម្នាក់ (សូមមើល មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ,២០១៧)។ ដោយឡែក សមាជិកវង់ភ្លេងនៅភូមិទាំង៥ខាងលើ គឺមានខ្លះមិនរស់នៅក្នុងភូមិជាមួយគ្នាទេ ពោលមានអ្នកខ្លះមកពីភូមិដែលនៅជិតគ្នា ឬជួនកាលមកពីភូមិដែលនៅឆ្ងាយពីគ្នា។ ឯក្រុមខ្លះទៀតដែលមានសមាជិកមិនគ្រប់ តែងតែខ្ចីដៃអ្នកភ្លេងមេមត់មកពីភូមិផ្សេងមកជួយលេង ឧទាហរណ៍ក្រុមភ្លេងមេមត់នៅភូមិទ្រៀក។

២.១. វង់ភ្លេងមេមត់ភូមិថ្នល់ចាក់

ភូមិថ្នល់បាក់ស្ថិតនៅផ្នែកខាងកើតតំបន់អង្គរ ក្នុងឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ភូមិនេះមានផ្ទះពាយគ្នាជាខ្សែតាមបណ្តោយសងខាងទំនប់បុរាណមួយ ដែលមានស្ពានស្ពាមតភ្ជាប់ពីខាងត្បូងប្រាសាទអង្គរវត្តត្រង់ទៅកើតចម្ងាយ១០គ.ម. រហូតដល់ភូមិត្រពាំងរុន ក្នុងឃុំដដែល។ រៀងរាល់ឆ្នាំ អ្នកភូមិមួយចំនួនដែលនៅតែប្រកាន់ទំនៀមពីដូនតាខ្លួន តែងលៀងមេមត់ ឬអារក្ស នៅរវាងខែមាឃ ឬពេលដែល «រូប» មានជម្ងឺម្តងៗ។ ដូចបានជម្រាបពីខាងលើរួចមកហើយ ក្នុងពិធីលៀងមេមត់នេះ ភ្លេងមានតួនាទីយ៉ាងសំខាន់ ឬអាចនិយាយបានថា បើមិនមានភ្លេងក៏ពុំអាចធ្វើពិធីលៀងមេមត់បានដែរ។ នៅភូមិនេះមានវង់ភ្លេង «មេមត់» ឬ «អារក្ស» មួយវង់ដែលមានគ្រូ សុខ កើត ជាមេក្រុម។

វង់ភ្លេងនៅភូមិថ្នល់បាក់មានសមាជិកចំនួន៦នាក់ (រូបលេខ២៤) ខ្លះរស់នៅក្នុងភូមិនេះតែម្តង ហើយខ្លះទៀតមកពីភូមិបង្កោង (ឃុំអំពិល) និងភូមិក្រវាន់ (សង្កាត់នគរធំ) ដែលនៅមិនឆ្ងាយពីគ្នាប៉ុន្មានឡើយ។ សមាជិកវង់ភ្លេងនេះខ្លះលេងភ្លេងតាំងពីសម័យ ប៉ុល ពត និងខ្លះទៀតចេះភ្លេងតាមរយៈការរៀនពីគ្រូ នៅក្នុងភូមិតៗគ្នាចាប់ពីទសវត្សរ៍ឆ្នាំ១៩៨០ ដោយមួយចំនួនធំរៀនពីមេក្រុមផ្ទាល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ចំពោះជីវភាពរស់នៅ សមាជិកវង់ភ្លេងនេះពុំមែនលេងភ្លេងតែមួយមុខទេ ដ្បិតពួកគាត់ជាអ្នកធ្វើស្រែ ខ្លះធ្វើការនៅសាលាឃុំ លេងភ្លេងការ តួល្ខោនបាសាក់ និងជាជាងធ្វើផ្ទះ។ល។ ឧបករណ៍ភ្លេងក្នុងវង់នេះមាន៖ ស្គរឃឹម ទ្រខ្សែបី ឈឹង និងតាខេ។

រូបលេខ២៤៖ វង់ភ្លេងភូមិថ្នល់បាក់

២.១.១. សមាជិកវង់ភ្លេងភូមិថ្នល់ចាក់

លោក សុខ កើត

លោក សុខ កើត អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិថ្នល់បាក់ ឃុំអំពិល ស្រុកប្រាសាទបាគង។ លោកជាមេក្រុម និងជាគ្រូភ្លេង ហើយជាអ្នកច្រៀង និងជាអ្នកវាយស្គរប្រចាំក្រុម។ ក្រៅពីជំនាញច្រៀង និងវាយស្គរ គាត់អាចលេងចាប៉ី និងទ្រពបានទៀតផងដែរ។ ក្រៅពីលេងភ្លេងមេមត់ លោកបានប្រកបរបរជាអ្នកលេងភ្លេងការ ជាជាងធ្វើផ្ទះ និងធ្វើស្រែ។ លោកបានរំឭកថា គាត់បានចាប់ផ្តើមលេងភ្លេងក្នុងឆ្នាំ១៩៨២ ក្រោយពីបានរៀនពីលោកគ្រូធឿន លោកគ្រូសឹង លោកគ្រូសុង លោកគ្រូសាន និងលោកគ្រូហាន។

លោក ជុន ថា

លោក ជុន ថា អាយុ៥៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្នល់បាក់ ឃុំអំពិល ស្រុកប្រាសាទបាគង។ លោកជាអ្នកលេងទ្រខ្មែរ៣។ ក្រៅពីជំនាញលេងទ្រខ្មែរ៣ គាត់អាចលេងឃឹម និងតាខេបានទៀតផង។ លោកបានចាប់ផ្តើមលេងភ្លេងក្នុងឆ្នាំ២០០៩ ហើយក្រោយមកបានចូលលេងភ្លេងមេមត់ និងភ្លេងការក្នុងក្រុមលោកគ្រូសុខ កើត។ លោកក៏ជាអ្នកលេងភ្លេងការ និងធ្វើស្រែ។

លោក ទិត្យ តើម



លោកទិត្យ តើមអាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រវាន់ សង្កាត់នគរធំ ក្រុងសៀមរាប។ លោកជាអ្នកលេងឃឹម និងអាចលេងទ្របានដែរ។ លោកបានរំឭកថា នៅសម័យ ប៉ុល ពត គាត់ជាសមាជិកក្រុមភ្លេងក្នុងក្រុមសិល្បៈមួយ ហើយក្រោយឆ្នាំ១៩៧៩ គាត់បានលេងភ្លេងការតាមភូមិ ហើយទើបតែចូលមកលេងភ្លេងក្នុងក្រុមលោកគ្រូ សុខ កើត នេះទេ។ ក្រៅពីលេងភ្លេងមេមត់ លោកបានប្រកបរបរជាអ្នកលេងភ្លេងការនិងធ្វើស្រែដូចសមាជិកក្នុងក្រុមមួយចំនួនដែរ។

លោក លឿង ពេជ្រ

លោក លឿង ពេជ្រ អាយុ៥៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង។ លោក ជាអ្នកវាយស្គរ និងឈឹង ហើយពុំចេះលេងឧបករណ៍អ្វីក្រៅពីនេះបានទៀតទេ។ ក្រៅពីលេងភ្លេងមេមត់ លេងភ្លេងការ និងធ្វើស្រែ លោកក៏ជាសមាជិកក្រុមល្ខោនបាសាក់រស្មីគោកឫស្សី នៅស្រុកប្រាសាទបាគងផងដែរ។ គាត់បានចូលមកលេងភ្លេងក្នុងក្រុមលោកគ្រូ សុខ កើតនៅឆ្នាំ២០១៣។

លោក តិក សាយ័ន្ត

លោក តិក សាយ័ន្ត អាយុ៣០ឆ្នាំ សព្វថ្ងៃរស់នៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង។ លោកជាអ្នកវាយស្គរ និងច្រៀង។ ក្រៅពីច្រៀង និងវាយស្គរ គាត់ចេះលេងទ្រដែរ។ លោក តិក សាយ័ន្ត បានចូលមកលេងភ្លេងក្នុងក្រុមលោកគ្រូ សុខ កើត តាំងពីឆ្នាំ២០០៩។ ក្រៅពីការលេងភ្លេង គាត់ធ្វើស្រែដែរ។

លោក ស៊ាន ស៊ា

លោក ស៊ាន ស៊ា អាយុ៣០ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្នល់បាក់ ឃុំអំពិល ស្រុកប្រាសាទបាគង។ លោកជាអ្នកលេងតាខេប្រចាំក្រុម ហើយក៏អាចលេងរនាតបានដែរ។ លោក ស៊ាន ស៊ា បានចូលមកលេងភ្លេងក្នុងក្រុមលោកគ្រូ សុខ កើតនៅឆ្នាំ២០១៤។ ក្រៅពីលេងភ្លេង គាត់នៅមានរបរធ្វើស្រែបន្ថែមទៀតដែរ។

២.២. វង់ភ្លេងមេមត់ភូមិព្រះដាក់

ភូមិព្រះដាក់ស្ថិតក្នុងបារាយណ៍យសោធរតដាក (សព្វថ្ងៃហៅបារាយណ៍ខាងកើត) នៅចំខាងកើតប្រាសាទមេបុណ្យខាងកើត ក្នុងឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលជាបារាយណ៍កសាងក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ «យសោធរតដាក»។ ភូមិអ្នកស្រុកតាំងទីក្នុង និងនៅលើខ្នងទំនប់បារាយណ៍តែម្តង។ សព្វថ្ងៃអ្នកភូមិនៅតែមានជំនឿលើ «មេមត់» ដូចជាអ្នកភូមិដទៃទៀតក្នុងតំបន់អង្គរដែរ។ វង់ភ្លេងមេមត់នៅភូមិព្រះដាក់មានសមាជិកចំនួន៦នាក់(រូបលេខ៥) ដែលជាអ្នករស់នៅក្នុងភូមិនេះលើកលែងតែម្នាក់មកពីភូមិរហាល សង្កាត់អង្គរធំ ក្រុងសៀមរាប។ សមាជិកវង់ភ្លេងនេះ ខ្លះចេះពីឪពុក និងខ្លះទៀតចេះពីគ្រូ នៅក្នុងភូមិតាំងពីវ័យជំទង់។ វង់ភ្លេងនេះ មានលោកគ្រូ លន់ រិន ជាមេក្រុម និងជាអ្នកបង្ហាត់ភ្លេងដល់សមាជិកក្នុងក្រុមផង។ សមាជិកវង់ភ្លេងនេះពុំមែនលេងភ្លេងមេមត់តែមួយមុខទេ ពួកគាត់ជាអ្នកធ្វើស្រែ ខ្លះឡើងត្នោតធ្វើឧបករណ៍ភ្លេងលក់ ដួលរោងការ និងចិញ្ចឹមមាន់។ ឧបករណ៍ភ្លេងក្នុងវង់នេះមាន៖ ស្គរ ឃឹម ទ្រអ៊ូ ទ្រខ្សែបី និងតាខេ។

រូបលេខ២៥៖ វង់ភ្លេងភូមិព្រះដាក់

២.២.១. សមាជិកវង់ភ្លេងភូមិព្រះដាក់

លោក លន់ រិន

លោក លន់ រិន អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។ លោកជាមេក្រុម និងជាអ្នកកូតទ្រសោ ក្រៅពីនេះគាត់ក៏អាចលេងចាប៉ី និងម៉ុងដូលីនបានដែរ។ លោកបានរំឭកថា គាត់ចេះលេងភ្លេងតាំងពីអាយុ១៧ឆ្នាំ ដោយបានរៀនពីលោកគ្រូលន់ និងលោកគ្រូសឿននៅភូមិស្រះស្រង់។ គាត់មានរបររកស៊ីជួលរោងការលក់ចាប់ហួយ និងធ្វើស្រែ។

លោក ប្រម ទុយ

លោក ប្រម ទុយ អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។ សព្វថ្ងៃ លោកជាអ្នកកូតទ្រអ៊ូ និងស្គរ ក្រៅពីនេះ គាត់អាចផ្លុំខ្លុយ និងវាយស្គរ។ លោកបានរំឭកថា គាត់ចេះលេងភ្លេងតាំងពីអាយុ១៧ឆ្នាំ ដោយបានរៀនពីលោក គ្រូ អោក ដែលជាអ្នករស់នៅភូមិស្រះស្រង់។ ក្រៅពីលេងភ្លេងមេមត់ និងភ្លេងការ គាត់ធ្វើស្រែ។

លោក ហួន ពាក់

លោក ហួន ពាក់ អាយុ៤១ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។ សព្វថ្ងៃលោក ហួន ពាក់ ជាអ្នកវាយស្គរ និងជាអ្នកច្រៀងប្រចាំក្រុម។ គាត់ចេះលេងភ្លេងនៅអាយុ១៩ឆ្នាំ ដោយបានរៀនពី លោកគ្រូ លន់ វិន ដែលជាមេក្រុមភ្លេងនៅភូមិព្រះដាក់។ ក្រៅពីលេងភ្លេងមេមត់ និងភ្លេងការគាត់ធ្វើស្រែ។

លោក ចន ង៉ិក

លោក ចន ង៉ិក អាយុ៤៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។ លោក ចន ង៉ិក ជាអ្នកវាយស្គរ និងច្រៀងប្រចាំក្រុម ដូចលោកហួន ពាក់ ដែរ។ គាត់ពុំចេះលេងឧបករណ៍អ្វីផ្សេងទៀតទេ។ លោកចន ង៉ិក បានចាប់ផ្តើមលេងភ្លេងនៅអាយុ២៥ ដោយបានរៀនពីលោកគ្រូ លន់ វិន។ ក្រៅពីលេងភ្លេងមេមត់ និងភ្លេងការ គាត់ធ្វើស្រែ និងឡើងត្នោត។

លោក ផុង ពឿន

លោក ផុង ពឿន អាយុ៣៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។ សព្វថ្ងៃ លោកជាអ្នកកូតទ្រ និងលេងឃឹម។ ក្រៅពីនេះគាត់អាចវាយស្គរនិងវាយឈឹងបានដែរ។ លោកបានរំឭកថាគាត់បានរៀនភ្លេងពីឪពុកឈ្មោះពេជ្រ ផុង រស់នៅភូមិស្រះស្រង់។ របរបន្ថែមរបស់គាត់ក្រៅពីលេងភ្លេង គឺធ្វើឧបករណ៍ភ្លេងលក់។

លោក ឡម លួន

លោក ឡម លួន អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។ លោក ឡម លួន ជាអ្នកលេងឃឹម។ ក្រៅពីនេះ គាត់អាចលេងឧបករណ៍បានច្រើនទៀត ដូចជា៖ ទ្រ តាខេ ចាប៉ី។ល។ លោក ឡម លួន បានរំឭកថាគាត់បានរៀនភ្លេងពីលោកតាទុយ លោកគ្រូអោក និងលោកគ្រូលន់ នៅភូមិស្រះស្រង់ ក្រៅពីលេងភ្លេងគាត់ធ្វើស្រែ។

២.៣. វង់ភ្លេងមេមត់ភូមិក្វង់

ភូមិក្វង់ស្ថិតនៅខាងជើងប្រាសាទព្រះខ័ន ប្រហែល២ គ.ម. ក្នុងឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ វង់ភ្លេងនៅភូមិនេះមានសមាជិកចំនួន៩នាក់ ខ្លះមានទីលំនៅក្នុងភូមិ ខ្លះទៀតមកពីភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ឯមួយចំនួនទៀតមកពីភូមិកណ្តាល ឃុំស្វាយចេក និងភូមិដូនឪ ឃុំដូនកែវ ស្រុកពួក (រូបលេខ២៦)។ អ្នកភ្លេងក្នុងវង់នេះមួយចំនួនចេះតពីឪពុក ខ្លះចេះពីគ្រូ និងម្នាក់ទៀតរៀនពីក្រុមសិល្បៈក្នុងសម័យប៉ុល ពត។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ មានសមាជិកថ្មីៗចូលរួមលេងដែរ។ ពួកគាត់ខ្លះរៀនបានតែ៥ ទៅ៧ឆ្នាំតែប៉ុណ្ណោះ ពីលោកគ្រូ ម៉ាប់ ពឿន ដែលជាមេក្រុម និងជាអ្នកបង្រៀនសមាជិកក្រុមដែលទើបចូលថ្មីៗ វង់នេះ មានវត្តមានតាំងពីសម័យសង្គមរាស្រ្តនិយមមកម្ល៉េះ តែបានផ្អាកនៅសម័យប៉ុល ពត និងបានបង្កើតឡើងវិញនៅឆ្នាំ១៩៨០។ សមាជិកក្នុងក្រុមនេះមានខ្លះបានស្លាប់ដោយសារវ័យចំណាស់ និងខ្លះបានចេញទៅបង្កើតក្រុមថ្មី។ មុខរបរផ្សេងទៀតរបស់សមាជិកក្រុមភ្លេងនេះមានដូចជា៖ ធ្វើស្រែ ចម្ការ ត្បាញជាលជាងសំណង់ រកអនុផលព្រៃឈើតាមរដូវកាល លេងល្ខោនបាសាក់ លេងភ្លេងការ និងចិញ្ចឹមជ្រូក។ ឧបករណ៍ភ្លេងក្នុងវង់នេះមាន៖ ទ្រ ស្គរ តាខេ និងឃឹម។

រូបលេខ២៦៖ វង់ភ្លេងភូមិក្វង់

២.៣.១. សមាជិកវង់ភ្លេងភូមិភ្នង់

លោក ឆាន់ ម៉ាប់

លោក ឆាន់ ម៉ាប់អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិភ្នង់ ឃុំលាងដៃ ស្រុកអង្គរធំ។ លោកជាអ្នកកូតទ្រសោ និងច្រៀង។ ក្រៅពីនេះ គាត់អាចកូតទ្រអ៊ូ និងវាយស្គរថែមទៀត។ លោក ឆាន់ ម៉ាប់ បានរំឭកថា គាត់ចេះលេងភ្លេងតាំងពីក្មេង តែពុំចាំឆ្នាំទេ ដោយបានរៀនពីឪពុកជាអ្នកភ្លេងក្នុងសម័យសង្គមរាស្ត្រនិយម។ លោកបានបន្តទៀតថាវង់ភ្លេងនេះមានវត្តមានតាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ តែបានផ្អាកនៅសម័យប៉ុល ពត និងបានបង្កើតឡើងវិញនៅឆ្នាំ១៩៨០ ដោយឪពុករបស់គាត់។ ក្រោយមកគាត់បានធ្វើជាប្រធានក្រុមបន្តពីឪពុក និងជាគ្រូបង្ហាត់ភ្លេង។ នៅឆ្នាំ២០០៤ គាត់បានឱ្យកូនឈ្មោះ ម៉ាប់ ពឿន ធ្វើជាមេក្រុម។ ក្រៅពីលេងភ្លេងមេមត់ និងភ្លេងការ គាត់ជាអ្នកធ្វើស្រែ ធ្វើអំបោសដើមពួចលក់ និងដើរបេះគុយតាមរដូវកាលលក់។

លោក ម៉ាប់ ពឿន

លោក ម៉ាប់ ពឿន អាយុ៣៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិភ្នង់ ឃុំលាងដៃ ស្រុកអង្គរធំ។ លោកជាប្រធានក្រុមភ្លេង និងជាគ្រូបង្ហាត់ភ្លេងក្នុងក្រុម។ លោក ម៉ាប់ ពឿន ចេះលេងភ្លេងតាំងពីអាយុ៩ឆ្នាំ ដោយបានរៀនពីឪពុកឈ្មោះ ឆាន់ ម៉ាប់។ សព្វថ្ងៃគាត់ជាអ្នកកូតទ្រសោ និងជាអ្នកច្រៀងក្នុងក្រុម ហើយគាត់អាចលេងឃឹម វាយស្គរ និងឈឹង។ ក្រៅពីលេងភ្លេងមេមត់ លេងភ្លេងការ គាត់ក៏ជាអ្នកភ្លេងក្នុងក្រុមល្ខោនបាសាក់ពំពាង នៅឃុំនគរភាស ស្រុកអង្គរជុំ ហើយក៏ជាអ្នកធ្វើអំបោសដើមពួចលក់ដូចឪពុកដែរ។

លោក ឡឿន ពៃ

លោក ឡឿន ពៃ អាយុ៤៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិកណ្ដាល ឃុំស្វាយចេក ស្រុកពួក។ លោក ឡឿន ពៃ ជាអ្នកលេងឃឹមប្រចាំក្រុម ហើយគាត់ក៏អាចវាយស្គរបានដែរ។ លោក ឡឿន ពៃ ចេះលេងភ្លេងតាំងពីអាយុ១៥ឆ្នាំ ដោយបានរៀនពីឪពុក។ ក្រៅពីលេងភ្លេង គាត់ជាអ្នកត្បាញជាល និងធ្វើសំណាង។

លោក រែម សារ៉េត

លោក រែម សារ៉េត អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិល្អក់ ឃុំកណ្ដែក ស្រុកប្រាសាទបាគង។ លោក រែម សារ៉េត បានរំឭកថា គាត់បានចូលលេងភ្លេងក្នុងក្រុមសិល្បៈ សម័យ ប៉ុល ពត នៅខេត្តសៀមរាប កាលពីអាយុ១០ឆ្នាំ។ សព្វថ្ងៃគាត់ជាអ្នកកូតទ្រអ៊ូ ប្រចាំក្រុម ហើយគាត់ក៏អាចកូតទ្រសោ និងវាយស្គរបានដែរ។ ក្រៅពីលេងភ្លេងគាត់ជាអ្នកធ្វើចម្ការ។[៣]

លោក ម៉ាប់ ពល

លោក ម៉ាប់ ពល អាយុ៣២ឆ្នាំ សព្វថ្ងៃរស់នៅភូមិកណ្ដាល ឃុំស្វាយចេក ស្រុកពួក។ លោក ម៉ាប់ ពល ចេះលេងភ្លេងនៅអាយុ១៥ឆ្នាំ ដោយរៀនពីឪពុកឈ្មោះ ឆាន់ ម៉ាប់ និងលោកគ្រូ កុយ។ សព្វថ្ងៃគាត់ជាអ្នកលេងតាខេ ហើយគាត់ក៏អាចកូតទ្រសោ ទ្រអ៊ូ លេងឃឹម និងវាយស្គរបានទៀតផង។ ក្រៅពីលេងភ្លេង គាត់ក៏មានរបរជាជាងសំណង់ផងដែរ។

លោក សោម សន

លោក សោម សន អាយុ៣០ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិកណ្ដាល ឃុំស្វាយចេក ស្រុកពួក។ លោក សោម សន ចេះលេងភ្លេងនៅអាយុ២៥ឆ្នាំ ដោយរៀនពីលោកគ្រូ ម៉ាប់ ពឿន ដែលជាប្រធានក្រុមវង់ភ្លេង។ សព្វថ្ងៃគាត់ជាអ្នកវាយស្គរប្រចាំក្រុម ក្រៅពីលេងភ្លេង គាត់ក៏មានរបរជាជាងសំណង់ផងដែរ។

លោក ដែន ជន

លោក ដែន ជន អាយុ៣៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិដូនឪ ឃុំដូនកែវ ស្រុកពួក។ លោក ដែន ជន ចេះលេងភ្លេងនៅអាយុ៣០ឆ្នាំ ដោយរៀនពីលោកគ្រូ ម៉ាប់ ពឿន។ គាត់ជាអ្នកវាយស្គរប្រចាំក្រុម ហើយអាចលេង តាខេ និងឃឹមបានទៀតផង។ ក្រៅពីលេងភ្លេង គាត់ក៏មានរបរចញ្ចឹមជ្រូកលក់ផងដែរ។

---

៣ ចម្ការនៅទីនេះ សំដៅលើដីដែលមិនរាបស្មើស្អាត ព្រោះគេដាំស្រូវដោយគ្រាន់តែពោយគ្រាប់ចូលក្នុងរុនតូចៗ កើតឡើងពីការយកឈើច្រឹងមួយគូទៅបុកដី ហើយគ្មានការដកសំណាប់យកទៅស្ទូង ដូចស្រូវស្រែឡើយ (សូមមើល "អាហារនៅជនបទអង្គរ", ស្គន, បច្ចេកទេសដាំស្រូវ ដំបូងមុននឹងស្ទូង ,ទំព័រ ៧០។

លោក មឿយ មិត

លោក មឿយ មិត អាយុ៣៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្វង់ ឃុំលាងដៃ ស្រុកអង្គរធំ។ លោក មឿយ មិត ចេះលេងភ្លេងនៅអាយុ៣០ឆ្នាំ ដោយរៀនពីលោកគ្រូ ម៉ាប់ ពឿន។ គាត់ជាអ្នកវាយស្គរប្រចាំក្រុម ហើយពុំចេះលេងឧបករណ៍ផ្សេងទៀតទេ។ ក្រៅពីលេងភ្លេងមេមត់ និងភ្លេងការ គាត់ធ្វើស្រែ។

លោក ម៉ៃ មឿត

លោក ម៉ៃ មឿត អាយុ២២ឆ្នាំ សព្វថ្ងៃរស់នៅភូមិ ក្វង់ ឃុំលាងដៃ ស្រុកអង្គរធំ។ លោក ម៉ៃ មឿត ពិការភ្នែក ចេះលេងភ្លេងនៅអាយុ១៥ឆ្នាំ ដោយរៀនពីលោកគ្រូ ម៉ាប់ ពឿន។ គាត់បានរំឭកថា ដោយសារគាត់ជាអ្នកពិការភ្នែក មិនអាចទៅធ្វើការអ្វីបានច្រើន ដើម្បីចិញ្ចឹមជីវិត ទើបគាត់សម្រេចទៅរៀនភ្លេង។ សព្វថ្ងៃ លោក ម៉ៃ មឿត ជាអ្នកវាយស្គរប្រចាំក្រុម ហើយគាត់ចេះលេងឧបករណ៍ផ្សេងទៀតដូចជា គង រនាត និងផ្លុំខ្លុយ។ ក្រៅពីរបរលេងភ្លេង គាត់ធ្វើស្រែ។

២.៤. វង់ភ្លេងមេមត់ភូមិទ្រៀក

ភូមិទ្រៀកស្ថិតនៅខាងជើងប្រាសាទវត្តអធ្វារ ក្នុងសង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប។ ភូមិទ្រៀកក៏មានវង់ភ្លេងមេមត់មួយក្រុមដែរ និងមានសមាជិកចំនួន១០នាក់ ខ្លះរស់នៅក្នុងភូមិ ខ្លះមកពីភូមិខ្នាស់ ឃុំខ្នាស់ ស្រុកសូទ្រនិគម និងខ្លះទៀតមកពីភូមិបឹងជុំ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង រីឯខ្លះទៀតមកពីភូមិឃុនមោឃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ហើយមួយចំនួនទៀតមកពីភូមិស្ពានជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប។ វង់ភ្លេងនេះ មានលោក ជុំ សំណាង ជាមេក្រុម (រូបលេខ៧)។ មិនខុសពីអ្នកភ្លេងនៅភូមិទាំង៣ខាងលើទេ ពួកគាត់មួយចំនួនចេះលេងភ្លេងពីឪពុក ខ្លះចេះពីគ្រូដែលជាមេក្រុម លើកលែងតែលោក ណូន សុខ ជាជនពិការភ្នែក បានរៀនភ្លេងពីគ្រូសិល្បៈនៅអង្គការគ្រួសារថ្មី។ ក្រុមភ្លេងនេះជាក្រុមថ្មី ទើបតែលេងជុំគ្នាក្នុងពិធីលៀងមេមត់នៅភូមិទ្រៀកបានមួយលើកទៅពីរលើកតែប៉ុណ្ណោះ ព្រោះសមាជិកក្រុមចាស់បានបែកទៅប្រកបរបរផ្សេងទៀតរៀងៗខ្លួន។ ម៉្លោះហើយ លោក ជុំ សំណាង បានខ្ចីដៃអ្នកភ្លេងនៅភូមិផ្សេងៗដែលស្គាល់គ្នាមកជួយលេងពេលឡើងអ្នកតា និងលៀងមេមត់ក្នុងភូមិកន្លងមក។ ដូច្នេះហើយទើបសមាជិកថ្មីខ្លះរស់នៅភូមិឆ្ងាយៗ ដូចជាមកពីភូមិខ្នាស់ ភូមិបឹងជុំ ភូមិកណ្ដែក និងភូមិជ្រាវជាដើម។ សមាជិកក្នុងក្រុមនេះ ក្រៅពីធ្វើស្រែ គឺមានរបរបន្ទាប់បន្សំផ្សេងទៀតដូចជាធ្វើគ្រូខ្មែរ លេងល្ខោន និងធ្វើជាគ្រូភ្លេង។ ឧបករណ៍ភ្លេងក្នុងវង់នេះមាន៖ ទ្រ ស្គរ តាខេ ឃឹម។

រូបលេខ៧៖ វង់ភ្លេងភូមិទ្រៀក

២.៤.១. សមាជិកវង់ភ្លេងភូមិទ្រៀក

លោក ជុំ សំណាង

លោក ជុំ សំណាង អាយុ៤២ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិទ្រៀក សង្កាត់សៀមរាប ក្រុងសៀមរាប។ លោក ជុំ សំណាង ចេះលេងភ្លេងតាំងពីវ័យក្មេង (ពុំចាំឆ្នាំ) ដោយរៀនពីឪពុក។ សព្វថ្ងៃ លោកជាមេក្រុម ជាគ្រូបង្ហាត់ភ្លេងដល់មនុស្សក្នុងក្រុម ជាអ្នកវាយស្គរ និងច្រៀងប្រចាំក្រុម ក្រៅពីនេះ គាត់ចេះដេញចាប៉ីដងវែង។ សព្វថ្ងៃក្រៅពីរបរលេងភ្លេង គាត់ធ្វើស្រែ។

លោក គា ធួក

លោក គា ធួក អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅភូមិទ្រៀក សង្កាត់សៀមរាប ក្រុងសៀមរាប។ លោក បានរំឭកថា គាត់ចេះលេងភ្លេងតាំងពីអាយុ១០ឆ្នាំ ដោយរៀនពីឪពុករបស់លោក ជុំ សំណាង ដែលជាប្រធានក្រុមវង់ភ្លេងសព្វថ្ងៃ។ សព្វថ្ងៃ លោក គា ធួក ជាអ្នកវាយស្គរ និងច្រៀងប្រចាំក្រុម។ លោកពុំចេះលេងឧបករណ៍អ្វីផ្សេងទៀតទេ ក្រៅពីរបរលេងភ្លេង គាត់ធ្វើស្រែ។

លោក រឹម ប៉ែន

លោក រឹម ប៉ែន អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិទ្រៀក សង្កាត់សៀមរាប ក្រុងសៀមរាប។ លោកចេះលេងភ្លេងនៅអាយុ២៥ឆ្នាំ ដោយរៀនពីលោកគ្រូ គឿក។ សព្វថ្ងៃ លោកជាអ្នកវាយស្គរក្នុងក្រុម ក្រៅពីវាយស្គរលោកចេះលេងឧបករណ៍ផ្សេងទៀតដូចជា ឃឹម ទ្រ និងតាខេ ហើយក្រៅពីរបរលេងភ្លេង គាត់ធ្វើស្រែ។

លោក ផម សារ៉ាត់

លោក ផម សារ៉ាត់ អាយុ២៩ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិខ្នាស់ ឃុំខ្នាស់ ស្រុកសូទ្រនិគម។ លោក ផម សារ៉ាត់ចេះលេងភ្លេងនៅអាយុ១៩ឆ្នាំ ដោយបានរៀនពីលោកគ្រូ អឿន។ សព្វថ្ងៃ គាត់ជាអ្នកវាយឃឹមប្រចាំក្រុម ក្រៅពីឃឹមគាត់ពុំចេះលេងឧបករណ៍អ្វីផ្សេងទៀតទេ។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែដូចសមាជិកក្នុងក្រុមមួយចំនួនទៀតដែរ។

លោក ធុន ញៀប

លោក ធុន ញៀប អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិបឹងជុំ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង។ លោក ធុន ញៀប ចេះលេងភ្លេងតាំងពីអាយុ៧ឆ្នាំ ដោយរៀនពីឪពុក និងលោកគ្រូ មៀន។ សព្វថ្ងៃ លោក ធុន ញៀប ជាអ្នកកូតទ្រសោ ក្រៅពីទ្រសោគាត់ចេះវាយឃឹម ដេញតាខេ និងផ្លុំប៉ីអ។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ និងជាគ្រូឱសថបុរាណ។

លោក សេង ស៊ាប

លោក សេង ស៊ាប អាយុ២៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិឃុនមោឃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង។ លោក សេង ស៊ាប ចេះលេងភ្លេងតាំងពីអាយុ១៣ឆ្នាំ ដោយរៀនពីឪពុកឈ្មោះ សួន។ សព្វថ្ងៃគាត់ជាអ្នកផ្លុំប៉ីអ និងជាអ្នកច្រៀង។ ក្រៅពីនេះ គាត់ចេះលេងឧបករណ៍ផ្សេងទៀតដូចជា ឃឹម តាខេ និងទ្រទៀតផង។ ក្រៅពីរបរលេងភ្លេងគាត់ក៏ជាតួសម្ដែងល្ខោនបាសាក់ក្នុងក្រុមអារញ្ញសង្ឃបារមីជំទាវខ្មៅនៅវត្តអារញ្ញ ហៅវត្តពោធិក្រោម។

លោក លេង ខៃ

លោក លេង ខៃ អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិខ្វាស់ ឃុំខ្វាស់ ស្រុកសូទ្រនិគម។ លោក លេង ខៃ ចេះលេងភ្លេងនៅឆ្នាំ២០១៥ ដោយរៀនពីលោក ធុន ញៀប។ សព្វថ្ងៃគាត់ជាអ្នកកូតទ្រអ៊ូក្នុងក្រុម ហើយគាត់ក៏អាចដេញតាខេបានដែរ។ ក្រៅពីលេងភ្លេងគាត់ធ្វើស្រែ។

លោក ណូន សុខ

លោក ណូន សុខ អាយុ៣៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្ពានជ្រាវ សង្កាត់សៀមរាប ក្រុងសៀមរាប គាត់ពិការភ្នែក ហើយចេះលេងភ្លេងតាំងពីអាយុ១៤ឆ្នាំ។ គាត់បានរំឭកថា ដោយគាត់ជាអ្នកពិការភ្នែក ដូច្នេះគាត់បានសម្រេចចិត្តទៅរៀនភ្លេងជាមួយអង្គការគ្រួសារថ្មីដើម្បីធ្វើជារបរចិញ្ចឹមជីវិតទៅថ្ងៃមុខ។ នៅក្នុងក្រុមភ្លេងនេះ លោកណូន សុខ ជាអ្នកដេញចាប៉ីដងវែង ផ្លុំប៉ីអ និងផ្លុំស្រឡៃ។ ក្រៅពីលេងឧបករណ៍ទាំងបីមុខនេះ គាត់ចេះលេងឧបករណ៍ផ្សេងៗជាច្រើនទៀត ដូចជាៈ ទ្រសោ ទ្រអ៊ូ ឃឹម រនាតឯក រនាតធុង គងវង់តូច គងវង់ធំ សម្ភោរ ស្គរធំ ស្រឡៃ កែន ខ្លុយ ស្នែង ផ្លុយ អង្គួច ព្រមទាំងចេះស្មូត ច្រៀងអាយៃ មហោរី យីកេ និងភ្លេងការ។ ដោយសារលោកណូន សុខ ចេះលេងឧបករណ៍ច្រើនប្រភេទ សព្វថ្ងៃគាត់បានបើកបង្រៀនភ្លេងនៅផ្ទះ។

លោក ជុំ ស័យ

លោក ជុំ ស័យ អាយុ៣៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិទ្រៀក សង្កាត់សៀមរាប ក្រុងសៀមរាប។ លោក ជុំ ស័យ ចេះលេងភ្លេងតាំងពីក្មេង (ពុំចាំឆ្នាំ) ដោយរៀនពីឪពុក។ សព្វថ្ងៃ គាត់ជាអ្នកវាយស្គរ ហើយក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

លោក ផម រ៉ុម

លោក ផម រ៉ុម អាយុ២៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិទ្រៀក សង្កាត់សៀមរាប ក្រុងសៀមរាប។ លោក ផម រ៉ុម ចេះលេងភ្លេងតាំងពីក្មេង (ពុំចាំឆ្នាំ) ដោយរៀនពីលោកគ្រូ ជុំ សំណាង។ សព្វថ្ងៃគាត់ជាអ្នកវាយស្គរ និងវាយឈឹង ហើយក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

២.៥. វង់ភ្លេងភូមិត្នោតជ្រុំ

ភូមិត្នោតជ្រុំស្ថិតនៅខាងជើងបារាយណ៍ទឹកថ្លា (បារាយណ៍ខាងលិច) ចម្ងាយប្រហែល៥គ.ម. ស្ថិតក្នុងឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។ វង់ភ្លេងមេមត់នៅភូមិត្នោតជ្រុំមានសមាជិកចំនួន៥នាក់ ដែលមានទីលំនៅក្នុងភូមិជាមួយគ្នាទាំងអស់ ពុំមានមកពីភូមិផ្សេងដូចវង់ភ្លេងនៅតាមភូមិមួយចំនួនដូចបានបញ្ជាក់ពីខាងលើទេ។ អ្នកភ្លេងក្នុងក្រុមនេះ មួយចំនួនចេះលេងពីគ្រូ ឈិន ហ៊ាន និងពីមេក្រុមឈ្មោះ ស៊ិន ស៊ាំង។ អ្នកភ្លេងក្រុមនេះច្រើនមានវ័យចំណាស់ ហើយបទដែលលេងជាបទធ្លាប់លេងតាំងពីដើមរៀងមក។ ក្រៅពីលេងភ្លេង សមាជិកក្រុមនេះមានរបរធ្វើស្រែ និងប្រកបរបរផ្សេងៗមួយចំនួនទៀត ដើម្បីរកកម្រៃបន្ថែម។ ឧបករណ៍ភ្លេងក្នុងវង់នេះមាន៖ ទ្រសោ ស្គរ ឃឹម និងប៉ីអ (រូបលេខ២៨)។

រូបលេខ២៨៖ វង់ភ្លេងភូមិត្នោតជ្រុំ

២.៥.១. សមាជិកាវង់ភ្លេងភូមិត្នោតជ្រុំ

លោក សិន សុាំង

លោក សិន សុាំង អាយុ៦១ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក។ លោក សិន សុាំង ចេះលេងភ្លេងនៅឆ្នាំ១៩៨០ ដោយរៀនពីលោកគ្រូ ឈឹន ហ៊ាន។ សព្វថ្ងៃ គាត់ជាមេក្រុម ជាអ្នកវាយស្គរ និងច្រៀងប្រចាំក្រុម។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

លោក សិន សែត



លោក សិន សែត អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅ ភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក។ លោក សិន សែត ចេះលេងភ្លេងនៅឆ្នាំ១៩៨០ ដោយរៀនពីលោកគ្រូ ឈឹន ហ៊ាន។ សព្វថ្ងៃ គាត់ជាអ្នកកូតទ្រសោ។ ក្រៅពីចេះលេងឧបករណ៍ទ្រ គាត់ចេះវាយស្គរ និងចេះច្រៀងផង។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

លោក ស៊ុត វិច

លោក ស៊ុត វិច អាយុ៤៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក។ លោក ស៊ុត វិច ចេះវាយស្គរនៅឆ្នាំ២០១៥ ដោយរៀនពីលោកគ្រូ សិន សុាំង។ សព្វថ្ងៃ គាត់ជាអ្នកផ្លុំប៉ីអ។ ក្រៅពីនេះ គាត់ចេះកូតទ្រ និងវាយស្គរ។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

លោក ហ៊ាន ហឿម

លោក ហ៊ាន ហឿម អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក។ លោក ហ៊ាន ហឿម ចេះលេងភ្លេងនៅឆ្នាំ១៩៨០ ដោយរៀនពីលោកគ្រូ ឈឹន ហ៊ាន និងរៀនបន្ថែមពីអ្នកក្នុងក្រុម។ សព្វថ្ងៃជាអ្នកលេង ឃឹម ហើយចេះវាយស្គរផង។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

លោក ណាន ធៀន

លោក ណាន ធៀន អាយុ៤៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក។ លោក ណាន ធៀន ចេះលេងភ្លេងនៅឆ្នាំ២០១៥ ដោយរៀនពីលោកគ្រូ សិន សុាំង។ សព្វថ្ងៃ គាត់ជាអ្នកវាយស្គរ និងច្រៀង ហើយគាត់ពុំចេះលេងឧបករណ៍ផ្សេងទៀតទេ។ ក្រៅពីរបរលេងភ្លេងគាត់ធ្វើស្រែ។

៣. គ្រឿងរណ្តាប់ និងតំណម

ជាធម្មតា អ្នករករង់ភ្លេងឱ្យលេងក្នុងពិធីលៀងមេមត់ ឬអារក្សម្តង ត្រូវជូនជមគ្រូ ឬជមព្រះពិស្ណុការ ទៅគ្រូភ្លេងប្រចាំក្រុមនីមួយៗដោយខានពុំបាន។ ជមគ្រូជាគ្រឿងរណ្តាប់ដែលរៀបក្នុងថាសមូលមួយមាន៖ អង្ករជ័យ ជម៤ ស្វាធម៌ មាន់ស្ងោរ ទៀន ធូប ចេក ម្លូរ ស្លា បារី ស្រាស ទឹកក្រូច និងទឹកជា។ ជមនេះត្រូវដាក់នៅលើកញ្ជើអង្ករចំកណ្តាលក្រុមភ្លេង។ ជាទូទៅយើងសង្កេតឃើញថា គ្រឿងរណ្តាប់ដែលរៀបសម្រាប់វង់ភ្លេងនីមួយៗមិនមានអ្វីខុសគ្នាទេ (រូបលេខ៩)។

រូបលេខ៩៖ ជមគ្រូភ្លេងនៅភូមិត្នោតជ្រុំ

មុនលេង អ្នកភ្លេងទាំងអស់ត្រូវមកអង្គុយជុំវិញជមគ្រូ[៨] ហើយអុជទៀនធូប ដើម្បីប្រាស្រ័យជាមួយគ្រូ។ នៅភូមិថ្នល់បាក់ ក្រៅពីអុជទៀនលើជមគ្រូភ្លេងហើយ មេក្រុមត្រូវអុជទៀនមួយដើមលើស្គរផង។[៩] ពេលសំពះគ្រូ មានតំណាមមិនឱ្យបែរក្រោយ (តំណាមនេះ តែងធ្វើតាមទម្លាប់តពីគ្រូមកសិស្ស) មើលទៅប្រហែលជាឱ្យអ្នកភ្លេងផ្តង់អារម្មណ៍ក្នុងពេលលេង (?)។ បន្ទាប់មកអ្នកភ្លេងចាប់ផ្តើមលេងបទ «ប្រគំគ្រូ» ជាបទប្រចាំវង់ភ្លេងនីមួយៗសិន ទើបប្រគំបទផ្សេងៗទៀតរហូតដល់ចប់កម្មវិធី (រូបលេខ១០)។ តំណាមមួយទៀត ពុំអនុញ្ញាតឱ្យអ្នកណាម្នាក់ប៉ះពាល់ជមគ្រូនោះឡើយក្នុងកំឡុងពេលលេង, យកចំណីចំណុកពីជមមកហូប ជាពិសេសនៅពេលអ្នករកវង់ភ្លេងមិនទាន់បានជូនជមទៅគ្រូភ្លេង រឹតតែមិនអាចលូកលាន់បានឡើយ។ ដោយឡែកមុនដល់ដំណាក់កាលលេងភ្លេងក្នុងពិធីលៀងមេមត់ គឺអ្នករកវង់ភ្លេងត្រូវទៅអញ្ជើញគ្រូភ្លេង ឬជួនកាលហៅថា «និមន្តគ្រូ»មកលេងក្នុងពិធីលៀងនោះ ត្រូវមានទ្រនឹប ដែលក្នុងនោះមាន៖ ទៀន ធូប ម្លូរ ស្លា ជូនទៅគ្រូភ្លេងហាក់ដូចជាការបញ្ចាំពីថ្ងៃ និងពេលវេលាដែលត្រូវមកលេង នេះប្រហែលជាត្រូវនឹងពាក្យថា«កក់»។ ប្រសិនបើពុំធ្វើដូច្នេះទេ ហាក់ដូចជា ការអញ្ជើញនោះពុំទាន់ពេញលេញនៅឡើយ។ ចំពោះឧបករណ៍ភ្លេង ក៏ពុំអាចឱ្យអ្នកណាម្នាក់ដើរកន្លង ទោះក្នុងពេលកំពុងលេង ឬទុកនៅផ្ទះក៏ដោយ។ ម្ល៉ោះហើយឧបករណ៍ភ្លេងពេលឈប់លេងគេតែងដាក់ព្យួរ ឬដាក់ឱ្យខ្ពស់ផុតពីដៃក្មេង (រូបលេខ១១)។

រូបលេខ១០៖ កិច្ចសំពះគ្រូភ្លេង មុនប្រគំនៅភូមិថ្នល់បាក់

រូបលេខ១១៖ ទ្រព្យូរនឹងក្តារហ៊ឹងគ្រូកំណើត នៅភូមិព្រះដាក់

ម្តងម្កាលនៅថ្ងៃសីល អ្នកភ្លេងតែងអុជធូបនៅក្តារហ៊ឹងគ្រូកំណើតដែលដាក់ឧបករណ៍ភ្លេង។ មានករណីខ្លះទៀត គ្រូភ្លេងក៏អាចធ្វើឱ្យអ្នកភ្លេងឈឺបានដែរ។ មានពេលមួយ អ្នកភ្លេងម្នាក់ធ្លាក់ខ្លួនឈឺខ្លាំង ម្តាយក៏ទៅពឹងពាក់គ្រូរកមើលហេតុនៃជម្ងឺឃើញថា ឈឺមកពីមិនបានរៀបចំសែនរំឭកគ្រូ។ ដោយឡែកគ្រូភ្លេងម្នាក់ទៀត ដើម្បីជៀសវាងវិបត្តិតូច ធំអាចកើតលើខ្លួនគាត់ នៅថ្ងៃដែលក្រុមយើងខ្ញុំបានទៅអាត់សម្លេងចម្រៀង

[៨] ជាទូទៅពាក្យថាគ្រូចំពោះអ្នកភ្លេង គឺព្រះពិស្ណុការនេះឯង។
[៩] ភ្លឺ-ពន្លឺជាជំនឿជាទូទៅទាក់ទងនឹងទេព (អាំង ជូលាន, https://www.yosothor.org/publications/khmerrenaissance/chapter-one/tean. html)។ ពន្លឺក៏មានទាក់ទងនឹងជីវិត ដូចពេលអភិសេកព្រះពុទ្ធរូប កិច្ចមុនគេគឺ «បើកព្រះនេត្រ» ដើម្បីឱ្យបដិមានោះចាប់មានជីវិតឡើង។

មេមត់នៅផ្ទះគាត់ៗបានរៀបចំជមពីរនៅអសនៈលើផ្ទះ មួយសម្រាប់ក្រុមភ្លេង និងមួយទៀតសម្រាប់គ្រូគាត់ ដើម្បីជាការជូនដំណឹងទៅគ្រូពីមនុស្សប្លែកមុខមកចូលផ្ទះ និងពីការលេងភ្លេងមេមត់នៅក្នុងផ្ទះគាត់ (រូបលេខ១២)។ ជួនកាលពុំចាំបាច់មានជមក៏បាន ដោយគ្រាន់តែអុជធូបប្រាប់គ្រូដោយខានពុំបាន។

រូបលេខ១២៖ កន្លែងដាក់ឧបករណ៍ភ្លេងរបស់អ្នកភ្លេងនៅភូមិទ្រៀក

ដោយឡែក នៅភូមិថ្នល់បាក់ គឺជាករណីពិសេសដែលគ្រូភ្លេងមេមត់ ឬអារក្ស មិនអាចបង្រៀនភ្លេងសិស្សនៅផ្ទះបានឡើយ ត្បិតជឿថាជួរ ឬគ្រូកំណើតនឹងធ្វើឱ្យក្មេងឈឺពុំខាន។ ម្ល៉ោះហើយ ដើម្បីហាត់រៀនលេងភ្លេងមេមត់បាន មានតែរង់ចាំដល់ពេលមានពិធីលៀងមេមត់ប៉ុណ្ណោះ ទើបអាចហាត់រៀនបាន។ ត្រង់ចំណុចនេះ សូមបញ្ជាក់ម្តងទៀតថា មេមត់ទាក់ទងនឹងជម្ងឺ។ តាមទម្លាប់រៀងមក គេលៀងនៅខែមាឃជាសហគមន៍ក្នុងភូមិនីមួយៗ តែក៏អាចលេងក្នុងខែផ្សេងបានក្នុងករណីរូបមេមត់ឈឺធ្ងន់ ហើយត្រូវលៀងដើម្បីបានជាសះស្បើយវិញ។ ក្នុងពេលយើងអាត់សំឡេងចម្រៀងមេមត់នៅផ្ទះគ្រូភ្លេងមានមនុស្សមកសួរនាំពីមូលហេតុលេងភ្លេងមេមត់នាពេលនោះ ត្បិតដូចបានពោលពីខាងលើពុំមែនលេងតាមការនឹកឃើញពេលណាក៏បាននោះទេ ដូចករណីរៀនភ្លេងគងស្គរ ឬទុបមុយដែរ។[៦]

៦ ភ្លេងគងស្គរ ឬទុបមុយ ដែលជាភ្លេងលេងក្នុងពិធីបុណ្យសព ឬចម្រើនអាយុ។ បទនេះអាចរៀនលេងបានតែនៅក្នុងវត្ត (សូមអានបន្ថែម អាំង ជូលាន ២០០៨-២០០៩)។

៤. បទចម្រៀងក្នុងកិច្ចលៀងមេមត់

ជាទូទៅបទចម្រៀងលេងពីដំណាក់កាលចាប់ផ្ដើមរហូតដល់ចប់ក្នុងកិច្ចពិធីលៀងមេមត់ ឬអារក្ស ដោយខានពុំបានមាន៖ បទប្រគំគ្រូ បទមេមត់រាំ បទដេញព្រាយ និងបទកាច់ផ្កាសាពិតាន។ បទប្រគំគ្រូ ជាបទត្រូវលេងមុនបង្អស់។ ក្រុមនីមួយៗមានបទប្រគំគ្រូដោយឡែកៗពីគ្នា។ បទថ្វាយគ្រូ ឬប្រគំគ្រូច្រើនតែជាចង្វាក់រង្វើលមួយៗមិនញាប់ឡើយ ទោះបទនោះត្រូវលេងញាប់បានក៏ដោយ។[៧] ចំណែកបទដេញព្រាយ និងបទកាច់ផ្កាសាពិតាន គឺជាបទត្រូវលេងក្នុងកិច្ចបញ្ចប់ពិធី។ ខាងក្រោមនេះជាបទចម្រៀងប្រគំគ្រូរបស់ក្រុមភ្លេងនៅភូមិទាំង៥៖

ភូមិ	បទប្រគំគ្រូ	បទផ្សេងៗដែលអាចលេងប្រគំគ្រូបាន
ថ្នល់បាក់	ភ្នាំង	ម្ចប់ដូង ភ្នំស្រួច ព្រៃកើត
ព្រះដាក់	ស្រីស្ទើរ	គ្រាំង
ភ្នង់	ភ្នាវ៉ាំ	ល្ងិន
ទ្រៀក	ជ្រោង	បញ្ចុះ ឬកុម៉ារេវ
ត្នោតជ្រុំ	យល់នាង	X

បើពិចារណាលើខ្លឹមសារទំនុកច្រៀងបទប្រគំគ្រូនៃវង់ភ្លេងទាំង៥ខាងលើសុទ្ធតែជាបទអញ្ជើញគ្រូមកចូលរួម។ ទំនុកច្រៀងទាំងនោះជារឿយៗមានពាក្យអញ្ជើញ «គ្រូតូច គ្រូធំ គ្រូជិត គ្រូឆ្ងាយ គ្រូចាស់ គ្រូក្មេង គ្រូថ្មី» និង«ស្រីខ្មៅ»[៨] ដោយឡែកបទប្រគំគ្រូ វង់ភ្លេងនៅភូមិត្នោតជ្រុំមានពាក្យ «ព្រះពិស្ណុការ» ដែលជាទេព ឬគ្រូផ្នែកជាង និងទម្រង់សិល្បៈ។ មុនពេលលេងបទប្រគំគ្រូ មេក្រុមវង់ភ្លេងត្រូវអុជធូបបួងសួងមុខជមភ្លេងដែលរៀបលើថាសដាក់លើកញ្ជើអង្ករជាមុនសិន។ ក្រៅពីបទប្រគំគ្រូ នៅមានបទមួយចំនួនទៀតដូចមានបង្ហាញក្នុងតារាងខាងលើក៏អាចលេងប្រគំគ្រូបានដែរ។ បន្ទាប់ពីប្រគំគ្រូរួចហើយ អ្នកភ្លេងអាចលេងបទផ្សេងៗឱ្យមេមត់រាំជាធម្មតា ជួនកាលត្រូវលេងបទប្រចាំដួរតាមការបង្គាប់ពីមេមត់។ ដោយឡែក បទប្រគំគ្រូមានក្នុងតារាងខាងលើក៏អាចលេងឱ្យមេមត់រាំបានដែរ គ្រាន់តែលេងឱ្យរន្ថើនជាងពេលលេងប្រគំគ្រូ។ ចំណែកបទដេញព្រាយ អ្នកភ្លេងត្រូវលេងឱ្យរន្ថើន ឬឱ្យមានសន្ទុះខ្លាំង ដើម្បីឱ្យមេមត់ម្នាក់ឡើងរាំវាយច្រូង ឬច្រមជើង៣ដែលធ្វើពីធាងចេក។[៩] ដោយឡែកក្នុងកិច្ចបញ្ចប់ពិធីត្រូវលេងបទកាច់ផ្កាសាពិតាន ដោយមានអ្នកភ្លេង

[៧] បទភ្លេងថតនៅភូមិទ្រៀកមានផ្ទុំស្នែងដែលជាករណីដោយឡែក (សូមអានចំណុចវង់ភ្លេងភូមិទ្រៀក)។
[៨] ជួនហៅផងរថា ជំទាវស្រីខ្មៅ។ អំពីជំនឿលើយាយម៉ៅនៅតំបន់សមុទ្រសូមអាន ហ៊ួន សាវង ២០២០។
[៩] នៅភូមិខ្លះគេហៅ «កិច្ចឱ្យបាយព្រាយ» គឺគេឱ្យស៊ីចុកចំណីចំណុកហើយក៏ដេញទៅឱ្យឆ្ងាយ ព្រោះគេខ្លាចព្រាយមកបន្ទំនៅជាមួយរូបស្នង។ កិច្ចស្រដៀងគ្នានេះក៏មានធ្វើនៅពេលសុំទឹកភ្លៀងដែរ ដែលទាក់ទងនឹងការបណ្ដេញ ឬបញ្ជូនឱ្យចេញឆ្ងាយ (សាម ច័ន្ទរីរៈ ២០០៩-១០)។ សម្រាប់ឧទាហរណ៍មួយបែបទៀត សូមអាន អ៊ូ គង្កា តូច សុភៈ សោ ចន្ទា ឆាន់ សុភីនី ២០២០។ នៅភូមិទ្រៀកមិនមានកិច្ចនេះទេ តែមានកិច្ចបញ្ជូនអមនុស្សចេញឱ្យឆ្ងាយនៅពេលបញ្ចប់ ដោយគេលេងបទបញ្ចុះ។

ម្នាក់ ឬពីរនាក់ឡើងរាំជាមួយមេមត់ ដើម្បីសាពិតានជាកិច្ចបញ្ចប់នៃពិធីលៀងមេមត់ ឬអារក្ស។

ភូមិ	បទដេញព្រាយ	បទសាពិតាន
ថ្នល់បាក់	ឡាំអ៊ីក	កាច់ផ្កា
ព្រះដាក់	ផ្កា	ផ្កា
ភូង	មេមត់ចូលហើយ	ស្រឡាញ់ស្រីខ្មៅ
ទ្រៀក	X	បញ្ចុះ
ត្នោតជ្រុំ	ផ្កា	កាច់ផ្កា

ការបែងចែកបទចម្រៀងណាលេងក្នុងកិច្ចណាមួយ ដូចបានបង្ហាញខាងលើ គឺបញ្ជាក់ពីបទចម្រៀងដែលត្រូវលេងតាមកិច្ចសំខាន់ៗក្នុងពិធី ជាក់ស្តែងបទទាំងអស់សុទ្ធតែលេងសាទៅមកជាច្រើនដងណាស់ ដើម្បីរូបមេមត់ចូលបានគ្រប់គ្នា។ ក្នុងករណីរូបមេមត់ច្រើន អ្នកភ្លេងត្រូវលេងរហូតទល់ភ្លឺផងក៏មាន។ ម្ល៉ោះហើយ ការលេងភ្លេងសាចុះឡើងជារឿងធម្មតា។ ចំណែកភ្លេងអាចលឿន ឬយឺត អាស្រ័យតាមរូបមេមត់បង្គាប់ដែរ។ ក្នុងករណីរូបមេមត់បោះសញ្ញាឱ្យលេងញាប់ អ្នកលេងភ្លេងក៏ប្រឹងលេងឱ្យសាច់ភ្លេងញាប់ទៅតាមនោះដែរ។ រូបមេមត់តែងមានបទប្រចាំខ្លួនតពីរូបមួយទៅរូបមួយ។[១០] សព្វថ្ងៃក្រៅពីទំនុកច្រៀងសម្រាប់លេងក្នុងពិធីលៀងមេមត់ ឬអារក្ស ក៏មានយកបទសម័យមកលេងក្នុងពិធីនេះដែរ ដូចជាបទ «សុំទឹកមួយផ្តិល» ដែលជាការពេញនិយមខ្លាំងនាពេលថ្មីៗនេះ។

ដោយឡែក ក្រៅពីលេងក្នុងពិធីលៀងមេមត់ ឬអារក្ស មានបទភ្លេងខ្លះអាចលេងពេលឡើងអ្នកតា និងក្នុងមង្គលការបានដែរ។ ក្នុងករណីយកបទទាំងនោះទៅលេងឡើងអ្នកតា ហៅថាបទ «អន្ទងហៅ ឬអញ្ជើញ»។ បើសិនលេងក្នុងពិធីមង្គលការ ហៅថា «ភ្លេងគ្រឹម» តែត្រូវលេងរង្វើលៗបែបបំពេរវិញ។

៤. ការបែងចែកវង់ភ្លេងបុរាណ និងវង់ភ្លេងសម័យ

ជាទូទៅអ្នកភ្លេងភូមិទាំង៥ខាងលើកត់សម្គាល់ថា វង់ភ្លេងមេមត់ ឬអារក្សណាជាវង់ភ្លេងបុរាណ និងវង់ភ្លេងសម័យ គឺអាស្រ័យលើឧបករណ៍ភ្លេងក្នុងវង់នីមួយៗ។ ឧទាហរណ៍វង់ភ្លេងមេមត់បុរាណ មានស្គរដៃ ចាប៉ីដងវែង ទ្រអ៊ូ ប៉ីអ និងក្រាប។ ឯវង់ភ្លេងសម័យមាន ឃឹម តាខេ ជំនួសចាប៉ីដងវែង ហើយប្រើធីងជំនួសក្រាប។ ការប្រើឧបករណ៍ភ្លេងខុសពីមុនក្នុងវង់ភ្លេងមេមត់ ឬអារក្ស គឺមាននៅក្រោយឆ្នាំ១៩៧៩។ វង់ភ្លេងនៅភូមិខាងលើខ្លះនៅប្រើចាប៉ីដងវែងនៅឡើយ។ ម្ល៉ោះហើយនេះមិនមែនមកពីចំណេះលេងចាប៉ីដងវែង

[១០] នៅខាងស្រុកអង្គរជុំ ខេត្តកំពត មេមត់ក៏មានបទប្រចាំខ្លួនដូច្នេះដែរ (វ៉ា បុប្ផារី et al.២០១៧ : ២០)។

បាត់បង់នោះទេ តែអាចទាក់ទងជាមួយអាជីពជាអ្នកលេងភ្លេងការ[១១] ព្រោះវង់ភ្លេងទាំង៥ខាងលើ សុទ្ធតែមានអាជីពជាអ្នកភ្លេងការ។ ភ្លេងការនៅទីនេះសំដៅលើប្រភេទចម្រៀងដែលគេចំណាំតែលេងតាមទីក្រុង ឬប្រជុំជននាពេលសព្វថ្ងៃ ឧទាហរណ៍ដូចជា បទត្រពាំងពាយអើយ ចៅព្រាហ្ម សារាយអណ្តែតជាដើម។ល។ ដែលប្រើតាខេ និងឃឹមជាសម្លេងដេញ ហើយមានធឹងជាដើមផង។ ម្យ៉ាងទៀត ចាប៉ីដងវែងក្នុងវង់ភ្លេងមេមត់ហាក់ដូចជាមិនសំខាន់ណាស់ណាទេ។ ឧទាហរណ៍ដូចជានៅភូមិត្នោតជ្រុំ វង់ភ្លេងនេះក៏ធ្លាប់ប្រើចាប៉ីដងវែងដែរ។ យ៉ាងណាមិញ បើទោះជាឥតមានចាប៉ីដងវែង ក៏គេនៅតែអាចលេងបានយ៉ាងពិរោះដែរ។

ដោយឡែក នៅរវាងប៉ុន្មានឆ្នាំចុងក្រោយនេះ ភូមិមួយចំនួននៅតំបន់ខាងជើងអង្គរ លែងសូវរាប់រកវង់ភ្លេងមេមត់ហើយ ដ្បិតពេលលៀងមេមត់ គេរកភ្លេងពិណពាទ្យ (អ្នកស្រុកនិយមហៅ «ភ្លេងសុផាត») មកជំនួសវិញ ដោយលើកហេតុផលថា ភ្លេងពិណពាទ្យរូបឆាប់ចូលជាង។[១២] ទំនោរបែបនេះ ឃើញថាធំដុំគ្រាន់បើដែរចំពោះអ្នកនៅតំបន់ខាងត្បូងអង្គរជាប់នឹងទន្លេសាបដូចជានៅចុងឃ្នៀសជាដើម។ យើងយល់ទៀតថា ជំនឿនៅពេលសព្វថ្ងៃនេះក៏ជាមូលហេតុមួយដែលគួរលើកមកពិចារណាដែរ។ អ្វីដែលយើងសង្កេតឃើញជាទូទៅនោះ គឺជំនឿលើបារមីផ្សេងៗ ដែលយល់ថារូបស្នងឱ្យវីរជន ស្តេចសម័យអង្គរ ទេពតាមសហគមន៍នានា ឬវត្ថុស័ក្តិសិទ្ធិណាមួយ។ ក្រុមបារមីទាំងនេះ គេនិយមរៀបចំពិធីបញ្ចូល ដោយប្រើភ្លេងពិណពាទ្យ។ នៅខាងក្នុំក្រោម យើងធ្លាប់ប្រទះឃើញយកស្គរសម្ភោរក្នុងវង់ភ្លេងពិណពាទ្យមកលេងចម្រុះគ្នាជាមួយឧបករណ៍ភ្លេងមេមត់។

៧. ទំនុកច្រៀង

ទោះបីជាបទខ្លះពុំដឹងថាមានតាំងពីពេលណាមកក៏ពិតមែន តែទំនុកច្រៀងមួយចំនួនធំអាចកើតឡើងភ្លាមៗ ដែលអ្នកច្រៀងមើលឃើញបរិស្ថានជុំវិញខ្លួននៅពេល កំពុងតែច្រៀង។ ជួនកាលជាពាក្យ លេបខាយឱ្យរូបមេមត់កំពុងរាំជាដើម។ ដូចបានរៀបរាប់ខ្លះៗ បើកាលណារូបមេមត់ចូលរាំលេងសប្បាយ បានន័យថាបំណងនៃការលៀងក៏សម្រេចលទ្ធផល។

ឃ្លាទំនុកបទចម្រៀងមួយចំនួនស្រដៀងគ្នា ដែលអ្នកច្រៀងយកទំនុកមកច្រៀង ដោយកាច់ទំនោរតាមសាច់ភ្លេងដើម្បីបង្កើតជាបទមួយផ្សេងទៀត ដូចជាបទ «អុំទូក» នៅភូមិថ្នល់បាក់ និងបទ «ស្ទើរ» នៅភូមិភ្វង់ជាឧទាហរណ៍។ សាច់ភ្លេងបទទាំង២ពុំដូចគ្នាទេ តែទំនុកច្រៀងដូចគ្នា។

---

[១១] និយាយនេះលើកលែងតែវង់ភ្លេងនៅភូមិត្នោតជ្រុំដែលពួកគាត់នៅលេងភ្លេងការទម្រង់បុរាណហៅថា «ភ្លេងគ្រឹម» តាំងពីដើមមកដល់សព្វថ្ងៃ។

[១២] ក្នុងពិធីលៀងមេមត់ដែលលើកឡើងពីខាងលើនោះប្រើវង់ភ្លេងពិណពាទ្យដែលមានឧបករណ៍៥គឺ រនាតឯក គងវង់ធំ ស្រឡៃ សម្ភោរ និងស្គរធំ ដែលគេអាចរកជួលបានពីវត្តយ៉ាងងាយ។

បទអុំទូក នៅភូមិថ្នល់បាក់ ល្បះទី២៖
«បងអុំទូកឆ្នោតអើយ ព្រលឹងកែវអើយ ទៅច្រូតអីនែស្រងែ អឺយ បងអុំទូកអើយឆ្នោតអើយ ព្រលឹងកែវអើយ ទៅច្រូតអីនែស្រងែ ភ្លៀងធ្លាក់អឺយ ភ្លៀងធ្លាក់អឺយខុសខែ ព្រលឹងកែវអឺយ ស្រងែបែកគុម្ព ស្រណោះភ្លៀងធ្លាក់អឺយខុសខែ ព្រលឹងកែវអឺយ ស្រងែបែកគុម្ព។»

បទស្មើរ នៅភូមិក្បង ល្បះទី១៖
«អេអើយ បងអុំហ្អើយ ទូកឆ្នោតហ្អើយ ឱណាថ្ងៃហ្អើយ អីនែទៅច្រូតហ្អើយស្រងែ ទៅច្រូតហ្អើយស្រងែ ឱណាថ្ងៃហ្អើយភ្លៀងធ្លាក់ហ្អើយខុសខែ ភ្លៀងធ្លាក់ហ្អើយខុសខែ ឱណាថ្ងៃហ្អើយ អីនែស្រងែបែកគុម្ព អើយ។»

ទំនុកបទខ្លះទៀតជាបទដែលគេនិយមលេងតាមពិធីមង្គលការ ដែលយើងតែងឮជាប្រចាំ។ វង់ភ្លេងភូមិថ្នល់បាក់មានបទផ្កាក្រង ត្រង់ល្បះទី២៖

«ដំរីធ្វន់ក្លុក មីអូនអើយ ត្រថុកធ្ងន់ផ្លែ ដំរីធ្ងន់ក្លុក អូនអើយ ត្រថុកធ្ងន់ផ្លែ យកគេធ្វើម៉ែមិនដូច អើយ ឱម៉ែខ្លួន អើយ ហាអើងអើយ គេបាន នៃ ចំណី ថ្ងៃអើយ គេលាក់ បំពួន ហ្អេ គេបាន នៃ ចំណី អូនអើយ គេលាក់ នៃ បំពួន មិនដូច អើយ ម៉ែខ្លួន ដេរទៅ អើយ ក៏ហៅមក អើយ ហាអឹងអើយ។»

ទំនុកខាងលើនេះទំនងជាមានជាយូរមកហើយ។ ក្រោយមកទៀតក៏មានការយកទំនុកដូចគ្នានេះមកច្រៀងម្តងទៀត។ ក្នុងបទ«ដំរីស»ច្រៀងដោយអ្នកស្រី រស់ សេរីសុទ្ធា និងទំនុកច្រៀង «ដំរីធ្ងន់ក្លុក មីអូនអើយ ត្រថុកធ្ងន់ផ្លែ» ក៏មានក្នុងទម្រង់បែបប្រជាប្រិយដែលច្រៀងដោយលោក តូច តេង និងអ្នកស្រី សូ សាវឿន ថែមទៀតផង។[១៣]

ដូចបានជម្រាបពីខាងដើមខ្លះៗមកហើយ បទចម្រៀងដំបូងៗគឺ ប្រគំអញ្ជើញគ្រូ ដែលទំនុកមានពាក្យអញ្ជើញគ្រូមករាំលេងសប្បាយ និងមកជួយប្រគំភ្លេងឱ្យឮពិរោះជាដើម។ គ្រូទាំងនោះក្រៅតែពីជួយប្រគំអ្នកភ្លេង ហាក់មានតួនាទីសំខាន់មួយទៀតគឺ មកព្យាបាលជម្ងឺ។ តែយើងនៅមិនប្រាកដថា គ្រូនោះសំដៅលើគ្រូកំណើត ឬយ៉ាងណាទេ ដ្បិតមេមត់ទាំងអស់មានជមគ្រូកំណើត ដែលរក្សាទុកលើក្តារហ៊ឹងនៅផ្ទះ ហើយយកមកជាមួយនៅពេលលៀង។ យើងប្រទះពាក្យ «គ្រូមកជួយស្តោះ ឬជួយបណ្តេញជម្ងឺ» ដែលយើងឮស្ទើរតែគ្រប់បទក្នុងវង់ភ្លេងភូមិឆ្នោតជ្រុំ។ ខាងក្រោមជាទំនុកច្រៀង ក្នុងក្រុមភ្លេងទាំង៥ភូមិ៖

---

[១៣] បទ«ដំរីស»៖ https://www.youtube.com/watch?v=y28urCGxBiU (10/08/2022), បទ«ដំរីធ្ងន់ក្លុកត្រថុកធ្ងន់ផ្លែ»(?)៖ https://www.youtube.com/watch?v=It0wkfcKQEs (10/08/2022)។

ក. ភូមិថ្នល់ចាក់

ល.រ	បទ	លេងពេល
១	ភ្ញាំង	ថ្វាយគ្រូ/សម្រាប់មេមត់រាំ
២	ម្ទប់ដូង	ថ្វាយគ្រូ/សម្រាប់មេមត់រាំ
៣	កុមារវេរ	មេមត់រាំ
៤	ផ្កាក្រង	មេមត់រាំ
៥	កុកគ្រោង	មេមត់រាំ
៦	កន្ទ្រប់	មេមត់រាំ
៧	ឡាំអ៊ួក	មេមត់រាំ/លេងពេលដេញព្រាយ (ពេលជិតចប់ពិធី)
៨	ដើតមន	មេមត់រាំ
៩	អុំទូក	មេមត់រាំ
១០	កាច់ផ្កា	បញ្ចប់កិច្ចសាពិតាន ឬសាច្រម/សម្រាប់មេមត់រាំ
១១	បរចាប	មេមត់រាំ/ក្មេងការ (ចាំចំណាងជើង ប៉ុន្តែក្មេចទំនុកច្រៀង និងបទក្មេង)
១២	ភ្នំស្រួច	សំពះគ្រូ/មេមត់រាំ (ចាំចំណាងជើង ប៉ុន្តែក្មេចទំនុកច្រៀង និងបទក្មេង)
១៣	ព្រៃកើត	សំពះគ្រូ/មេមត់រាំ (ចាំចំណាងជើង ប៉ុន្តែក្មេចទំនុកច្រៀង និងបទក្មេង)

ភ្ញាំង

១. លោកគ្រូអើយ សូមលោក អីនៃនិមន្ត អើយហ្អា អើយ គ្រូអើយ ហ្អេ អើយ ឱណាលោកអើយ សូមលោក អីនៃ និមន្ត អើយហ្អា អើយ គ្រូអើយ ហ្អេ ឱណាលោកអើយ សូមលោក អីនៃ និមន្ត អើយហ្អា កូនអើថៅ ណាកូនថៅ តែងមានអាសន្ន ឱណា គ្រូអើយ និមន្តឱ្យឱគ្រូមក អើយហ្អា កូនអើថៅ ណាកូនថៅ តែងមាន អាសន្ន ឱណា គ្រូអើយ មេមត់ ឱ្យគ្រូមក អើយ គ្រូហ្អើយប្រញាប់ឆាប់ អីនៃរិះរក ហើយយាងមក កូនថៅ អីនៃត្រូវការ។

២. អើង អើយ គ្រូហ្អើយ អីនៃ យាងឆាប់ អើយ ហ្អា អើយ គ្រូអើយ ហ្អេ ឱណាលោកអើយ គ្រូអើយ អីនៃ យាងឆាប់ អើយហ្អា អើយ គ្រូអើយ ហ្អេ ឱណាលោកអើយ គ្រូអើយ ឱ្យឱយាងឆាប់ អើយ កូនថៅ ណាកូនថៅ នៃ ប្រញាប់អើយ ឱណាគ្រូអើយ ហួសពេល អីនៃ វេលា កូនថៅ ណាកូនថៅ ចង់បានឱ្យឆាប់ ឱណាគ្រូអើយ ហួសពេល អីនៃ វេលា អើយ គ្រូអើយឆាប់ៗ កុំមករួញរា ហ្អា ឱណាគ្រូអើយ ឆាប់ឡើយណាកូនធូរ អើយ ហ្អា។

ម្ញប់ដូង

១. ឱម្ញប់ដូង អើយ ឱណាអូន ហ្អើយ ស្រណោះ អីអីនៃ ម្ញប់ដូង អើយ ម្ញប់ដូង អើយ ឱណាអូន ហ្អើយ ស្រណោះ អីអីនៃ ម្ញប់ដូង អើយ ស្រីហ្អើស្រស់ ណាស្រីស្រស់ អីនៃ ទងវង ហ្អា ឱណា ថ្ងៃហ្អើយ ស្រីជ្រក ជាមួយនឹងបង អើយ ស្រីហ្អើស្រស់ ណាស្រីស្រស់ អីនៃ ទងវង ហ្អា ឱណា ថ្ងៃហ្អើយ ស្រីជ្រកជាមួយនឹងបង អើយ។

២. ម្ញប់ដូង អើយ ឱណាថ្ងៃ ហ្អើយ យើងមិនដែលមានសៅហ្មង អើយ ហ្អា ម្ញប់ដូង អើយ ឱណាថ្ងៃ ហ្អើយ មិនដែលមាន អីនៃ សៅហ្មង អើយ អូនហើយណាអូនហើយ អីនៃ នឹងបង ហ្អើ ឱណា ថ្ងៃហ្អើយ មិនដែល អីនៃ ឃ្លាតឃ្លា អើយ អូនអ្ហើយណាអូនអ្ហើយ អីនៃ នឹងបង ហ្អើ ឱណា ថ្ងៃហ្អើយ មិនដែល អីនៃ ឃ្លាតឃ្លា អើយ ហ្អា។

៣. ព្រះគុណយាងមក អើយ ឱណា ថ្ងៃហ្អើយ ជំទាវ អីនៃ ស្រីខ្មៅ អើយ ហ្អា ព្រះគុណយាងមក អើយ ឱណា ថ្ងៃហ្អើយ ជំទាវ អីនៃ ស្រីខ្មៅ អើយ ព្រះគុណអីណាព្រះគុណ អីនៃយាងទៅ ហ្អា ឱណា ថ្ងៃហ្អើយ បាក់ស្មៅ អីនៃ ទាំងវាល អើយព្រះគុណណាព្រះគុណ អីនៃ យាងទៅ ហ្អា ឱណា ថ្ងៃហ្អើយ បាក់ស្មៅ អីនៃ ទាំងវាល អើយ ហ្អា។

៤. បាក់ទាំងគុម្ពព្រិច អើយ ឱណាថ្ងៃ ហ្អើយ វារេចទាំង អីនៃគុម្ពទ្រៀល អើយ ហ្អា បាក់ទាំងគុម្ពព្រិច អើយ ឱណាថ្ងៃ ហ្អើយ វារេចទាំង អីនៃគុម្ពទ្រៀល អើយ បាក់ហ្អើស្មៅ ណាបាក់ស្មៅ អីនៃ ទាំងវាល ហ្អា ឱណាថ្ងៃ ហ្អើយ ស្នាដៃសម្តេចព្រះគ្រូ អើយ បាក់ហ្អើស្មៅ ណាបាក់ស្មៅ អីនៃ ទាំងវាល ហ្អា ឱណាថ្ងៃ ហ្អើយ ស្នាដៃ សម្តេចព្រះគ្រូ អើយ ហ្អា។

ក្មេងវរេ

១. អេ អើយ ផ្គរលាន់ឯជើង ថ្ងៃហ្អើយ នៃ ថាផ្គរលាន់ឯជើង ផ្គរលាន់ឯជើង ថ្ងៃហ្អើយ ផ្គរលាន់ឯជើង នៃ ក្រមុំឱ ស្រុកយើង វាជុំចង អីនៃជិះឡាន ហ្អេ អើយ ជិះឡាន។

២. អេ អើយ តែម៉ាកាក់ពីរកាក់ ថ្ងៃហ្អើយ ថាវាជិះ ឱ មិនបាន ថាម៉ាកាក់ពីរកាក់ ថ្ងៃហ្អើយ ថាវាជិះមិនបាន លក់ខ្លួនលក់ប្រាណ ធ្វើម្តេចឱ្យ តែបានជិះឡានសិន អើយ ឡានសិន។

៣. អេ អើយ ផ្គរលាន់ច្រកភ្នំ ជ្រែកគុម្ព អីនៃ រមៀត ផ្គរលាន់ច្រកភ្នំ ថ្ងៃហ្អើយ ជ្រែកគុម្ពរមៀត នៃ បើនាងមាន ទៀត ប្រាប់បង អីនៃ ដោយស្មគ្រ អើ អើយ ដោយស្មគ្រ។

៤. អេ អើយ នៃ ក៏ បាតដៃខ្នងដៃ ទុកជា អីនៃ បន្ទាស់ បាតដៃខ្នងដៃ ថ្ងៃហ្អើយ ទុកជាបន្ទាស់ ប្រាប់បងដោយ ស្មោះ បងហ្នឹង អេ ដោះដៃចេញ ហ្អេ អើយ ដៃចេញ។

ផ្កាក្រាង

១. តូចហ្អើយ ស្រីតូច អូនហ្អើយ តូចហ្អើយ ស្រីតូច ហ្អេ តូចហ្អើយ ស្រីតូច ថ្ងៃហ្អើយ តូចហ្អើយ ស្រីតូច បង សុំអើយ ទទូច នាងហ្អើយ តូចស្រីហ្អើ ម៉ោថ្នមបី ហ្អេ អើយ ហាអឺងអើយ ថ្នមគោរទេះ ថ្ងៃហ្អើយ ថ្នមសេះ ដំរី ថ្នមគោរទេះ ថ្ងៃអើយ ថ្នមសេះ ដំរី តូចចេះ ហ្អើយ ថ្នមបី ថ្នមកាយ ឱបង អឺផង អឺយ ហាអើងអឺយ។ យើស យើស

២. ដំរីធ្ងន់ក្លុក មីអូនអើយ ត្រថុកធ្ងន់ផ្ទៃ ដំរីធ្ងន់ក្លុក អូនអើយ ត្រថុកធ្ងន់ផ្ទៃ យកគេធ្វើម៉ែមិនដូច អឺយ ឱម៉ែខ្លួន អឺយ ហាអើងអឺយ គេបាន នៃ ចំណី ថ្ងៃអើយ គេលាក់ បំពួន ហ្អេ គេបាន នៃ ចំណី អូនអើយ គេលាក់ នៃ បំពួន មិនដូច អើយ ម៉ែខ្លួន ដេរទៅ អើយ ក៏ហៅមក អើយ ហាអឺងអើយ។

ក្អុកក្អារគ្រោង

១. ឱ កុក អើយ គ្រោង ហ្អើយ ហ្អេ ចុះ ហ្អា ស៊ី ត្រីចង្វា ឱ កុក អើយ គ្រោង ហ្អើយ ហ្អេ ចុះ ហ្អា ស៊ី ត្រីចង្វា កំភ្លាញ នៃវាថា អាកុកច្រមុះវែង អឺយ កំភ្លាញ នៃវាថា អាកុកកវែង។

២. ឱ កុក អើយ គ្រោង ហ្អើយ អើយ ខ្ញុំនេះក៏និយាយ អើយ លេង ឱ កុក អើយ គ្រោង ហ្អើយ អើយ ខ្ញុំអ្នក អឺង អើយ និយាយ អើយ លេងថាកុក អើយ កវែង ចង់ ហ្អើយ ត្រីចង្វារ ថាកុក អើយ កវែង ចង់ ហ្អើយ ត្រីចង្វារ។

៣. ព្រះអើយសែនស្តាយ អើយ ស្តាយណាស់ ស្រីស្រស់សង្ហា ស្តាយ អើយ សែនស្តាយ ស្តាយស្រី អើយ កនិដ្ឋា ស្រីស្រស់ នៃ ជីវ៉ា អូននៅឯស្រុក អើយ ឆ្ងាយ ស្រីស្រស់ នៃ សង្ហា អូនវានៅ ឱស្រុក អើយ ឆ្ងាយ ។

៤. ស្តាយ អឺយ សែនស្តាយ ស្តាយអើយ នៃបងសែន អើយស្តាយ ស្តាយ អឺយ សែនស្តាយ ស្តាយអើយ នៃ បងសែន អើយស្តាយ ព្រោះអូននៅឆ្ងាយ ធ្វើម្តេចបងនឹងទៅ អើយ ដល់ អឺយ ព្រោះអូននៅឆ្ងាយ ធ្វើម្តេច បាននឹងទៅ អើយ ដល់។

កន្ត្រប់

១. កន្ត្រប់អើយ ត្រប់អើយ ថ្ងៃអើយ ទៅកប់នឹងចំបើង កន្ត្រប់អើយ ត្រប់អើយ ថ្ងៃអើយ ទៅកប់នឹងចំបើង យកដៃទៅ ទៅប៉ើង ថ្ងៃអើយ ចាប់ទុកបើចង់ជ្រក់ យកដៃក៏ទៅ ទៅប៉ើង ថ្ងៃអើយ ចាប់ទុកបើចង់ជ្រក់។

២. នាងស្រីអើយនាងស្រី ថ្ងៃអើយនាងអើយនាងស្រីអើយ នាងអើយក៏នាងស្រី បើនាងអើយយកប្តី ថ្ងៃអើយ នាងប្រាប់បងផង បើនាងយកប្តីថ្ងៃអើយ នាងប្រាប់ក៏បងផងអើយ។

៣. ម៉ាស្ទឹងហាសិប អើយនៃបងយកទៅចង ម៉ាស្ទឹងហាសិប អើយនៃបងយកទៅចង ឆ្លើយប្រាប់អឺយបងផង អឺយ អីនៃហូបជ្រក់រួមគ្នា ឆ្លើយប្រាប់បងផង អឺយនៃហូបជ្រក់ក៏រួមគ្នា។

៤. បងស្រឡាញ់អឺយស្រីក្រែល អឺយនៃ កាលក្រែលក៏មកវិញ បងស្រឡាញ់អឺយស្រីក្រែលអីនៃ កាលក្រែលនៃមកវិញ បងស្រឡាញ់ស្រីនេះអីនៃបាត់មុខក៏មិនបាន បងស្រឡាញ់អឺយស្រីនេះអីនៃបាត់មុខក៏មិនបាន។

៥. បាត់មុខអើយមួយថ្ងៃអើយ នាង អឺយ មុខបងឱ្យខ្មៅប៉ែ បាត់មុខអើយមួយថ្ងៃអើយ អី នៃ មុខបងឱ្យខ្មៅប៉ែ បាត់មុខមួយខែ នាងអឺយដូចក្ដែ អឺយ បាត់ម្ចាស់ បាត់មុខ អឺយ មួយខែ នាងដូចក្ដែ អឺយ បាត់ម្ចាស់ អើយ។ អឺប អឺប...

៦. បងស្រណោះអីអឺយ អីនៃ ប្រវែកប្រវឹកនៃអើយ បងស្រណោះអីវើយ អីនៃព្រវែក អឺយ ព្រវឹក បានប្ដីចេះផឹក អីនៃអស់មាន់ក៏អស់ទា បានប្ដីចេះផឹក អីនៃអស់មាន់ក៏អស់ទា អើយ។

ឡាំអ៊ួកា

១. អេ អឺង អើយ ហ្អាអឺងអើយ ផាត់មារចេញ បណ្ដេញ អីនៃ មារទៅ អើយ មារហ្អើយ កុំនៅ ស្រុកគេ អីនៃ ក្រណាស់ អើយ ថ្ងៃហ្អើយ ស្រុកគេ អីនៃ ក្រណាស់ អើយ ហាអឺងអើយ ហ្អា។

២. អេ អឺង អើយ ហ្អាអឺងអើយ មារហ្អើយ ចេញទៅ ចេញឱ្យ អីនៃ ស្រឡះ អើយ ចេញហើយ ចេញឱ្យ អីនៃ ស្រឡះ ស្រុកគេក្រណាស់ មារហ្អើយ ប្រញាប់ចេញទៅ អើយ ហ្អាអើយហ្អា

៣. អេ អឺង អើយ ហ្អាអឺងអើយ កម្ចាត់មារចេញ បណ្ដេញ អីនៃ មារទៅ អើយ មារហ្អើយ កុំនៅ ស្រុកគេ អីនៃ ក្រណាស់ មារហ្អើយ ចេញហើយ ចេញទៅ ឱអើយ ស្រឡះ អើយ ស្រឡះ មារហ្អើយ ប្រញាប់ចេញទៅ អើយ ហ្អាអើយហ្អា។

៤. អេ អឺង អើយ ហ្អាអឺងអើយ កម្ចាត់មារចេញ បណ្ដេញ អីនៃ មារទៅ អើយ មារហ្អើយ កុំនៅ ស្រុកគេ អីនៃ ក្រណាស់ ចេញហើយ ចេញទៅ ឱ្យស្រឡះ ស្រុកគេក្រណាស់ មារហ្អើយ ប្រញាប់ចេញទៅ អើយ ហ្អាអើយហ្អា។

៥. អេ អឺង អើយ ហ្អាអឺងអើយ មារអើយ មារហ្អើយ អីនៃ ចេញទៅ មារហ្អើយ កុំនៅ ស្រុកគេ អីនៃ ក្រណាស់ ចេញហើយ ចេញទៅ ឱ្យស្រលះ មារអើយ ក្រណាស់ ប្រញាប់ អីនៃ ចេញទៅ អើយ ហ្អាអើយហ្អា។

ជីតមង

១. ពៅហ្អើយ ស្រីពៅ អីនៃ ពៅហ្អើយ ស្រីអីពៅ ហ្អេ ពៅហ្អើយ ស្រីពៅ អីនៃ ពៅហ្អើយ ហ្អា ស្រីហ្អាពៅ ហ្អើស្រណោះ ណា បងទៅ ពៅហ្អើយ ពៅចាប់ណាផ្ដែចង ស្រណោះ នៃ បងទៅ ពៅហ្អើយ ពៅចាប់ណាផ្ដែចងអួនដាក់ណាច្រវ៉ាក់ ហ្អេ ឬដាក់ខ្សែចង អើយ អួនដាក់ណាច្រវ៉ាក់ នៃ ឬ ដាក់ខ្សែចង ពៅចាប់ឱផ្ដែចងនាង ហ្អើយ បង នៃ ឆ្ងងដល់ ពៅចាប់ណាផ្ដែចង នាងហ្អើយ បង នៃ ឆ្ងងដល់។

២. ម៉ះ អើយ ស្រីម៉ះ ហ្អើ ម៉ះអើយ ហ្អា ស្រីម៉ះ អើយ ម៉ះ អើយ ស្រីម៉ះ ហ្អើ ម៉ះអើយ ហ្អា ស្រីហ្អាម៉ះ ផ្ទះធំណាស្រឡះ នាងអើយ ម៉ះដេកអឺម្នាក់អឺឯង ផ្ទះធំណាស្រឡះ ថ្ងៃអើយ ម៉ះដេកម្នាក់អឺឯង បើម៉ះបានបង នៃ មានគ្នា នៃ កំអឺប្លែង អើយ បើអូនបានបង នៃ នឹងបានគ្នាកំប្លែង ពៅដេកម្នាក់ឯង នាងហ្អើយ ប្រឡែងតែនឹងហ្អាខ្នើយ ម៉ះដេកម្នាក់ឯង នាងហ្អើយ ប្រឡែងតែនឹងហ្អាខ្នើយ។

៣. បងស្រលាញ់ស្រីស សហ្អើយហ្អា ដូចក្អែក អើយ ស្រលាញ់ស្រីស សហ្អើយហ្អា ដូចក្អែក ដៃទន់ ហ្អា ដូចដែក នាងហ្អើយ ជាងណាគេដុត ហ្អា ឱ្យ ដៃទន់ ហ្អា ដូចដែក នាងហ្អើយ ជាងណាគេដុត ហ្អា ឱ្យជាងនេះដំមុន នៃ ជាងនោះ ហ្អា ដំណាក្រោយ អើយ ជាងនេះដំមុន នៃ ជាងនោះ ហ្អា ដំណាក្រោយ ជាងណាដំឱ្យនាងហ្អើយ ដៃទន់ ហ្អា ដូចដែក ជាងណាគេដំឱ្យ ថ្ងៃហ្អើយ ដៃទន់ ហ្អា ដូចដែក។

៤. ផ្គរលាន់ឯត្បូង ហ្អេ ត្រយោងហ្អាចេកក្តឹប អើយ ផ្គរលាន់ឯត្បូង អីនៃ ត្រយោងហ្អាចេកក្តឹប នាំគ្នាសាមសិបទៅដណ្តឹង នៃ កូនគេ នាំគ្នាសាមសិប នាងអើយ ដណ្តឹងកូនគេ ឪគេថាឱ្យ ហ្អេ ម្តាយនាងថាទេ អើយ ឪពុកថាឱ្យ ហ្អើ ម្តាយនាងថាទេ លើកកូន នៃ ឱ្យគេ ថ្ងៃហ្អើយ ចង់ស៊ីណាក្បាលជ្រូក លើកកូន ហ្អា ឱ្យគេ លោកហ្អើយ ចង់ស៊ីណាក្បាលជ្រូក......អើយ។

អុំទូក

១. អើយបងអុំទូកទៅអឺយ ព្រលឹងកែវអើយ អុំកាត់អីនៃវាលធំអើយ បងអុំទូកទៅអឺយ ព្រលឹងកែវអើយ អុំកាត់អីនៃវាលធំអើយ កែវអើយកែវអើយកុំយំ ព្រលឹងកែវអើយស្រុកបង អីនៃ ឆ្ងាយណាស់អើយ កែវអើយកែវអើយ កុំយំព្រលឹងកែវអើយ ស្រុកបងអីនៃឆ្ងាយណាស់អឺយ។

២. បងអុំទូកឆ្នោតអើយ ព្រលឹងកែវអើយ ទៅប្រចូតអីនៃស្រងែ អឺយ បងអុំទូកអើយឆ្នោតអើយ ព្រលឹងកែវអើយ ទៅប្រចូតអីនៃស្រងែ ភ្លៀងធ្លាក់អឺយ ភ្លៀងធ្លាក់អឺយខុសខែ ព្រលឹងកែវអឺយ ស្រងែបែកគុម្ព ស្រណោះភ្លៀងធ្លាក់អឺយខុសខែ ព្រលឹងកែវអឺយ ស្រងែបែកគុម្ព។

៣. ស្រណោះបងដើរឆ្វេងព្រែក ព្រលឹងកែវអឺយ ឮខ្វែកអីនៃវាយំអឺយ បងដើរឆ្វេងព្រែក ព្រលឹងកែវអឺយ ឮខ្វែកអីនៃវាយំ ស្រណោះបងដើរឆ្វេងភ្នំ ព្រលឹងកែវអឺយ ឮឃ្មុំវាយកផ្កា ស្រណោះបងដើរឆ្វេងភ្នំ ព្រលឹងកែវអឺយ ឮឃ្មុំវាយកផ្កា។

៤. ស្រណោះអឺយតាំងពីប្រាំងអឺយ ព្រលឹងកែវអឺយដល់ខែអីនៃវស្សាអើយ ស្រណោះអូនតាំងពីប្រាំងអឺយ ព្រលឹងកែវអឺយ ដល់ខែវស្សា អឺយ ស្តាប់ឃ្មុំៗឱណាយកផ្កា ព្រលឹងកែវអើយ ឃ្មុំពេញឱណាក្បាលផ្ទិតអើយ ស្រណោះស្តាប់ឃ្មុំយកផ្កា ព្រលឹងកែវអឺយ ឃ្មុំពេញអឺយណាក្បាលផ្ទិត។

កាច់ផ្កា

១. ឯងកាច់ហ្អើយ ផ្កាអី អឺងអើយ ឯងកាច់ អើយ ផ្កាអី ទងវង អើយណាបង ហ្អើយ........កាច់ផ្កា ឱត្របែក អើយ ឯងកាច់ផ្កាអី ឯងកាច់ អើយ ផ្កាអី ទងវង អើយ ណាបង ហ្អើយ កាច់ផ្កា ឱត្របែក អឺយ អញសួហ្អើយ គ្រប់មែក អើយ អញសួ ហ្អា គ្រប់មែក សង្សារ ហ្អា បង ហ្អើយ យកមក អើយ ផ្ញើនាង អើយ អឺយ អញសួ ហ្អើយ គ្រប់មែក អើយ អញសួហ្អើយ គ្រប់មែក សង្សារ ហ្អា ថ្លៃ ហ្អើយ យកមក អើយ ឱផ្ញើនាង អើយ ហ្អា។

២. កាច់ អើយ ផ្កាអី អើយ ឯងកាច់ផ្កាអី កាច់ផ្កា អឺងអើយ ចម្ប៉ាឱណា មកជូននាង អើយ ឯងកាច់ផ្កាអី អឺយ ឯងកាច់ផ្កាអី កាច់ផ្កា អើងអើយ ចម្ប៉ា យកមក ឱផ្ញើនាង បានផ្កាល្អៗ អើយ បានផ្កាល្អៗ ថ្លៃហ្អើយ យកមក បងមិនវាង ចូលមុខ អើយ ឱផ្ទះស្រី អើយ អើយ កាច់ផ្កាល្អៗ អើយ កាច់ផ្កាល្អៗ ស្រីហ្អើយ នាងស្រី យកមក អើយ មកផ្ទះនាង អើយ។

៧. ភូមិព្រះដាក់

ល.រ	បទ	លេងពេល
១	ស្រីស្ទើរ	ថ្វាយគ្រូ/សម្រាប់មេមត់រាំ
២	អុំទូក	មេមត់រាំ
៣	ម្ទប់ដូង	មេមត់រាំ
៤	បរចាប	មេមត់រាំ
៥	ឡាំយីកេ	មេមត់រាំ
៦	គ្រាំង	ថ្វាយគ្រូ/សម្រាប់មេមត់រាំ
៧	ឡាំ	មេមត់រាំ (ពេលមេមត់ចង់បានបទញាប់ ឬកន្ត្រាក់)
៨	កន្ត្រប់	មេមត់រាំ
៩	ជ្វា	ដេញព្រាយ/សម្រាប់មេមត់រាំ/កាច់ផ្កាសាពិតាន
១០	ផ្កាក្រង	មេមត់រាំ
១១	កាត់ស្លឹក	មេមត់រាំ
១២	ក្របីដល់ចេក	មេមត់រាំ (អ្នកច្រៀងមិនសូវចាំ ដោយសារខានលេងយូរ)

ស្រីស្មើរ

១. ហី អឺ ហីអឺអឺងអើយ ថ្មមអូនហ្អើយ ឱណា ជង្គង់ ឱ ខ្ញុំបត់ ខ្ញុំហ្អើយ ឱប្រណម អើយ ហីអឺអឺងអើយ អើយ នៃប្រណម ហី អឺ ហីអឺអឺងអើយ ថ្មមអូនហ្អើយ ជង្គង់ហ្អើយ ឱ ខ្ញុំបត់ ហត្ថខ្ញុំហ្អើយ ឱ ប្រណម

២. អឺ ហីអឺអឺងអើយ ថ្មមអូនហ្អើយ ដៃខ្ញុំ កែវហ្អើយ ឱ ប្រណម អញ្ជើញហ្អើយ ឱ គ្រូតូច អើយណា លោកហ្អើយ ស្តើងអូនហ្អើយ អញ្ជើញហ្អើយ លោកគ្រូធំ ឱ ពៅអូនហ្អើយ កែវហ្អើយ អញ្ជើញ កែវហ្អើយ នៃគ្រូធំ គ្រូស្តោះ គ្រូផ្ទុំ គ្រូហ្អើយគ្រូ អញ្ជើញទាំងគ្រូ នៃមន្តអាគម គ្រូហ្អើយ អើយ នៃជួយខ្ញុំ ហ្អើយ កែវហ្អើយ ស្តើងអូនហ្អើយ ជួយប្រហ្អើយនៃគុំភ្លេង ឱ គ្រូខ្ញុំហ្អើយ ស្តើងហ្អើយ ជួយប្រហ្អើយនៃគុំភ្លេង គ្រូហ្អើយ ជួយលេងលោកហ្អើយ អើយ ជួយច្រៀងហ្អើយ ឱ ប្រគំ។

៣. ហា អឺ ហីអឺអឺងអើយ ពៅអូនហ្អើយ អញ្ជើញទាំងហ្អើយ ឱ គ្រូជិត អញ្ជើញទាំង ឱ គ្រូឆ្ងាយ អើយ ហី អឺ អឺងអើយ ស្តើងអូនហ្អើយ អញ្ជើញ ណា គ្រូឆ្ងាយ

៤. ហា អឺ ហីអឺអឺងអើយ ថ្មមអូនហ្អើយ អញ្ជើញហ្អើយ គ្រូនៅឆ្ងាយ គ្រូបងហ្អើយ ឱ គ្រូពិត អើយ ហីអឺអឺង អើយ ថ្មមអូនហ្អើយ ជ្រោះជ្រង ដង នៃ ប្រឡាយ គ្រូហ្អើយ នៅឆ្ងាយ លោកហ្អើយ ស្តើងអូនហ្អើយ មកជួយ ហ្អើយ នៃ ប្រោះព្រំ ឱ គ្រូខ្ញុំហ្អើយ លោកហ្អើយ ជួយមកហ្អើយ ប្រោះព្រំ ខ្ញុំលេងប្រគំ ស្តើងអូនហ្អើយ ថ្វាយ អស់ហ្អើយ នៃគ្រូហើយ។

អុំទូក

១. បងអុំហ្អើយទូកទៅ កាពៅអូនអើយ ទឹករាក់ហ្អើយ ទឹកជ្រៅ អុំទូកទៅ ក្រមុំអូនអើយ ទឹករាក់ហ្អើយ ទឹកជ្រៅហ្អើយ បងអុំ បងអុំហ្អើយ ស្រីទៅអើយ ក្រមុំអើយ ទៅលេងអើយអង្គរ ដើណា ដើងណា កែវណា ក្រមុំ អូនអើយ ទៅលេងអង្គរ។

២. បងបោះបងបាន ក្រមុំកែវអើយ ច្រើនអស់កុះករ ជូនអូនទៅបាន ក្រមុំបងអើយ ភ្ញៀវអស់កុះករ ជូនអូន ជូនអូនលេងអង្គរ ក្រមុំអូនអើយ ទៅនឹងបង ដើណា ឱណាអូនអើយ ក្រមុំកែវអើយ ទៅលេងឱនឹងបង។

៣. ដាក់អូនឱខាងមុខ ក្រមុំកែវអើយ ទុកអូនខាងខ្នង ដាក់អូនខាងមុខ ក្រមុំអូនអើយ ទុកអូនខាងខ្នង ដាក់ទូ ដាក់ទូលើភ្លៅបង ក្រមុំអូនអើយ ខ្លាចញាតិគេថា ដើណា ឱណាអូនអើយ ក្រមុំកែវអើយ ខ្លាចញាតិគេថា។

៤. ដាក់ទូខាងមុខ ក្រមុំអូនអើយ ពុកអូននៅក្រោយ ដាក់ទូខាងមុខ ក្រមុំអូនអើយ ពុកអូននៅក្រោយ ដាក់ទូ ដាក់ទូទុកឱ ក្រមុំអូនអើយ ដាក់លើភ្លៅបង ដើណា ឱណាកែវអើយ ឱសង្សារហ្អើយ ដាក់លើភ្លៅបង។

៥. ទូកបងលឿនលយ ក្រមុំអូនអើយ កន្សែងចងក្បាល ទូកបងលឿនលយ ក្រមុំបងអើយ កន្សែងចងក្បាល

ឈរចាំ ឈរចាំកណ្តាលហ្អើយ ក្រមុំអូនអើយ ដែបកហៅអូន ដើណា ឱណាកែវអើយ ឱសង្សារអើយ ដែបករកអូន..គ្រោ ឆើស..ឆើស។

៦. ក្រមុំបងអើយ ដៃឆ្វេងកាន់ថ្នាំ អីយ៉ាស់ដៃឆ្វេងកាន់ថ្នាំ ក្រមុំបងអើយ ដៃស្តាំបងកាន់ម្ទូ ឈរចាំ ឈរចាំអើយស្រីទូ ឱទូអូនហ្អើយ នៅមុខផ្ទះបង ដើណា ឱណាអូនអើយ ក្រមុំកែវអើយ នៅមុខផ្ទះបង។

៧. ទាំងយប់អាធ្រាត្រ ក្រមុំបងអើយ ព្រលប់អើយឆ្ងង អីយ៉ាស់ទាំងយប់អធ្រាត្រ ក្រមុំបងអើយ ទាំងយប់អាធ្រាត្រឆ្ងង ឈរចាំ ឈរចាំអើយផ្លូវបង ក្រមុំអូនអើយ ជូនអូនអើយទៅផ្ទះ ដើណា ឱណាកែវអើយ ក្រមុំអូនអើយ ជូនទូទៅផ្ទះ។

ម្ទប់ដូង

១. ឱម្ទប់ដូងហ្អើយ អើយ ព្រលឹងកែវហ្អើយ ដែលខ្ញុំធ្លាប់ជ្រកម្ទប់ដូងហ្អើយ អើយព្រលឹងកែវហ្អើយ ដែលខ្ញុំធ្លាប់ជ្រកលោកមេបាមេបា អញ្ជើញមក ព្រលឹងកែវហ្អើយ អង្គុយឱលើព្រំ ដើណាដើណា ថ្ងៃណា ព្រលឹងកែវហ្អើយ អង្គុយលើព្រំ។

២. ឱម្ទប់ដូងហ្អើយ អើយព្រលឹងកែវហ្អើយ ដែលបងធ្លាប់ជ្រក ម្ទប់ដូងហ្អើយអើយព្រលឹងកែវហ្អើយ ដែលបងធ្លាប់ជ្រក មេបាមេបាអញ្ជើញមក ព្រលឹងកែវហ្អើយ ឱអង្គុយឱលើព្រំ ដើណា ដើណាថ្ងៃណា ព្រលឹងកែវហ្អើយ ឱអង្គុយឱលើព្រំ។

៣. បាំងឆ័ត្រជូនម្តាយហ្អើយអើយ ព្រលឹងកែវហ្អើយ ដែលលោកឱជាធំ បាំងឆ័ត្រជូនម្តាយហ្អើយ អើយព្រលឹងកែវហ្អើយ ដែលលោកឱជាធំអ្នកមាន អ្នកមានគុណធំហ្អើយ ព្រលឹងកែវហ្អើយ ដូចភ្នំព្រះសុមេរុ ដើណា ដើណាថ្ងៃណា ព្រលឹងកែវហ្អើយ ឱភ្នំព្រះសុមេរុ (គ្រោ..ឆើត..ឆើត..ហើស..ហើស..ឆើត..ឆើត)។

៤. បារមីសណ្ឋិតហ្អើយ អើយព្រះគុណខ្ញុំហ្អើយ ជួយបាំងរាំងរាហ្អើយ បារមីសណ្ឋិតហ្អើយ អើយ ព្រលឹងខ្ញុំហ្អើយ ជួយបាំងរាំងរាហ្អើយ ជួយប្រោះ ជួយព្រំការពារ ព្រលឹងកែវហ្អើយ ដល់យើងខ្ញុំហ្អើយផង ដើណា ដើណាថ្ងៃណា ព្រលឹងកែវហ្អើយ ដល់យើងខ្ញុំហ្អើយផង។

៥. មានទាំងគ្រូតូចហ្អើយ អើយ ព្រលឹងខ្ញុំហ្អើយ មានគ្រូកាន់ដំបងហ្អើយមានទាំងគ្រូតូចហ្អើយ ព្រលឹងខ្ញុំហ្អើយ មានគ្រូកាន់ដំបងហ្អើយ បារមី បារមីជួយខ្ញុំផងហ្អើយ ព្រលឹងកែវហ្អើយ ជួយសង្គ្រោះស្រី ដើណា ដើណាថ្ងៃណា ព្រលឹងកែវហ្អើយ ជួយសង្គ្រោះស្រី។

៦. ជួយស្តោះខាងមុខហ្អើយ ព្រលឹងកែវហ្អើយ ជួយស្តោះពីខាងក្រោយ ជួយស្តោះខាងមុខហ្អើយ ព្រលឹងខ្ញុំហ្អើយ ជួយផ្លុំពីខាងក្រោយ សុំជួយ សុំជួយស្តោះឱ្យហ្អើយ ព្រលឹងកែវហ្អើយ កែរោគឱទាំងពួង ដើណា ដើណាថ្ងៃណា ព្រលឹងកែវហ្អើយ កែរោគឱទាំងពួង។

បរចាប

១. ហី អឺ អឺង អឺ អើយ ហីអឺងអើយ បងទៅ ឱ ដេញចាប ហ្អើយ អើយ ហ្អើយ អើយ អឺ អូនហ្អើយ ចាបចេញទៅ ឱ ស៊ីស្រូវ ហីអឺអើយ ស៊ីស្រូវ។ ហា អឺ ហ្អើយ ហ្អើយ ហី អូន ហ្អើយ បងចេញទៅ ឱ ដេញចាប អើយ ហឺ ហ្អើយ ហីអឺងអើយ ចាបវានៅ ឱ ស៊ីស្រូវ ឱណា ឱ ស៊ីស្រូវ។

២. ហា អឺ ហឺ ហ្អើយ អឺ អើយ ឱ ស៊ីស្រូវ ហីចាបធំ ឱ ហើរទៅ ហ្អើយ ហ្អេ ឱ ហើរទៅ ធើ ធើ គ្រោ គ្រោ ព្រោះស្រូវ អញ ឱ វាទុំ ហី អឺ អើយ ឱ វាទុំ។ ហា អឺ ហ្អើយ ហ្អេ អឺ អើយ ឱ អូន ហ្អើយ ព្រោះស្រូវ ឱ ខ្ញុំទុំ អើយ អឺ អើយ ឱ អឺង អើយ ស្រូវឱ ហ្អេ ឱ ចាប អើយ ឱណា ណា ឱ ចាប អើយ (គ្រោ គ្រោ គ្រោ ធើស ធើស)។

៣. ហី អឺ ហ្អើ អឺ អើយ ឱអូន ហ្អើយ ព្រោះថ្ងៃ ឱ ក្តៅខ្លាំង ហ្អើ អើយ ហី អឺ ហ្អើ អើយ ឱ ក្តៅខ្លាំង ព្រោះ ចាប ទៅ ឱ ស្រូវខ្ញុំ ឱណា ណា ឱ ស្រូវខ្ញុំ..គ្រោ គ្រោ ធើស ធើស..យើស។ ហា អឺ ហ្អើយ ហ្អេ អឺ អើយ ឱមុំហ្អើយ ព្រោះបង ឱ ទៅដេញ ហ្អេ អើយ អឺ អើយ ឱ ទៅដេញ ហី ចាបសែនហើរ ឱ មកវិញ ឱណា ណា ឱ មកវិញ (គ្រោ គ្រោ)។

ឡាំយីកោ

គ្រោ..ហឹស..ធើស..ធើស..ហឹស..ហឹស

១. អូនហ្អើយ ថ្ងៃអើយ អូនអើយ មុំអើយ ស្រីមុំអូនអើយ មុំអើយស្រីមុំ ថ្កាល់នាងលឿងទុំអើយ នែក្រមុំអើយ ទៅណា ថ្កាល់នាងលឿងទុំ នាងអើយ ក្រមុំនាងទៅណា ឱ្យបងសុំផ្កា នាងអើយ មេត្តាប្រាប់ផង ឱ្យនាងសុំផ្កា នាងអើយ មេត្តាប្រាប់ផង គ្រោ ធើស ហឹស ពើត ពើត។

២. ហឹយ នា ឱរណា ណៃអើយ ក្រមុំបងអើយ នាងអើយចាំអើយចាំបាត់ ឱ្យណាថ្ងៃអើយ នាងអើយចាំបាត់ ចាំទាំងយប់ងងឹតមិនឃើញនាងអូនមក ចាំទាំងយប់ងងឹតមិនឃើញនាងអូនមក បាត់ស្រស់ពន្លកកែវអើយ មកជួបនឹងបង ឱរណា ឱរណា ណាយអើយ។ បាត់ស្រស់ពន្លកថ្ងៃអើយ មកជួបនឹងបង ធើស ធើស គ្រោ ធាក់ ហើស ហើស។

៣. យប់អធ្រាត្រឆ្ងង ចាំបងសិនថ្ងៃអើយ អូណា អូរណោអើយ ឱណា ណាយអើយណាយអើយ ចាំយប់ងងឹត ថ្ងៃអើយចាំបងសិនថ្ងៃ ចាំតាំងពីព្រឹក នាងអើយរហូតដល់ថ្ងៃ ចាំតាំងពីព្រឹក នាងអើយរហូតដល់ថ្ងៃចាំអូន នាងថ្ងៃ នាងអើយមិនឃើញឱ្យនាងឡើងរាំ កេអើយ ហ្អើយ គ្រោ ធើស ធើស ធើត ធើត អរអើយ ណាយ អើយ ណាយអើយ ឱ្យណាមុំហ្អើយ ថ្ងៃអើយណាយអើយ ឡើងរាំ ឱ្យណាណាយអើយ កែវហ្អើយ ណាយ អើយឡើងរាំ គ្រោ ហឺ គ្រោ។

គ្រាំង

១. ឱ ទូកទៅ អើយ អើយ ឱ ណាអូនហ្អើយ ឱណា ណា ឱ ទូកទៅអើយ ព្រលឹងកែវ អើយ ទូកហ្អើយ ឱ ទូកត្នោត អឺ អើយ ព្រលឹងកែវ អើយ បងអុំដឹក ឱ ស្រីស្ងួន គ្រោ អើយ ឱណា ណា ហ្អើយ។

២. អូនហ្អើយ អើយ ព្រលឹងកែវ ហ្អើយ បងដឹកដឹក ឱ ស្រីស្ងួន អើយ ឱណា ហ្អើយ អញ្ជើញស្រី អើយ ឱណា អូនហ្អើយ ស្រីខ្មៅ ហ្អើយ ឱ សំពោង អើយ ឱណា អូនហ្អើយ ស្រីខ្មៅ ហ្អើយ ឱ សំពោង អឺ អើយ ដល់ចេញពីពោង មកជួយ ហ្អើយ ឱ ខ្ញុំផង អើយ គ្រោ គ្រោ...យើស។

៣. នាង អឺ អើយ ឱ ធាប់ប៉ា អើយ ហា អឺ អើយ ឱណា ណា ឱ ធាប់ប៉ា ព្រលឹងកែវហ្អើយ ស្រី ហ្អើយ សថ្ងោស ហ្អើយ នាងចេញពីក្នុង មកជួយ ហ្អើយ ឱ វង់ខ្ញុំ អើយ ឱណា ណា ណា កែវអើយ ហា អឺ អើយ ឱណា ណា ឱ កែវបង អើយ ឱណា អូនហ្អើយ។

៤. ស្រអែម ហ្អើយ ឱ ខ្មៅស្រស់ អឺ អើយ ព្រលឹងកែវ អើយ អូនដើរ ហ្អើយ ឱ ទៅណា អើយ ឱណា ដើរ ឱ ទៅណា អើយ ព្រលឹងកែវហ្អើយ ដៃឆ្វេង ហ្អើយ ឱបួងសួង។

ឡាំ

១. អើយ ហីហ្អើយ ឱអើយ ឱគ្រូធំ ស្រីតូចក្រមុំ ឱ នៅភ្នំគូលែន អើយ ហាហ្អើយ អើយ ឱណាអូនអើយ កាត្រែតត្រែតហ្អើយ អូនអើយ ត្រែតស្រី លើកដៃបួងសួងដល់អស់ ឱបារមី ឱណាអូនអើយ ស្រីអើយ អើយ ហាហ្អើយ បារមី ឱ សណ្ឋិត មានគ្រូពិតៗ លោកអើយ ឱ ប្រោះព្រំ គ្រូតូចគ្រូធំ បារមី ខ្ញុំអឺផង។ គ្រោ យើស យើស

២. ហាហ្អើយ អើយ ហ្អើយ អើយ ឱណាកែវអើយកែវ អើយកែវកើច ឱណាកែវអើយ កែវអើយ កែវកើច បងលួងឱសើច អូនអើយ ឱដើងធ្មេញ បងលួងស្រីសើច ថ្ងៃអើយ ឱ ធ្វើដើងធ្មេញ គន់មើលដើងសក់រត់ជួរ ឱ រមិញ ដើងសក់រត់ជួរ ឱ រមិញ ដើងធ្មេញល្អ ហើយឱសមផង។ គ្រោ យើស យើស យើស។

៣. ហាហ្អើយ អើយ ហ្អើយ អើយ ឱ ណាអូនអើយ គន់មើល ឱដើងសក់ ឱណាថ្ងៃអើយ ដូចសក់ឱសារិកា ឱណាអូនអើយ ដូចសក់ឱសារិកា ហ្អើយ អើយ ហ្អើយ អើយ ឱណាអូនអើយ ឱសារិកា ខ្ញុំបង្ខុំហើយណាទេព្តា ឱជួយផង ទេព្តាអូនអើយ ឱ ជួយផង។ គ្រោ យើស យើស

៤. ហ្អើយ អើយ ហ្អើយ អើយ ហាហ្អើយ អើយ ឱ ណាថ្ងៃអើយ សក់វែងឱប្រះខ្នង ឱណាសក់ក្រង សក់ឱកន្ទុយ ឱណាអូនអើយ ស្រីអើយ ឱកន្ទុយ ហ្អើយ អើយ ហ្អើយ អើយ ឱស្រីល្អអើយ ឱណាអូនអើយ សក់វែងអើយ ហាយឡាយ គន់មើលទៅឆ្ងាយស្រីល្អ ឱពេកពន់ ឱណាស្រីទន់ ស្រីទន់ ឱល្វន់ដើរ។

កន្ទ្រប់

១. ហាអើយ អឺយ កន្ទ្រប់ ត្រប់ហ្អើយ អីយ៉ាស់កប់ក្នុងក្អក់ចំបើង អីនែកប់ក្នុងក្អក់ចំបើង យកដៃទៅប៉ើង ឱណាអីនែកំពប់ចានជ្រក់ (សម្លេងបន្ទរ អឺយ) កំពប់ចានជ្រក់។

២. ហី កន្ទ្រប់ ត្រប់ហ្អើយ អីយ៉ាស់កប់ក្នុងក្អក់ភ្លើង អីនែកន្ទ្រប់ កប់ក្នុងក្អក់ភ្លើង យកដៃគ្គឹះឡើង ឱវាផ្ទារឡើងកន្ទ្រេត ឱផ្ទារកន្ទ្រេត។

៣. អឺយ អើយ កន្ទ្រប់បងមួយ អីនែ បងព្រួយរក្សា កន្ទ្រប់បងមួយ អូនហ្អើយ បងព្រួយរក្សា ដល់ខែហើយណា អីយ៉ាស់ចាប់កន្ទ្រប់អាំងស៊ី អឺយ អើយ។

៤. អឺយ អើយ កន្ទ្រប់ ត្រប់អើយ អីយ៉ាស់កប់ស្ទឹករមៀត យកដៃទៅសៀត អូនអឺយ កន្ទ្រប់ខ្មាស់គេ កន្ទ្រប់តូចៗ អីយ៉ាស់ វាមិនល្មមទេ ខ្លាចលោខ្មាសគេ អីយ៉ាស់ខ្លាចប៉ះកន្ទ្រប់ស្រី កន្ទ្រប់ស្រី។ (សម្លេងបន្ទរ គ្រូ....)

៥. នែអូនហ្អើយ នែដង្កៀតក្បែរកន្ទ្រប់ កង្កែបកូបហ្អើយ អីយ៉ាស់កង្កែបកូបអាំង គេអាំងខែប្រាំងអីយ៉ាស់រដូវវស្សា ខែប្រាំងអូនហ្អើយ ដល់ខែវស្សា ឱ អាំងខែណាថ្ងៃហ្អើយ ក៏កង្កែបឈ្មុយម៉្វេះ ឈ្មុយម៉្វេះ អីនែអូនហ្អើយ កង្កែបអាំង អីយ៉ាស់សកវាអូនហ្អើយ ថ្ងៃអើយ សកវាកង្កែបអាំង យកដៃទៅបាំង ថ្ងៃអើយកង្កែបអើយបះជើង ហ្អើយបះជើង

៦. កណ្តូបដូបអើយ ថ្ងៃហ្អើយ កណ្តូបស្រួយមួយ អីនែកណ្តូប ដូបហ្អើយ ថ្ងៃអើយ កណ្តូបស្រួយមួយយកដៃកុំព្រួយ អូនហ្អើយ បងជួយណានាង ត្រីកញ្ចុះនាងហ្អើយ ជញ្ជាត់អីហ្នឹងឈ្នាង អីយ៉ាស់ត្រីកញ្ចុះនាងហ្អើយបងជាត់អីហ្នឹងឈ្នាង ស្រណោះ ឱ ខ្លួននាង អីយ៉ាស់រៀសរៀងឱពេញទ្រូ។

ផ្កា

១. អី ហា អី ហា អើយ អី ហា អី ហា អើយនែអូនហ្អើយ នែអូនហ្អើយ ស្រីហ្អើយ ស្រីពៅ ស្រីហ្អើយ ឱ ស្រីពៅពាក់អាវក្រហមឆ្នៅ សំពត់ ឱ បៃតង ពាក់អាវក្រហមឆ្នៅសំពត់ ឱ បៃតង។

២. អី ហា អី ហា អីង អើយ អី ហា អីង អើយ ពាលហ្អើយ ពាលពៅ ទៅណា ឱ នួនល្អងពាលអើយ ពាលពៅទៅណា ឱ នួនល្អង ស្មៀកពាក់បៃតង បង់ ឱ ក្រមា។

៣. ហា អី អីង អើយឱ ណាអូន អើយ ហៃ សក្រវា ថ្ងៃ ហ្អើយ ហី ផ្កាក្រវាន់ថ្ងៃ ហ្អើយ ឱ ផ្កាក្រវាន់ បងសុំកាច់កាន់ បានទេ ឱ ពុំងា។

៤. ហា អី អីង អើយ ឱណា អូនហ្អើយ បង នៃ រងាកំព្រា ឱ ខ្វះគូរ ដល់ខែរងាកំព្រា ឱ ខ្វះគូកុំនៅយូរៗ អូនហ្អើយ ថាបងផង។

៥. អឺ ហា អឺង អើយ អឺ..អឺង អើយ ហា អឺង អើយ យ៉ង ហ្អើយ ស្រីយ៉ង យ៉ង ហ្អើយ ឱ ស្រីយ៉ងទៅណា ទៅផង បានទេ ឱ ពុំង៉ា ហា អឺង អើយ អឺ..អឺង អើយ ហា អឺង អើយឱ ណាអូន អើយ បងសុំទៅផង បានទេ ឱ នួនល្អង ចែកបងទៅផង ព្រោះបង ឱ កំព្រា។

៦. អឺ ហា អឺង អើយ អឺ..អឺង អើយ ឱនៃ នៃ ឱ ស្រីនួន ឱណា នួនហ្អើយ នួនហ្អើយ ស្រីនួន ឱ សមនួន ឱ ណា ស្រីនួន ស្រីនួន ឱ ល្អអនេក គាប់ភ្នែក គាប់ភ្នែក ឱ ស្រីមាសបង យើស យើស យើស។

ផ្កាក្រង

១. អើយ ផ្កាក្រង អឺ ផ្កា ផ្កាអើយ ផ្កាក្រង ផ្កាដុះ ផ្កាដុះក្នុងរបង ធ្វើម្ដេច ឱបងបានថើប ផ្កាដុះក្នុងរបង ធ្វើម្ដេច ឱ បងបានថើបផ្កា អើយ ផ្ការសើប ហា អឺង អើយ ផ្កា អើយ ផ្ការសើប ផ្កាអើយ អើយ ផ្ការសើប ហា អឺង អើយ ផ្កា អើយ ផ្ការសើប ធ្វើម្ដេច ធ្វើម្ដេចបានថើប ផ្កាអូន ឱនៅឆ្ងាយ ធ្វើម្ដេចបានថើប ផ្កាអូន ឱនៅឆ្ងាយ។

២. បងសុំ លោកឪពុក អឺង អើយ ទៅដល់ អ្នកម្ដាយគ្រា គ្រា បងសុំ លោកឪពុក អឺង អើយ ទៅដល់ លោកម្ដាយ ផ្កាអូន ផ្កាអូននៅឆ្ងាយ ថ្ងៃហ្អើយ បងឈោងពុំដល់ ផ្កាអូន ផ្កាអូន បើនៅឆ្ងាយ បងឈោង ឱ ពុំដល់។

៣. បងផ្ដាំតាមទឹក អឺង អើយ ទឹកហូរមិនដល់ បងផ្ដាំតាមទឹក អឺង អើយ ទឹកហូរមិនដល់ បងផ្ដាំ បងផ្ដាំ ឱ តាមខ្យល់ ឱ្យខ្យល់ ឱ្យជួយប្រាប់ បងផ្ដាំ បងផ្ដាំ ឱ តាមខ្យល់ ពៅហ្អើយ ឱ្យខ្យល់ជួយប្រាប់។

៤. ស្រណោះខែប្រាំង អឺង អើយ ស្រណោះខែប្រាំង ស្រណោះខែប្រាំង អឺង អើយ បងស្រណោះខែប្រាំង ខែរាំងពោយទឹកខ្លាំង បងផ្ដាំ ឱពុំបាន ខែរាំងអើយពោយទឹកខ្លាំង បងផ្ដាំ មិនបាន គ្រា គ្រា ធើស ធើស។

៥. ផ្កា អើយ លូកទៅ អឺង អើយ ទងផ្ការបេះ បងលូកដៃទៅ អឺង អើយ ខ្លាចផ្ការបេះ ផ្កាដុះ ផ្កាដុះឆ្ងាយ យ៉ាងនេះ ធ្វើម្ដេច ឱ បានទៅផ្កាដុះឆ្ងាយយ៉ាងនេះ ធ្វើម្ដេច បងបានយកទៅ។

៦. ផ្កាអូនទំនេរ ហា អឺង អើយ មានគេចែចូវ ផ្កាអូនទំនេរ ហា អឺង អើយ មានគេចែចូវ បងលូក បងលូក ឱដៃទៅ ពៅអើយ រសាត់អឺឆ្ងាយ បងលូក បងលូកដៃទៅ ផ្កាអើយ ឱរសាត់ទៅឆ្ងាយ។

កាត់ស្ទឹក

១. បងទៅកាត់ស្ទឹក ក្រមុំបងហ្អើយ បងចេញ ទៅកាត់ហ្លាស្ទឹក រៀបបាយ រៀបទឹក ក្រមុំបង ហ្អើយ ឱ្យបងរៀបបាយ រៀបទឹក ក្រមុំបងហ្អើយ ទុកឱ្យបង បងទៅហ្អើយ ពីព្រឹក អើយ ក្រមុំបងហ្អើយ រៀបទឹកបំពង់អើយបងទៅហ្អើយ ពីព្រឹកអើយ ក្រមុំបងហ្អើយ រៀបបាយ បំពង់ ម្ជូស្លាបារី ឱ ណាអូនហ្អើយ វេចដាយហ្អើយ ក្រមា ម្ជូស្លាបារី ក្រមុំបងហ្អើយ វេចដាយហ្អើយ ក្រមា មានទាំង ហ្អើយ ម្ជូស្លា ក្រមុំបង ហ្អើយ រៀបបាច់ឱស្រេច មានទាំងបារីម្ជូស្លា ក្រមុំបង ហ្អើយ រៀបអស់ឱស្រេច បងចេញទើបលិចហ្អើយ ក្រមុំបង ហ្អើយ កាត់ស្ទឹកជូនស្រី អូនអើយកុំភ្លេច ក្រមុំបង ហ្អើយ កាត់ស្ទឹកមកឱ្យស្រី។

២. ថ្ងៃត្រង់ ហ្អើយ ក្រលួច អើយ ក្រមុំបង ហ្អើយ ត្រូវស្នេហ៍អូនស្រី ថ្ងៃត្រង់ ហ្អើយ ក្រលួច អើយ ក្រមុំបង ហ្អើយ ត្រូវស្នេហ៍អូនស្រី កាត់ស្លឹក ហ្អើ ជូនស្រី ក្រមុំបង ហ្អើយ បងទៅមិនរួច យកស្លឹក ហ្អើយ ឱ្យស្រី ក្រមុំបង ហ្អើយ បងទៅ ហ្អើយ....មិនរួច។

៣. ត្រូវទាំង ហ្អើយ កន្ទេលដេក ក្រមុំបង ហ្អើយ ត្រូវនៃ ទាំងខ្នើយ ត្រូវទាំង ហ្អើយ កន្ទេលដេក ក្រមុំបង ហ្អើយ ត្រូវទាំងកន្ទេលខ្នើយ ត្រូវស្នេហ៍ស្រីហើយ ឱណាអូន ហ្អើយ ដកចិត្ត ហ្អើយ មិនបាន ត្រូវស្នេហ៍អូន ហើយ ណាកែវ ហ្អើយ ដកស្នេហ៍មិនបាន គ្រោ គ្រោ យើស។

គ. ក្លុមិក្លង់

ល.រ	បទ	លេងពេល
១	ភ្លាវ៉ា	លេងក្មេងការ, ប្រគំគ្រូ, មេមត់រាំ
២	ម្លប់ដូង	មេមត់រាំ
៣	ដើតមន	ថ្វាយអ្នកតា, មេមត់រាំ
៤	អុំទូក	មេមត់រាំ
៥	មេមត់ចូលហើយ	ថ្វាយអ្នកតា, ដេញព្រាយវាយច្រូង, មេមត់រាំ
៦	ទាក់ដំរី	មេមត់រាំ
៧ *	ប្រដាល់	មេមត់រាំ (បទនេះពុំមានទំនុកទេ)
៨	ល្ងិន	លេងក្មេងការ, ប្រគំគ្រូ, មេមត់រាំ
៩	ស្ទើរ	លេងក្មេងការ, ប្រគំគ្រូ, មេមត់រាំ
១០	ភ្លាំង	មេមត់រាំ
១១	ស្រឡាញ់ស្រីខ្មៅ	មេមត់រាំ, សាពិតាន
១២	កញ្ចាញ់ចេក	មេមត់រាំ
១៣	ស្វាយចន្ទី	មេមត់រាំ
១៤	លើកដៃប្រណម្យ	មេមត់រាំ

ក្អាវក់

១. ហីអេអើយ ជន្ទង់ហ្ហើយខ្ញុំលុតអេអើយ ជន្ទង់ហ្ហើយខ្ញុំលុត លោកហ្ហើយ អីនៃហត្ថខ្ញុំអើយប្រណម្យអើយ ឱណាហ្ហើយប្រណម្យអើយ។

២. អេអើយ អញ្ជើញហ្ហើយគ្រូតូចអើយ អញ្ជើញគ្រូតូច ឱណាលោកហ្ហើយ ហីនៃអញ្ជើញហ្ហើយគ្រូធំអើយ អញ្ជើញលោកគ្រូស្តោះផ្ទុំអើយ ឱណាលោកហ្ហើយ មកជួយហ្ហើយប្រោះព្រំ ឱណាគ្រូហ្ហើយ ថ្ងៃហ្ហើយ ឱណាលោកហ្ហើយ មកជួយអើយប្រោះព្រំអើយ ឱណាប្រោះព្រំអើយ។

៣. អេអើយ ជួយវង់ហ្ហើយយើងខ្ញុំអើយ ជួយវង់ហ្ហើយយើងខ្ញុំហ្អា ឱណាគ្រូហ្ហើយ អីនៃសុំសុខអើយ សប្បាយ សុំសុខហ្ហើយសប្បាយ។

៤. អេអើយ សត្រូវហ្ហើយជិតឆ្ងាយអើយ សត្រូវហ្ហើយជិតឆ្ងាយ ឱណាលោកហ្ហើយ អីនៃជៀសចេញហ្ហើយ បានឆ្ងាយ ឱ្យគ្រូហ្ហើយអើយជួយ ឱណានៃណាប្រោះព្រំហ្អា ឱណាគ្រូហ្ហើយ ថ្ងៃហ្ហើយ ឱណាគ្រូហ្ហើយ លោកជួយហ្ហើយប្រោះព្រំអើយ លោកជួយហ្ហើយប្រោះព្រំអើយ។

៦. អេអើយ អញ្ជើញស្រីខ្មៅអើយ អញ្ជើញស្រីខ្មៅហ្ហើយ ឱណាថ្ងៃហ្ហើយ អីនៃមកឡកហ្អាលេងអើយ ឱណាឡកលេងអើយ។

៧. អេអើយ សម្លេងហ្ហើយស្គរឡើងអើយ សម្លេងហ្ហើយស្គរឡើង ឱណាថ្ងៃហ្ហើយ ឱនៃអញ្ជើញហ្ហើយស្រីខ្មៅ អើយ អូនហ្ហើយ ឱណាថ្ងៃហ្ហើយមករាំហ្ហើយឡកលេង ឱណាថ្ងៃហ្ហើយ ថ្ងៃហ្ហើយ ឱណាអូនហ្ហើយ មករាំ ហ្ហើយឡកលេងអើយ មករាំហ្ហើយឡកលេង។

ម្ញប់ដូង

១. ឱម្ញប់ហ្ហើយដូងហ្ហើយ ឱណាថ្ងៃហ្ហើយ ដែលបងធ្លាប់ជ្រកអើយ ម្ញប់ហ្ហើយដូងហ្ហើយ ឱណាថ្ងៃហ្ហើយ ដែលបងធ្លាប់ជ្រកអើយ តាំងពីហ្ហើយឱកើតមក ឱណាថ្ងៃហ្ហើយរកគូប្រលែងអេអើយ សាពាវ៉ាន់កែវហ្ហើយ ឱណាថ្ងៃហ្ហើយ រកគូប្រលែង (យើស)។

២. សង្វារបងមួយហ្ហើយ ឱណាថ្ងៃហ្ហើយ សង្វារកម្សត់អេអើយ (យើស) សង្វារបងមួយហ្ហើយ ឱណាថ្ងៃ ហ្ហើយ សង្វារកម្សត់អេអើយ (យើស) កាលបងនាំអូនស្រីរត់ ឱណាថ្ងៃហ្ហើយ កាត់វាលហ្ហើយសែនឆ្ងាយ អើយ សាពាវ៉ាន់កែវអើយ ឱណាថ្ងៃហ្ហើយ កាត់វាលហ្ហើយសែនឆ្ងាយ។
(គ្រោ ហ៊ិច ហ៊ិច ហ៊ិច ហ៊ិច គ្រោ អើយមកណាលោកគ្រូ យើស គ្រោ ហ៊ិច ហ៊ិច)

៣. មុំហ្ហើយស្រីមុំហ្ហើយ ឱណាថ្ងៃហ្ហើយ មុំហ្ហើយស្រីមុំអើយ មុំហ្ហើយស្រីមុំហ្ហើយ ឱណាថ្ងៃហ្ហើយ មុំហ្ហើយ ស្រីមុំអើយ ថ្ពាល់ដូចហ្ហើយឱត្រឡបហ្ហើយ ឱណាថ្ងៃហ្ហើយដៃមុំហ្ហើយ លាយលក្ខ័អើយ សាពាវ៉ាន់កែវហ្ហើយ ឱណាថ្ងៃហ្ហើយដៃមុំហ្អាលាយ...លក្ខ័។

៤. បាតដៃហ្អើយខ្នងដៃ ឱណាថ្ងៃហ្អើយ ត្រដុំហ្អើយត្រដាក់អើយ បាតដៃខ្នងដៃ ឱណាថ្ងៃហ្អើយ ត្រដុំហ្អើយត្រដាក់អើយ ដៃមុំអូនឱលាយលក្ខណ៍ហ្អើយ ឱណាថ្ងៃហ្អើយដាក់លើទ្រូងបងហ្អេ សាពវ៉ាន់កែវហ្អើយ ឱណាថ្ងៃហ្អើយ ដាក់លើហ្អើទ្រូងបង។ (គ្រោ ហ៊ឺច..ហ៊ឺច ឆឹច អើយ..គ្រោ..គ្រោ..អើយមកណា...)

៥. បងរុកហ្អើយឱព្រៃប្រោក ឱណាថ្ងៃហ្អើយ ឮសត្វហ្អើយទោចយំអេអើយ បងរុកហ្អើយឱព្រៃប្រោក ឱណាថ្ងៃហ្អើយ ឮសត្វហ្អើយទោចយំអេអើយ បងរុកហ្អើយឱព្រៃភ្នំ ឱណាថ្ងៃហ្អើយ ឃើញទោចត្បាញដាលអេអើយ សាពវ៉ាន់កែវហ្អើយ ឱណាថ្ងៃហ្អើយ ឃើញទោចត្បាញដាលអើយ។
(គ្រោ វ៉ិច)

៦. អាមួយហ្អើយបោចវល្លិ៍ ឱណាថ្ងៃហ្អើយ អាមួយហ្អើយបោចព្រាលអេអើយ អាមួយបោចវល្លិ៍ ឱណាថ្ងៃហ្អើយ អាមួយបកព្រាលអើយ ឃើញទោចឱត្បាញដាល ឱណាថ្ងៃហ្អើយបេះផ្លែសាវម៉ាវអេអើយ សាពវ៉ាន់កែវហ្អើយ ឱណាថ្ងៃហ្អើយបេះផ្លែសាវម៉ាវ។

ដើតមង

គ្រោ..គ្រោ..ហ៊ើយ..មកណា......
១. អេអើយ ហៃអេអឺអើយ នៃសង្សារបងមួយហ្អើយ ឱណាថ្ងៃហ្អើយ អីនៃសង្សារកម្សត់អើយ ឱសាពវ៉ាន់ហ្អើយកែវហ្អើយ ឱណាថ្ងៃហ្អើយ អីនៃសង្សារកំសត់អើយ កាលបងនាំហ្អើយស្រីរត់អើយ ឱណាថ្ងៃអើយ អីនៃកាត់ព្រៃសែនឆ្ងាយ (យើស) កាត់វាលហ្អើយសែន...ឆ្ងាយ។

២. អេអើយ ហៃអេអឺអើយ (យើស) នៃស្ពាយហ្អើយសែនស្ពាយ ឱណាថ្ងៃហ្អើយ អីនៃស្ពាយចេកហ្អើយទួនក្វាយ ឱសាពវ៉ាន់ហ្អើយកែវហ្អើយ ឱណាថ្ងៃហ្អើយ អីនៃស្ពាយចេកហ្អើយទួនក្វាយ ស្ពាយចេកហ្អើយទួនក្វាយ ឱណាថ្ងៃហ្អើយ អីនៃស្រគាលហ្អើយទុំដើម ស្រគៀលហ្អើយទុំដើម។
(យើស គ្រោ...........លោកគ្រូ..ហ៊ុច..ហ៊ីច គ្រោ អេហឹម គ្រោ ហ៊ិច)

៣. អេអើយ ហៃអេអឺអើយ (យើស) បងដើរឆ្ពងព្រែក ឱណាថ្ងៃហ្អើយ អីនៃឮខ្វែងវាយំហ្អេ ឱសាពវ៉ាន់ហ្អើយកែវហ្អើយ ឱណាថ្ងៃហ្អើយ អីនៃឮខ្វែងវាយំហ្អេ អីនៃបងដើរឆ្ពងភ្នំហ្អើយ ឱណាថ្ងៃហ្អើយ អីនៃឃើញឃ្មុំហ្អើយយកផ្កាហ្អេ ឃើញឃ្មុំហ្អើយយកផ្កាហ្អេ។

៤. អេអើយ ហៃអេអឺអើយ អីនៃយកទាំងហ្អើយខែប្រាំង សង្សារបងអើយ អីនៃដល់ខែវស្សា ឱសាពវ៉ាន់ហ្អើយកែវហ្អើយ ឱណាថ្ងៃហ្អើយ អីនៃដល់ខែវស្សា..អីនៃឃើញឃ្មុំហ្អើយយកផ្កា ឱណាថ្ងៃហ្អើយ អីនៃបំពេញហ្អើយក្បាលទឹកហ្អេ បំពេញហ្អើយក្បាលទឹក។
(គ្រោ ហ៊ិច ហ៊ិច)

អុំទូក

១. ហ្អើយបង់អុំហ្អើយទូកទៅហ្អើយ ឱណាថ្ងៃហ្អើយទៅវែងហ្អើយអង្កាំហ្អេ ហ្អើយបង់អុំហ្អើយទូកទៅឆ្ងាយ ឱណាថ្ងៃហ្អើយ បង់រហ័សមកវិញ ដើណា ដើណា ថ្ងៃណា សារវ៉ាន់កែវហើយបង់មកវិញ។

២. អីនែរសៀលហ្អើយជ្រៀលជ្រែកហ្អើយ ក្រមុំអូនហ្អើយសូរិយាគង់ភ្នំអើយ រសៀលហ្អើយជ្រៀលជ្រែក ហ្អើយ ក្រមុំអូនហ្អើយសូរិយាគង់ភ្នំហ្អេ បង់ឮហ្អើយបង់ឮហ្អើយវៃយំ ឱណាថ្ងៃហ្អើយ វៃយំហ្អើយក្រលួច ដើណា ដើណា ថ្ងៃណា ក្រមុំអូនហ្អើយវៃយំហ្អើយ.......ក្រលួច។
(គ្រោ អឺ ហ៊ឹប អើយមកណា)។

៣. ហ្អើយបង់អុំហ្អើយទូកទៅហ្អើយ ក្រមុំអូនហ្អើយទៅច្រូតស្រងែ ហ្អើយបង់អុំហ្អើយទូកទៅហ្អើយ ក្រមុំអូន ហ្អើយទៅច្រូតស្រងែ រនោចហ្អើយដើមខែ ណាថ្ងៃហ្អើយបង់វិលមកវិញ ដើណា ដើណា ថ្ងៃណា ក្រមុំអូន ហ្អើយបង់វិលមកវិញ។

៤. អីនែតូចហ្អើយស្រីតូចហ្អើយ ក្រមុំអូនហ្អើយ តូចហ្អើយស្រីតូច តូចហ្អើយស្រីតូចហ្អើយ ក្រមុំអូនហ្អើយ តូចហ្អើយស្រីតូច បង់សុំហ្អើយទទួចហ្អើយ ឱណាថ្ងៃហ្អើយតូចចេះថ្នមប្ដី ដើណា ដើណា ថ្ងៃណា ក្រមុំអូន ហ្អើយ តូចចេះហ្អើយថ្នមប្ដី។
(ធីប គ្រោ ហិច គ្រោ)

៥. បង់អុំហ្អើយទូកត្នោត ក្រមុំអូនហ្អើយទៅច្រូតស្រងែ ឱនែបង់អុំហ្អើយទូកត្នោត ក្រមុំអូនហ្អើយទៅច្រូត ស្រងែ ភ្លៀងធ្លាក់ហ្អើយភ្លៀងធ្លាក់ហ្អើយខុសខែ ឱណាថ្ងៃហ្អើយស្រងែបែកគុម្ព ភ្លៀងធ្លាក់ហ្អើយខុសខែ ឱណាថ្ងៃហ្អើយស្រងែបែកគុម្ព។

មេមត់ចូលហើយ

១. អេអឺអើយ អឺអឹងអើយ សារិកាកែវហ្អើយ មុំហ្អើយថាសារិកាកែវកើច ឱណានាងណា មុំហ្អើយថាសារិកា កែវកើច បង់លួងឱ្យសើច មុំហ្អើយមេចបានស្រែកយំអើយ ឱណាកែវហ្អើយណានាងម៉េចបានស្រែកយំ។

២. អេអឹងអើយ អឺអឹងអើយ សារិកាកែវហ្អើយ មុំហ្អើយស៊ីអីកង់ៗ ឱណានាងណា មុំហ្អើយស៊ីអីកង់ៗ ស៊ីផ្លែ បាក់ដង់..ក្រមុំហ្អើយថាវាចឹកគ្នាលេង ឱណាកែវហ្អើយ ណានាងវាចឹកគ្នាលេង។
(ហ៊ិច ៗៗៗៗ យេ)

៣. អេអើយ អឺអឹងអើយ ស្វាបវាចាក់ក្បាច់ មុំហ្អើយមាត់វាធ្វើភ្លេង សារិកាកែវហ្អើយ ណានាងមាត់វាធ្វើភ្លេង ឱវាចឹកគ្នាលេងមុំហ្អើយក្នុងព្រៃព្រឹក្សា។
(ហ៊ិច ៗៗ យឺ គ្រោ យឺ ៗៗៗៗ ឈោះ ៗៗៗៗ)

៤. អេអើយ អឺអឹងអើយ មុំហ្អើយស្រីមុំ ណានាងមុំហ្អើយស្រីមុំ សារិកាកែវហ្អើយ ណានាងមុំហ្អើយស្រីមុំ ថ្ពាល់ដូចត្រប់ទុំ មុំហ្អើយដៃអូនញ័រញាក់ហ្អើយ ឱណាកែវហ្អើយណានាងដៃអូនញ័រញាក់អើយ។
(គ្រោ ហ្អេ ហឺស យីស យីស)

៥. អឹងអើយ អឺអឹងអើយ បាតដៃខ្នងដៃ ក្រមុំហ្អើយថាត្រជុំត្រជាក់ សារិកាកែវហ្អើយ ណានាងថាត្រជុំត្រជាក់ បាតដៃលាយលក្ខណ៍ មុំហ្អើយដាក់លើទ្រូងបង ណានាងដាក់លើទ្រូង.......បង។
(យឺ ៗៗៗៗ ឈោះ ៗៗៗៗ ហ៊ុច ៗៗ)

៦. អេអឺអើយ អឺអឹងអើយ សារិកាកែវហ្អើយ មុំអើយសារិកាកែវកើច ឱណានាងណា មុំហ្អើយសារិកាកែវកើច បងលួងឱ្យសើច មុំអើយម៉េចបានអូនយំ ណានាងម៉េចបានអូនយំ។

នាក់ដំរី

១. អីនែ លឡេឡេហ្អើយ លីស្នាទៅបាញ់ត្រយង (ធើស) អើយឱត្រយង ថ្ងៃហ្អើយត្រយង អូនហ្អើយនាងដេកផេះ (គ្រោ) ស្នាបាក់អើយនឹងត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះ។

២. លឡេឡេហ្អើយអើយ លីស្នាអឺទៅបាញ់ត្រយង អីនែលឡេឡេហ្អើយអើយ លីស្នាអឺទៅបាញ់ត្រយងស្នាបាក់ហ្អើយនឹងត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះ ស្នាបាក់ហ្អើយនឹងត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយដេកផេះ.......ដេកផេះ

៣. [អីនែ លឡេឡេ] ហ្អើយអើយ លីស្នាអឺទៅបាញ់ត្រយង អីនែលឡេឡេហ្អើយ លីស្នាអឺទៅបាញ់ត្រយងស្នាបាក់អើយនឹងត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះ ស្នាបាក់អើយឱត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះ នាងដេកផេះ (គ្រោ តោះ តោះ តោះ តោះ តោះ គ្រោ)

៤. [អីនែ] លឡេឡេហ្អើយអើយ លីស្នាទៅបាញ់ត្រយង អីនែលឡេឡេហ្អើយ លីស្នាអឺទៅបាញ់ត្រយងស្នាបាក់អើយនឹងត្រយង ថ្ងៃហ្អើយត្រយង អូនហ្អើយនាងដេកផេះ ស្នាបាក់ហ្អើយឱត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះនាងដេកផេះ

៥. លឡេឡេហ្អើយ លីស្នាអើយទៅបាញ់ត្រយង (គ្រោ) អីនែលឡេឡេហ្អើយ លីស្នាអឺទៅបាញ់ត្រយងស្នាបាក់អើយនឹងត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះ ស្នាបាក់អើយនឹងត្រយង ថ្ងៃហ្អើយត្រយងអូនហ្អើយនាងដេកផេះ។

ល្ងិន

១. ហឺអេ ហឺនៃពេលយប់ហ្អើយត្រជាក់ ណាពេលយប់ហ្អើយត្រជាក់ ឱណាអូនហ្អើយ ស្រណោះពេលយប់ហឺត្រជាក់ ឱណាពេលយប់អូនហ្អើយត្រជាក់។
(ហ៊ិច ហ៊ិច)

២. អេ អឺនៃលើកត្បាញទៅពាក់ លើកត្បាញទៅពាក់ ឱណាថ្ងៃហ្អើយ អឺនៃសញ្ចប់ហ្អើយលើគី អឺនៃដើផដាន់ហ្អើយឈើឈ្នាន់អើយ ឱណាអូនហ្អើយ ដៃកាន់មកត្រល់ថ្មី សញ្ចប់អូនហ្អើយលើគី ថ្ងៃហ្អើយឱណាអូនហ្អើយ ស្ដាប់ផ្គរហ្អើយឆ្លើយគ្នាអើយ ស្ដាប់ផ្គរហ្អើយឆ្លើយគ្នាអើយ។
(ហ៊ិច ហ៊ិច ហឹប)

៣. អេអើយ ផ្គរមួយហ្អើយឆ្លើយផ្កាំអេអើយ ផ្គរមួយហ្អើយឆ្លើយផ្កាំសង្វារបងហ្អើយ ហឺនៃផ្គរពីរហ្អើយឆ្លើយលាអើយ (អើយ...កូនហ្អើយ ឡើងមកណាកូន) ផ្គរពីរហ្អើយឆ្លើយលាអើយ។
(ហ៊ិច ហ៊ិច)

៤. អេអើយ លាស្រស់ហ្អើយពុំផាអេអើយ (អឺ ណាកូន នៃឡើងមកដាំបាយកូន) លាស្រស់ហ្អើយពុំផា ឱណាអូនហ្អើយ អឺនៃលាអូនហ្អើយទៅស្រុកអើយ (ហ្អេស គ្រោ) ទៅសួរហ្អើយសុខទុក្ខអេអើយ ថ្ងៃហ្អើយលោកឪពុកហ្អើយអ្នកម្ដាយ ឱណាអូនហ្អើយ ថ្ងៃហ្អើយឱណាអូនហ្អើយ លោកឪពុកហ្អើយអ្នកម្ដាយ លោកឪពុកហ្អើយអ្នកម្ដាយ។
(......... អឺ ឡើងមកកូន)

៥. អេអើយ ស្ដាយហ្អើយសែនស្ដាយអើយ (អេ ហ្អេស) ស្ដាយហ្អើយសែនណាស្ដាយ ឱណាអូនហ្អើយ ហឺនៃស្ដាយចេកហ្អើយទួនក្វាយអើយ ឱណាទួនក្វាយ។
(គ្រោ ហ៊ិច ហ៊ិច)

៦. អេអើយ ស្ដាយចេកហ្អើយទួនក្វាយ ស្ដាយចេកហ្អើយទួនក្វាយ ឱណាថ្ងៃហ្អើយ អឺនៃស្រគាលហ្អើយទុំដើមបងនឹកហ្អើយអូនពេកអើយ ថ្ងៃហ្អើយស្ទើរដាច់ហ្អើយដង្ហើម ស្រគាលហ្អើយទុំដើម អូនហ្អើយ ឱណាថ្ងៃហ្អើយអ្នកណាបេះបាត់អើយ អ្នកណាបេះបាត់ អើយ។

ក្វាំង

អើយ មកណា លោកគ្រូតូច លោកគ្រូធំ ណា
១. ហាអេអឺងអើយ ហឺនៃអញ្ជើញគ្រូតូច ព្រះគុណហ្អើយលោកហ្អើយ អេអញ្ជើញគ្រូធំហ្អេ អញ្ជើញហ្អើយគ្រូតូច ឱព្រះគុណហ្អើយខ្ញុំហ្អើយ អញ្ជើញហ្អាគ្រូធំ អឺនៃគ្រូហ្អើយជួយខ្ញុំអើយ លោកហ្អើយនៃថ្វាយពិអើយស្ពុការហ្អេ។

២. អេអើយ អឺអើយអឺ អីនៃអញ្ជើញហ្អាគ្រូតូចហ្អេ ព្រះគុណហ្អាលោកហ្អើយ នៃអញ្ជើញគ្រូធំហ្អេ អញ្ជើញហ្អាគ្រូមកហ្អេ ព្រះគុណហ្អើយខ្ញុំហ្អើយ ដាច់ស្មោះហ្អើយទាំងវាលហ្អេ (គ្រោ) អីនៃបាក់ទាំងហ្អើយគុម្ពព្រេចព្រះគុណហ្អាលោកហ្អើយ បាក់ទាំងហ្អើយគុម្ពព្រាលហ្អេអើយ ហាអេអើយ ហ្អេអើយ អីនៃបាក់ទាំងហ្អាគុម្ពព្រេចហ្អា រិចទាំងហ្អើយគុម្ពព្រាល ព្រះគុណហ្អើយលោកហ្អើយ ស្នាដៃស្ដេចព្រះគ្រូហ្អេ។
(គ្រោ..ហ៊ិច..ហ៊ិច..មកហើយ លោកគ្រូមកហើយ ហ្អើយ)

៣. ហាអេអឺអើយ អីនៃអញ្ជើញហ្អាស្រីខ្មៅ ព្រះគុណហ្អាលោកហ្អើយ នាងមករាំហ្អេសប្បាយ អីនៃអញ្ជើញហ្អើយស្រីខ្មៅ នៃព្រះគុណហ្អាលោកហ្អើយហ្អេ មករាំហ្អាសប្បាយ អីនៃចូលមកហ្អើយក្នុងកាយ ព្រះគុណហ្អាលោកហ្អើយ អើយសុំសុខអើយសួស្ដីអេអើយ។

ស្រលាញ់ស្រីខ្មៅ

(គ្រោ ហ៊ិច ហ៊ិច)
១. ស្រលាញ់ហ្អាស្រីខ្មៅ ថ្ងៃហ្អើយពាក់អាវហ្អើយក៏មូរដៃហ្អេ នៃស្រលាញ់ហ្អាស្រីខ្មៅ អូនហ្អើយពាក់អាវហ្អើយក៏មូរដៃ សាច់ហ្អា សហ្អើយក៏ម៉ដ្ឋហ្អាខៃ ថ្ងៃហ្អើយរាងដូចហ្អាត្បាល់ហ្អាបុក ដើណា ថ្ងៃណា ក្រមុំហ្អាអូនហ្អើយរាងដូចត្បាល់ហ្អាបុក។

២. ចុះបងកាច់ផ្កាអឺ ថ្ងៃហ្អើយកាច់ផ្កាណាសាពិតាន បងកាច់ឱផ្កាអឺ ថ្ងៃហ្អើយកាច់ផ្កាណាសាពិតានបងកាច់ហ្អើយឱ្យបានទុកឱ្យដល់ឆ្នាំហ្អាក្នែក ដើណា ថ្ងៃណា ក្រមុំអូនហ្អើយទុកដល់ឆ្នាំហ្អាក្នែក។
(ធីប ធីប គ្រោ)

៣. បងកាច់ផ្កាអឺ..ថ្ងៃហ្អើយកាច់ផ្កាណាសាពិតានបងកាច់ឱផ្កាអឺ..ថ្ងៃហ្អើយកាច់ផ្កាណាសាពិតានបងកាច់ហ្អើយឱ្យបាន ថ្ងៃហ្អើយទុកដល់ហ្អាឆ្នាំហ្អាក្នែក ដើណា ថ្ងៃណា ថ្ងៃហ្អើយទុកដល់ហ្អាឆ្នាំហ្អាក្នែក។
ជ័យហោង (ជ័យ) សួរហោង (សួរ) សុខហោង (សុខ)
ថ្ងៃនេះកាច់ផ្កាសាពិតានមានសេរីសួស្ដីមែនហោង (មែន) បើមែនបានអីជាបន្ទាល់ បានអីជាប្រាកដ (ជ័យ) បានអីជាសេរីសួស្ដី ហ៊ោ។

កញ្ចាញ់ចេក

១. កញ្ចាញ់ចេកហ្អើយ អីនៃ លោតទំបាច់អុស កញ្ចាញ់ចេកហ្អើយ អីនៃ លោតទំបាច់អុស ចុះមេម៉ាយកាងឹតច្រមុះអើយ ដេញប្រុសណាហុយហ្អាដី កាងឹតច្រមុះហ្អើយ ដេញប្រុសណាហុយហ្អាដី។

២. ដេញទៅដេញមក អីយ៉ាស់ រត់ចូលណាគុម្ពហ្អាចេក (គ្រោ) ដេញទៅញទៅដេញមក អីយ៉ាស់រត់ចូលតា

គុម្ពចេក អីនែ កំពុងហ្អើយតែដេក អើយបាក់ដើមចេកណាម្ដែគុម្ព ហ្អើយគល់ចេកបាក់ដើមចេកណាម្ដែគុម្ព។
(គ្រោ ឆើស ឆីចៗៗ)

៣. កញ្ចាញ់ចេកហ្អើយ អីនែ លោតទំបាច់អុស (គ្រោ) ថាកញ្ចាញ់ចេកហ្អើយ អីនែ លោតទំបាច់អុស មេម៉ាយ កាងឹតច្រមុះហ្អើយ ដេញប្រុសណាហុយដី កាងឹតច្រមុះហ្អើយ ដេញប្រុសណាហុយដី

៤. ដេញទៅដេញមក អីយ៉ាស់រត់ចូលណាគុម្ពចេក ដេញទៅដេញមក អីយ៉ាស់រត់ចូលណាគុម្ពចេកអាល័យ ហ្អើយតែដេកអើយ បាក់គល់ចេកណាម្ដែគុម្ព អាល័យហ្អើយតែដេក អីយ៉ាស់បាក់ចេកម្ដែគុម្ព។
(គ្រោ ឆីចៗៗៗៗៗៗ)

ស្វាយចន្ទី

១. ឱស្វាយចន្ទីនារីអូនហ្អើយ បែកមែកសាខា ឱស្វាយចន្ទីនារីអូនហ្អើយបែកមែកសាខា ធ្វើបុណ្យហ្អើយកាលណា បងប្រាថ្នាជួបតែមីអូនស្រី ធ្វើបុណ្យកាលណា បងប្រាថ្នាជួបតែមីអូនស្រី។

២. សាច់ហ្អាសសែនហ្អាសម ឱនែក្រមុំអូនហ្អើយកុំអាលយកប្ដី សាច់សសែនសម ក្រមុំអូនហ្អើយកុំអាលយកប្ដីចាំហ្អាបងនែទៅទិញហ្អាឡានថ្មី យកម៉ោដឹកអូនស្រីដើរលេងកម្សាន្ត ចាំហ្អាបងនែទៅទិញហ្អាឡានថ្មី យកម៉ោដឹកនែអូនស្រីដើរលេងកម្សាន្ត។
(ធិច ៗ គ្រោ ហ៊ិច ៗ)

៣. ឱស្វាយចន្ទីនារីអូនហ្អើយបែកមែកសាខា ឱស្វាយចន្ទីនារីអូនហ្អើយបែកមែកសាខា ធ្វើបុណ្យកាលណា បងប្រាថ្នាជួបតែមីអូនស្រី ធ្វើបុណ្យហ្អើយកាលណា បងប្រាថ្នាជួបតែមីអូនស្រី។

៤. សាច់ហ្អាសសែនហ្អាសម អានែក្រមុំអូនហ្អើយនែកុំអាលយកប្ដីអើយ សាច់ហ្អាសសែនហ្អាសម អានែក្រមុំអូនហ្អើយកុំអាលយកប្ដី ចាំហ្អាបងទៅទិញឡានថ្មី នាំអូនស្រីទៅលេងអង្គរវត្ត ចាំហ្អាបងនែទៅទិញឡានថ្មី នាំមីអូនស្រីទៅលេងអង្គរវត្ត។

ឃ. ភូមិផ្ទៀក

ល.រ	បទ	លេងពេល
១	ជ្រេង	ថ្វាយគ្រូ
២	ម្ធប់ដូង	មេមត់រាំ/ឡើងអ្នកតា

៣	អុំទូក	មេមត់រាំ/ឡើងអ្នកតា
៤	បញ្ចុះ	មេមត់រាំ/សាពិតាន/បញ្ជូន/ឡើងអ្នកតា
៥	ទាក់ជំរឺ	មេមត់រាំ/ឡើងអ្នកតា
៦ *	ប្រដាល់	មេមត់រាំ/ឡើងអ្នកតា (បទនេះពុំមានទំនុកទេ)
៧ *	ផៃយ៉ាំ	មេមត់រាំ/ឡើងអ្នកតា (បទនេះពុំមានទំនុកទេ)
៨	បរចាប	មេមត់រាំពីដើមអាចលេងក្នុងវង់ភ្លេងការពេលបើករាំងនន

ជ្រេង

១. ហាអើយ អើយ អើយ អើយ សុំអញ្ជើញលោកគ្រូតូច ព្រះគុណហ្អើយ អើយ អើយ អើយ សុំអញ្ជើញលោកគ្រូធំហ្អើយ អើយ ហ្អើយ អើយ ឱណា លោកគ្រូនៅលើកំពូលភ្នំ ព្រះគុណហ្អើយ អើយ អើយ កូនចៅជ្រោងកន្ទោងហៅរកហ្អើយ អើយ អើយ។

ម្លប់ដូង

១. ម្លប់ដូងហ្អើយ អើយ អើយ ហាអើយ លោកគ្រូខ្ញុំហ្អើយ គ្រូអើយ ឱធ្លាប់ជ្រកអើយ ឱម្លប់ដូងហ្អើយ អើយ អើយ ហាអើយ គ្រូហកអើយ គ្រូអើយ ឱធ្លាប់ជ្រកអើយ អើយ លោកគ្រូ នៃកូនចៅហ្អើយ ហៅរក ឱលោកគ្រូហ្អើយ ខ្ញុំអើយ ធ្លាប់ជ្រក ក្រោមម្លប់ដូងត្រជាក់អើយ លោកគ្រូហ្អើយ កូនចៅហៅរកហ្អើយ លោកគ្រូអើយធ្លាប់ជ្រកម្លប់ដូងឱ......ត្រជាក់។

២. ម្លប់ដូងហ្អើយ អើយ អើយ ហា ហាអើយ គ្រូហ្អើយ កុំអាក់ហ្អើយ កុំអន់អើយ ឱលោកគ្រូហ្អើយ ខ្ញុំហ្អើយអើយ ហា ហាអើយ គ្រូហ្អើយ កុំអាក់កុំហ្អើយអន់អើយ សូមអញ្ជើញហ្អើយ គ្រូអើយ និមន្តហ្អើយ លោកគ្រូដៃទន់ និមន្តមកលេងកំសាន្តហ្អើយ អើយ ហាអើយ អើយ លោកគ្រូហ្អើយដៃទន់ លោកគ្រូនៃនិមន្ត មកលេងឱកម្សាន្ត។

៣. ម្លប់ដូងហ្អើយ អើយ ហា ហាអើយ អើយ គ្រូហ្អើយ លោកគ្រូស្វាចា អើយ អើយ ហា ហាអើយ ឱលោកគ្រូហ្អើយ ស្វាជមហ្អើយ គ្រូអើយ លោកគ្រូ ឱស្វាចាអើយ អើយលោកគ្រូហ្អើយ រវល់ហ្អើយទៅណា លោកគ្រូហ្អើយ ខ្ញុំហ្អើយ ថ្ងៃនេះមិនទាន់មកដល់អើយ អើយ ហា ហាអើយ លោកគ្រូហ្អើយ អាឡែវរវល់ទៅណាលោកគ្រូហ្អើយ ខ្ញុំហ្អើយ ថ្ងៃនេះមិនទាន់មកដល់អើយ។

៤. [ម្ងប់]ដូងអឺយ គ្រូហ្អើយ ឱគ្រូធំហ្អើយ សូមអញ្ជើញគ្រូតូចហ្អើយ គ្រូហ្អើយ លោកគ្រូធំអើយ អើយ លោកគ្រូអញ្ជើញចុះលើពីភ្នំ លោកគ្រូនិមន្ត គ្រូហ្អើយ មកសប្បាយហ្អើយ លោកគ្រូសុំអញ្ជើញនិមន្តហ្អើយ លោកគ្រូបាយខុននិមន្តមកកម្សាន្ត។

៥. អើយ អើយ ហា ហាអើយ..គ្រូហ្អើយ ទៅទាក់ហ្អើយ ដំរីអើយ ឱលោកគ្រូហ្អើយ តូចហ្អើយ គ្រូហ្អើយ ទៅទាក់ហ្អើយដំរីអើយ លោកគ្រូហ្អើយ ទៅទាក់ដំរីព្រៃហ្អើយ ទៅទាក់បានបី ទម័កឱ្យរួចមួយអឺយ រួចចំអាក្បាលស្លួយ ដំរីរួចមួយ អឺ ចំអាក្នុកធំអឺយ។

អុំទូក

១. ឱណាបងអុំទូកទៅ ឱមាសបងហ្អើយ ចង្វាព្រាតៗអើយ ហីនែបងអុំទូកទៅ ព្រលឹងកែវហ្អើយ ចង្វាព្រាតៗអើយ បងស្រែក បងស្រែកប្រាប់ញាតិ ខ្មៅអូនហ្អើយ ឱមើលខ្មៅផង ដើណា ដើណាថ្ងៃណា ឱមាសបងហ្អើយឱ្យមើលខ្មៅផង

២. ឱមាសបងហ្អើយ មើលពួរចំណង ឱមាសបងហ្អើយ មើលពួរចំណង មើលខ្មៅហ្អើយ មើលខ្មៅហ្អើយ បែកផង ឱមាសបងហ្អើយ ក្រែងបានទៅគេ ដើណា ដើណាថ្ងៃណា ឱមាសបងហ្អើយ ក្រែងបានទៅគេ។

៣. ឱណាបងអុំហ្អើយទូកទៅអើយ ឱខ្មៅបងហ្អើយ ខ្មៅអូនយំតាម អុំហ្អើយទូកទៅអើយ ឱខ្មៅបងហ្អើយ ខ្មៅអូនយំតាម ទឹកភ្នែកហ្អើយ ទឹកភ្នែករហាម ឱខ្មៅអូនហ្អើយ ដាក់ខ្មៅត្រង់ណា ដើណា ដើណាថ្ងៃណា ឱមាសបងហ្អើយដាក់ខ្មៅត្រង់ណា។

៤. ដាក់ខ្មៅខាងមុខ ឱមាសបងហ្អើយ ខ្មៅទើសដងច្រវាអឺយ ដាក់ខ្មៅខាងមុខអឺយ ឱមាសបងហ្អើយ ខ្មៅទើសដងច្រវាអឺយ ដាក់ខ្មៅៗត្រង់ណា ឱមាសបងហ្អើយ ដាក់លើភ្លៅបង អឺយថ្ងៃណា ឱមាសបងហ្អើយ ដាក់លើភ្លៅបង។

បញ្ចុះ (ជូនហៅ កុមាររ៉េវ)

១. អេអើយ ហ្អើយ អើយ អើយ ហា ហាអើយ អើយ ហាអើយហៅឱចេញមកគ្រូតូច គ្រូធំ អញ្ជើញអើយអស់ឱណាគ្រូតូច គ្រូហ្អើយនិមន្តមក លោកគ្រូអើយមកកំសាន្ត អញ្ជើញគ្រូមក លោកគ្រូហ្អើយមកកម្សាន្ត។

២. អើយ អើយ អើយ ហា ហាអើយ ហ្អើយ អើយ ខ្មៅហ្អើយ ខ្មៅហ្អើយ ខ្មៅហ្អើយ ខ្មៅនិល ហីនែខ្មៅហ្អើយ ខ្មៅហ្អើយ ខ្មៅមិញ ខឹងហើយជាវិញ ខ្មៅហ្អើយ ជាលើសដើម ខឹងហ្អើយជាវិញ ខ្មៅហ្អើយជាលើសដើម។ គ្រោ... ហីស ហីស ផាច់ ផាច់។

៣. អើយ អើយ អើយ ហា ហាអើយ អើយ អើយ ហាអើយ អញហ្អើយខ្មៅហ្អើយ ដាក់មង់ចុង់ស្រែ ខ្មៅអញហ្អើយ ខ្មៅអើយដាក់មង់ចុង់ស្រែ ជាប់ត្រីកាហែ គ្រូហ្អើយ កន្ទុយក្រហម (គ្រោ...) ចាប់ត្រីកាហែ គ្រូហ្អើយ កន្ទុយក្រហម។ យើស យើស។

៤. អើយ អើយ អើយ អើយ ហា ហាអើយ អើយ អើយ អញហ្អើយ ខ្មៅហ្អើយ ពាក់អាវ កណ្តាច់ខ្មៅអញហ្អើយ ពាក់អាវកណ្តាច់ ដល់ភ្លៀងវាសាច ខ្មៅហ្អើយ ទទឹកដោះអស់ ដល់ភ្លៀងវាសាច ខ្មៅហ្អើយ ទទឹកដោះអស់។ អើយ គ្រោ គ្រោ... ធាក ធាក គី គូ គី គូ។

៥. អើយ អើយ អើយ អើយ ហា ហាអើយ អើយ អើយ កេរអញហ្អើយ ឱកេរអើយ ឱកេរប្រមឹកហ្អើយ ឱកេរអញហ្អើយ ឱកេរហ្អើយប្រមឹកហ្អើយ ជឿស្រាគេផឹក កេរហ្អើយ មិនឱ្យលុយគេ ហា យកស្រាគេផឹក កេរហ្អើយ មិនឱ្យលុយគេ។ យើស អា យើស យើស គ្រោ។

ធាក់ដំរី

១. ទៅទាក់ ទាក់ ឱ ដំរី អើយ ទាក់បានបី ដំរី ឱ រួចមួយ ទៅទាក់ ទាក់ ឱ ដំរី អើយ ទាក់បានបី ដំរី ឱ រួចមួយ ព្រះគ្រូឱលោកជួយ ដំរីរួចមួយ ចំ ឱ ក្នុកធំ ដើណាណា ឱ ថ្ងៃណា ដំរីរួចមួយ ចំ ឱ ក្នុកធំ។
គ្រោ...។

២. ទៅទាក់ ទាក់ ឱ ដំរី អើយ ទាក់បានបី ដំរី ឱ រួចមួយ ទៅទាក់ ទាក់ ឱ ដំរី អើយ ទាក់បានបី ដំរី ឱ រួចមួយ ព្រះគ្រូឱលោកជួយ ដំរីរួចមួយចំ ឱ ក្នុកធំ ដើណា ណា ឱ ថ្ងៃណា ដំរីរួចមួយ ចំ ឱ ក្នុកធំ។

៣. អញ្ជើញទាំង់លោកគ្រូតូច គ្រូអើយអញ្ជើញទាំង់ អឺ លោកគ្រូធំ អញ្ជើញទាំង់លោកគ្រូតូច លោកអើយ អញ្ជើញចុះទាំង់ អឺ លោកគ្រូធំ អញ្ជើញ ហ្អើយ លោកគ្រូខ្ញុំ លោកគ្រូខ្ញុំ ហ្អើយ មកទាក់ដំរី ដើណា ណា ថ្ងៃណា លោកគ្រូខ្ញុំ ហ្អើយ មកទាក់ដំរី។

បរចាប

១. ឱ អាំហ្អើយ ស្រីអាំ ឱណា អាំហ្អើយ ស្រីអាំ ឱ អាំហ្អើយ ស្រីអាំ អាំហ្អើយ ស្រីអាំ ព្រះពុទ្ធលោកផ្តាំស្រីអាំ បង់អើយឱ្យអាំអូននាង់ដោយបង់ ឱអូនអើយ ឆ្លង់ទូកមួយពីរនាក់។

២. សូមអញ្ជើញលោកគ្រូតូច លោកគ្រូ ហ្អើយ ខ្ញុំហ្អើយ អញ្ជើញទាំង់លោកគ្រូធំ សូមអញ្ជើញលោកគ្រូតូច លោកគ្រូ ហ្អើយ ខ្ញុំហ្អើយ..អញ្ជើញទាំង់លោកគ្រូធំ សូមអញ្ជើញចាំលើព្រំជាមួយគ្រូខ្ញុំ អើយ។

ង. ភូមិត្នោតជ្រុំ

ល.រ	បទ	លេងពេល
១	យល់នាង	ថ្វាយគ្រូ/មេមត់រាំ/ឡើងអ្នកតា
២	ផ្កា	មេមត់រាំ/បណ្ដេញព្រាយ
៣	សៀម	មេមត់រាំ
៤	ផ្កាក្រង	មេមត់រាំ
៥	សន្ទូច	មេមត់រាំ
៦	ម្ទប់ដូង	មេមត់រាំ
៧	ព្រឹន	មេមត់រាំ
៨	អុំទូក	មេមត់រាំ
៩	ស្រងែ	មេមត់រាំ
១០	ត្រែងត្រាច់	មេមត់រាំ
១១	អ៊ួក	មេមត់រាំ
១២	ប្របកៃ	មេមត់រាំ
១៣	កាច់ផ្កា	មេមត់រាំ/សាពិតាន

យល់នាង

១. ស្មើណោះស្មើម៉ានអើយរើយ ព្រលឹងគ្រូអើយ គ្រូហ្អើយគ្រូហ្អើយ បើស្មើណោះហីនៃចុះបណ្ដើរគ្រូហ្អើយ ស្មើម៉ាន រើយគ្រូហ្អើយនៃស្មើម៉ាន។

២. អើយស្មើណោះហើយស្មើម៉ានអើយ អីរើយគ្រូអើយ ព្រលឹងគ្រូហ្អើយ បើស្មើណោះហីនៃចុះបណ្ដើរគ្រូអញ ស្មើម៉ាន ព្រោះអីចុះបណ្ដើរអើយគ្រូហ្អើយ ចុះបណ្ដើរគ្រូអញដល់ឋាន ដល់ឋានរួចស្មើណោះបើស្មើម៉ាន គ្រូហ្អើយបានហីគ្រូចុះមក៍ (ម៉ោ) ដល់អេអើយ រើយគ្រូហ្អើយ...មក៍ (ម៉ោ)ដល់។

៣. រូចមានទាំងជមបួនអើយ រើយគ្រូអើយ ជម្រាបប្រជួន ប្រជួន គ្រូហ្អើយស្វាធម៌មានទាំងឆ្វេងស្ដាំ រើយគ្រូហ្អើយឆ្វេងស្ដាំ រូចមានទាំងជមបួនអើយ រើយជមបួនអើយ ចុះជម្រាបប្រជួន ប្រជួន គ្រូហ្អើយស្វាធម៌មាន

ទាំងឆ្វេងស្តាំ អញ្ជើញចុះមកគ្រូហ្អើយ ព្រោះអីគ្រូគង់នៃចង់ចាំ ចង់ចាំហ្អើយ គ្រូហ្អើយអញ្ជើញ គ្រូហ្អើយ អញ្ជើញចុះមករក្សាអើយ អ៊ើយគ្រូហ្អើយរក្សា..អើយ។

៤. រួចសំពត់សប្រាំហត្ថអើយ អ៊ើយប្រាំហត្ថអើយ ចុះជម្រាបផ្កាប់ផ្កុន គ្រូហ្អើយគេរៀបដាក់តម្កល់ អ៊ើយគ្រូអើយ រួចតម្កល់ រួចសំពត់សប្រាំហត្ថអើយ អ៊ើយប្រាំហត្ថអើយ ចុះជម្រាបផ្កាប់ផ្កុន ផ្កាប់ផ្កុន គ្រូហ្អើយខ្ញុំលើកដាក់ តម្កល់ ព្រះពិស្ណុការគ្រូហ្អើយ ឱនៃទើបគ្រូចុះមកដល់ មកដល់ហ្អើយ គ្រូហ្អើយបើចុះមក គ្រូហ្អើយចុះមក ជួយរក្សាអើយ អ៊ើយគ្រូហ្អើយរក្សាអើយ។

៥. ថ្ងៃណាហ្អើយម្រាមដៃ ឱនៃខ្ញុំលើកដាក់ទាំងដប់ អ៊ើយគ្រូហ្អើយរួចទាំងដប់ រួចមានទាំងឱណាម្រាមដៃអើយ អ៊ើយម្រាមដៃអើយ គ្រូហ្អើយខ្ញុំលើក អីនៃខ្ញុំលើករួចទាំងដប់ ព្រោះអី ទង្វិក គ្រូហ្អើយទង្វិក អីនៃសព្វគ្រប់ សព្វគ្រប់ហ្អើយ គ្រូហ្អើយបើចុះមក គ្រូហ្អើយចុះមកជួយរក្សាអើយ អ៊ើយគ្រូហ្អើយរក្សាអើយ។

ផ្កា

១. អឺ អើយ អញ្ជើញគ្រូតូច មិនដូចគ្រូធំ ថ្ងៃអើយមិនដូចគ្រូធំ ចុះពីខ្នងភ្នំ គ្រូអើយមកលេងសប្បាយ ថ្ងៃអើយ មកលេងសប្បាយ គ្រូអើយសប្បាយ។

២. អឺ អើយ ហៅបានគ្រូជិត អាណិតគ្រូឆ្ងាយ ហឺអើយអាណិតគ្រូឆ្ងាយ មកលេងសប្បាយ អ្នកអើយឱ្យអស់ ពីចិត្ត ហឺអើយឱ្យអស់ពីចិត្ត គ្រូអើយពីចិត្ត។

៣. អេ អើយ អញ្ជើញមកលេង មកអញអាណិត ហឺអើយព្រោះអញអាណិត ហឺអើយព្រោះអញអាណិត ឱ្យអស់ពីចិត្ត គេបានជាបន់ គ្រូអើយជាបន់ ថ្ងៃអើយជាបន់។

៤. អេ អើយ អញឱ្យមកលេងបណ្តោះអាសន្ន ហឺអើយបណ្តោះអាសន្ន ហឺអើយបណ្តោះអាសន្ន គេបានជា បន់ ហៅក្មេងលេងទៀត គ្រូអើយលេងទៀត ហឺវើយលេងទៀត។

៥. អេ អើយ មកលេងឆ្នាំនេះ លេងចោលមួយស្នៀត ហឺហ្អើយ លេងចោលមួយស្នៀត ហឺហ្អើយលេងចោល មួយស្នៀត ឆ្នាំក្រោយលេងទៀតឱ្យសះឱ្យស្បើយ គ្រូហ្អើយឱ្យស្បើយ ថ្ងៃវើយឱ្យស្បើយ

៦. តម្កាត់ តម្កាត់ឱ្យស្បើយ ថ្ងៃអើយតម្កាត់ឱ្យស្បើយ ថ្ងៃអើយតម្កាត់ឱ្យស្បើយ ឱ្យល្ហែឱ្យល្ហើយ ពីថ្ងៃនេះទៅ គ្រូហ្អើយនេះទៅ ថ្ងៃវើយនេះទៅ។

សៀម

១. ទៅណាមកណា នៃស្រកាគ្រូហ្អើយ ចែកអញទៅផង ទៅណាមក៍ (ម៉ោ) ណា នៃស្រកាគ្រូហ្អើយ ចែកអញទៅផង គ្រូហ្អើយបើទៅបាត់ ក្រាស់ហើយដំបង គ្រូហ្អើយបើទៅមើល ថាទៅមើលសៀមរាំអើយ ហៃហ្អើយ គ្រូហ្អើយបើទៅមើល ទៅមើលសៀមរាំអើយ ហាអេអឺ.......អើយ។

២. នឿយហត់ប៉ុន្មាន សេចក្ដីរាប់អាន អញស៊ូទ្រទ្រាំ គ្រូអើយទៅមើលសៀមរាំ រាំលេងសប្បាយនឿយហត់ប៉ុន្មាន សេចក្ដីរាប់អាន អញស៊ូទ្រទ្រាំ គ្រូអើយទៅមើលសៀមរាំ រាំលេងសប្បាយជួយបានប៉ុន្មានសេចក្ដីរាប់អាន...រាំលេងហ ថ្ងៃអើយ ព្រោះអញរាំលេង ថ្ងៃអើយសប្បាយ

៣. ហាអេអឺអើយ ហៅបានគ្រូជិត អ៊ីរួចអញរាប់អញគិត ចុះអាណិតគ្រូឆ្ងាយ ហៅបានគ្រូជិតរួចអញរាប់អញគិត ចុះអាណិតគ្រូឆ្ងាយ អញឱ្យមកលេង ក្រាស់នៃសប្បាយ ចុះលោកអើយអ្នកអើយ លេងឱ្យអស់ចិត្តអេអើយថ្ងៃហ្អើយ គ្រូអើយលេងឱ្យ គ្រូអញអស់ចិត្តអេ.......អើយ។

៤. ហាអេអឺអើយ អញហៅមកលេង គ្រូចាស់គ្រូក្មេង ព្រោះអញអាណិត អញហៅមកលេង គ្រូចាស់គ្រូក្មេង ព្រោះអញអាណិត អញឱ្យមកលេងឱ្យអស់ពីចិត្ត ដ្បិតអីគេបាន គេបានជាបទ់អើយ ថ្ងៃហ្អើយគ្រូអើយ គេបានគ្រូអញជាបទ់ អឺ ហាអឺអេអើយ។

ផ្កាក្រង

១. ហាអេអើយ ហាអឺងអើយ ចុះស្រណោះផ្កាក្រង អូនហ្អើយក្រងហើយដោយមាលា ថ្ងៃហ្អើយ ក្រងហើយដោយមាលា អូនហ្អើយរសាត់ដោយតាមគង្គា អូនហ្អើយលាហើយបើទៅអឺមក ថ្ងៃហ្អើយលាហើយវិលទៅអឺមក។

២. ធម្មតាអ្នកលេង ចុះអញប្រាប់គ្រូឯងអ៊ើយ!កុំឱ្យជ្រុល អ្នកលេងអញប្រាប់គ្រូឯងកុំជ្រុល ព្រោះអីលាហើយបើទៅមក ចុះអញ្ជើញគ្រូមកលេងឲ្យសប្បាយ ថ្ងៃហ្អើយមកលេង....សប្បាយ។

៣. ចុះអញហៅគ្រូជិត ចុះអញរាប់អញគិត អាណិតគ្រូនៅអឺឆ្ងាយ ថ្ងៃហ្អើយអាណិតគ្រូ អីនៅអឺឆ្ងាយព្រោះអីគេរៀបអីដាក់ថ្វាយ គ្រូហ្អើយមានសេកអើយកន្ទង់ ថ្ងៃហ្អើយមានសេកអើយកន្ទង់។

៤. ហាអេអើយ ហាអឺងអើយ ចុះស្រណោះផ្កាក្រង ឱស្រណោះផ្កាក្រង ថ្ងៃហ្អើយបងស្រណោះផ្កាក្រង ឱណាផ្កាដែលមីអូនក្រង មិនឱ្យផ្កាប្អូនបាត់ ថ្ងៃហ្អើយមិនឱ្យណាប្អូននៃបាត់។

សន្ទូច

១. ហ៊ីអឺ ហាអ៊ីអឺងអើយ សន្ទូចបង់មួយ ឱណាគ្រូហ្អើយពន់មង់ត្រឡោក ហែនែត្រឡោក ចុះបង្កែលើគោក ឱណាគ្រូហ្អើយចាប់ត្រីកញ្ជូន ហែនែកញ្ជូន ហែនែកញ្ជូន ហែនែកញ្ជូន ហែនែកញ្ជូន ហែនែកញ្ជូន អេអឺ ហាអ៊ីអឺងអើយ។

២. អញ្ជើញមកលេង ឱណាគ្រូហ្អើយ គ្រូកុំក្រោងក្រែ ហែនែក្រោងក្រែ គ្រូចាស់គ្រូថ្មី ឱណាគ្រូហ្អើយ ចុះមកលេងទាំងអស់ ហ៊ីរ៉ើយទាំងអស់ ហ៊ីរ៉ើយទាំងអស់ គ្រូអើយទាំងអស់ គ្រូហ្អើយទាំងអស់ គ្រូហ្អើយទាំងអស់ អេអឺ ហាអ៊ីអឺងអើយ។

៣. អញ្ជើញគ្រូតូច ឱណាគ្រូហ្អើយ ចុះមិនដូចគ្រូធំ ហែនែគ្រូធំ ចុះពីខ្នងក្នំ ឱណាគ្រូហ្អើយ ចុះមក (ម៉ោ) លេងសប្បាយ ហ៊ីរ៉ើយសប្បាយ ហ៊ីរ៉ើយសប្បាយ គ្រូហ្អើយសប្បាយ គ្រូហ្អើយសប្បាយ គ្រូហ្អើយសប្បាយ អេអឺ ហាអ៊ីអឺងអើយ។

៤. អញ្ជើញគ្រូជិត ឱណាគ្រូហ្អើយ ចុះអាណិតគ្រូឆ្ងាយ ហ៊ីរ៉ើយគ្រូឆ្ងាយ ចុះមក (ម៉ោ) លេងសប្បាយ ឱណាគ្រូហ្អើយឱ្យអស់ពីចិត្ត ហ៊ីរ៉ើយពីចិត្ត ហ៊ីរ៉ើយពីចិត្ត គ្រូហ្អើយពីចិត្ត គ្រូហ្អើយពីចិត្ត គ្រូហ្អើយពីចិត្ត អេអឺ ហាអ៊ីអឺងអើយ។

៥. មក (ម៉ោ) ឱណាគ្រូហ្អើយមក (ម៉ោ) ណាខាងកើត ហែនែខាងកើត ឱ្យអស់ពីចិត្ត ឱណាគ្រូហ្អើយ វាបានជាបន់ ហ៊ីរ៉ើយជាបន់ ហ៊ីរ៉ើយជាបន់ គ្រូហ្អើយជាបន់ គ្រូហ្អើយជាបន់ គ្រូហ្អើយជាបន់ អេអឺ ហាអ៊ីអឺងអើយ។

ម្ញប់ដូង

១. ម្ញប់ដូងអើយដែលអញអង្គុយអើយ ម្ញប់ដូងអើយអង្គុយអើយ ចង់អត់ងងុយ គ្រូហ្អើយដើម្បីរវៃអើយ ស្រីហ្អើយចាំស្រីអើយរវៃ ស្រីហ្អើយថ្ងៃអើយចាំស្រីរវៃ ដើងជាន់ឈើឈ្នាន់ ថ្ងៃហ្អើយដៃបោះឱណាត្រល់ថ្មីអើយ ថ្ងៃហ្អើយ អ៊ីអើយត្រល់ថ្មីអ៊ីអើយ ចុះសញ្ជប់លើកីសញ្ជឹងឱនែស្តាប់ស្គរអឺអឺយ ថ្ងៃហ្អើយសញ្ជឹងស្តាប់ស្គរ ថ្ងៃហ្អើយសញ្ជឹងស្តាប់ស្គរអឺយ។

២. [ដើម]ស្វាជាពោង គ្រូហ្អើយដើមដូង ឱណាជាម្ញប់អើយ ថ្ងៃអើយជាម្ញប់អេអើយ ដាក់បានឈរឈប់ក្រោមម្ញប់ឱនែដូងហ្អើយអើយ ថ្ងៃហ្អើយក្រោមម្ញប់ដូងហ្អើយ ថ្ងៃហ្អើយក្រោមម្ញប់ដូងហ្អើយ ឈឺឱបាត់ព្រោះអីនែកំចាត់ឱ្យចៀសឱ្យឆ្ងាយអើយ គ្រូអើយឱ្យឆ្ងាយអើយឱ្យលេងសប្បាយពីថ្ងៃឱនេះទៅ ពីថ្ងៃនេះទៅថ្ងៃហ្អើយពីថ្ងៃឱនែនេះទៅ។

ព្រឺង

១. អឺងអើយ បងលបលូកទៅចាក់អូនហ្អើយកន្ត្រាក់បើបានជាល ថ្ងៃហ្អើយអូនហ្អើយ កន្ត្រាក់ថាបើបានជាល ចុះកន្ត្រាក់បានផាល អូនហ្អើយចោលក្បាលមីអូនសិន ថ្ងៃហ្អើយអូនហ្អើយ ចោលក្បាលមីអូនសិន។

២. អឺ ហាអឺងអើយ គន់មើលពីក្រោយ អូនហ្អើយស្រួចដូចអីកាំបិត ថ្ងៃអើយអូនអើយស្រួចដូចឱកាំបិត ចោលក្បាលមីអូនធិត អូនហ្អើយអាគីថាបើដូចស្តុយ ថ្ងៃហ្អើយអូនហ្អើយ អាគីថាបើដូចស្តុយ។

៣. អឺ ហាអឺងអើយ អញ្ជើញមកលេង ថ្ងៃហ្អើយអ្នកកុំថាមករកក្តី ថ្ងៃហ្អើយអូនហ្អើយ អ្នកកុំថាមករកក្តី សំពត់អាវថ្មីថ្ងៃហ្អើយជួបគ្រូ បើទាំងអើយអស់ ថ្ងៃហ្អើយអូនហ្អើយ ជួបគ្រូបើទាំងអើយអស់។

៤. អឺ ហាអឺងអើយ អញ្ជើញមកលេងគ្រូហ្អើយគ្រូប៉ិនខាងបើគេចដោះ ថ្ងៃហ្អើយគ្រូហ្អើយគ្រូកុំខាងបើគេចអើយដោះ ចុះមកលេងទាំងអស់ គ្រូហ្អើយបណ្តោះហើយហីអាសន្ន ថ្ងៃហ្អើយគ្រូហ្អើយបណ្តោះហើយបើអាសន្ន។

៥. អឺ ហាអឺងអើយ អញ្ជើញមកលេង គ្រូហ្អើយគេបានបើជាបន់ ហីអើយគ្រូហ្អើយ គេបានខាងបើជាបន់ បណ្តោះអាសន្ន គ្រូហ្អើយឆ្នាំក្អែកលេងម្តងទៀត ថ្ងៃហ្អើយគ្រូហ្អើយ ឆ្នាំក្អែកលេងម្តងទៀត។*

....

* ឆ្នាំក្អែកសំដៅទៅឆ្នាំ ឬឆ្នាំខាងមុខ

អុំទូក

១. បងអុំទូកទៅ នារីអូនហ្អើយ ....ដូចគេលេង រលកអើយចុះរលកគ្រាំគ្រេង ថ្ងៃហ្អើយមិនដឹងដាក់ខ្មៅស្រីអូនខាងអឺណាអើយ ស្រីហ្អើយព្រលឹងអូនហ្អើយ មិនដឹងដាក់ខ្មៅស្រី អូនខាងអឺណាអើយ។

២. ដាក់ខ្មៅខាងមុខ នារីអូនហ្អើយ ព្រោះអីខ្លាចវាទើសស្ទាបច្រវាអើយ ដាក់ខ្មៅខាងមុខ ថ្ងៃហ្អើយខ្លាចវាទើសស្ទាបច្រវាអេអើយ ដាក់ខ្មៅអើយចុះមេអូនត្រង់ណា ថ្ងៃអើយព្រោះអីដាក់លើបើទ្រូងអឺបង ថ្ងៃអើយព្រលឹងអូនហ្អើយ ដាក់លើបើទ្រូងបងអឺបង។

៣. ទូកមកលឿនគែម ថ្ងៃហ្អើយទូកមកលឿនអឺគែម ទូកម៉ោលឿនគែម ថ្ងៃហ្អើយ ទូកម៉ោលឿនអឺគែមអើយស្រីខ្មៅអើយស្រីខ្មៅស្រអែម ថ្ងៃហ្អើយតើអូនអុំទូកបើទៅអឺណាអើយ អីណា អូនហ្អើយតើអូនស្រីអុំទូកទៅអើយណាអើយ។

៤. ដើងដាន់គែមទូក ថ្ងៃហ្អើយដៃលូក......ពានស្វាអេអើយ ដើងដាន់គែមទូក ថ្ងៃហ្អើយដៃលូក......ពានស្វាអេអើយ ប្រញាប់អើយចុះប្រញាប់ទៅណា ខ្មៅហ្អើយព្រោះអីបងសូមបើទៅអឺផង អីណា អូនហ្អើយ ព្រោះអីបងសូមបើទៅអឺផងអើយ។

ស្រងែ

១. ឱស្រងែ ងែហ្អើយ ផ្ទៃវាដូចអើយស្រូវ ថ្ងៃហ្អើយផ្ទៃវាដូចអើយស្រូវ ស្រីតូចច្រឡឹង អូនហ្អើយច្រូតស្រូវខាងស្រងែ អឺអើយ គ្រូហ្អើយ ច្រូតស្រូវខាងស្រងែ មាសទៅលេង......ម៉ែ ថ្ងៃអើយកុំឱគេចអើយកែ បានជាកូនម៉ែ គ្រូអើយមកលេងខាងទាំងអឺអស់ ថ្ងៃអើយគ្រូអើយមកលេងខាងទាំងអឺអស់ គ្រូហ្អើយមកលេងគ្រូកុំគេចដោះ ហីហ្អើយគ្រូកុំគេចដោះ មកលេងទាំងអស់គ្រូអើយមកដោះខាងអាសន្ន ថ្ងៃអើយគ្រូអើយមកដោះខាងអាសន្ន។

២. ថ្ងៃអើយគ្រូកូនបានជាអឺបន់ មកដោះអាសន្នគ្រូអើយឆ្នាំក្អែកនេះម្តងទៀត ថ្ងៃអើយគ្រូអើយឆ្នាំក្អែកនេះម្តងទៀត ក្របីវែងចេកវែងបាក់របង អើយវែងបាក់របង ក្របីវែងបង ថ្ងៃអើយមុតទាំងកញ្ចូញគូទ ថ្ងៃអើយគ្រូអើយមុតទាំងកញ្ចូញគូទ។

ត្រែងត្រាច់

១. ហាអើយ ត្រែងត្រាច់ ដុះដោយវាលគុម្ពោត រួចកំពុងប្រុសបងបញ្ឆោត បងត្រាច់រកស្រី រួចកន្រ្តៃតណា កំពុង កុំបេតី នៃគូកម្មនៃអ្វី ធ្វើឱ្យប្រុសបងព្រាត់ ដើណាព្រលឹងឱណា គូកម្មអឺអ្វីធ្វើឱប្រុសបងព្រាត់។

២. ហាអើយ មើលឈើវារុះ ឱ!ពោយផ្កាអើយ ហាអើយមើលឈើវារុះ ឱ!ពោយផ្កា ដូចសត្វបក្សា វាអើយតែងទំ..រួចចាំរៀននៃរាប់ឈើមាសឧត្តមអឺ នៃដុះលើខ្នងភ្នំច្រើនអើយក្រាស់ក្រៃ ដើណាថ្ងៃណា ដុះលើខ្នងភ្នំច្រើនក្រាស់ក្រៃ។

៣. ហាអើយ ដើមត្រសេកមែកឱ!ឃ្លាតឃ្លៃអើយ ហាអើយ ដើមត្រសេកមែកឱ!ឃ្លាតឃ្លៃ ព្រីង ព្រូស ពួចព្រៃ ប្រអើយពាលខែ មានដើមញញៀតទាំងឱ!ស្នាត់ស្នេរ ពពេលជ្រៃជ្រៃ ក្រាយហីក្រវាន់ ដើណាថ្ងៃណា នៃពពេលជ្រៃជ្រៃ ក្រាយហីក្រវាន់

៤. ហាអើយ ឱ!ដើមញញៀត ដើមអើយសណ្តាន់អើយ ហាអើយ ញញៀត ដើមអើយ សណ្តាន់ ដើមទ្នួនអើយក្រវាន់ ចន្ទន៍អើយក្រស្នា មានដើមណាចំប៉ី លាយអើយចម្ប៉ាចុះ កញ្ចាត់យុថ្កា សូមអើយខន្តី ដើណាថ្ងៃណា ចុះកញ្ចាត់នៃយុថ្កា សូមឱ!ខន្តី

៥. ហាអើយ មានទាំងយាងត្រាចដើមរវៃអើយ ហាអើយ យាងត្រាចដើមអើយរវៃ ដើមទ្នួននាងស្រី លោតពីកាដកពោធិផ្ទៃវាលាយអើយធាំធា ចុះកញ្ចាត់យុថ្កា សូមឱ!ខន្តី ដើណាថ្ងៃណា ចុះកញ្ចាត់យុថ្កាហី! សូមខន្តី។

អ៊្លូកា

១. ហាអឺ ហាអឺអើយ ហីនៃអកអើយ អកសែន ណាវ៉ើយអឺនៃអ៊្លូកហ្អើយ អ៊្លូកសែនអើយ ហីអ៊្លូកសែនអឺអេអើយ អឺអើយ ហាអើយ ហីនៃអ៊្លូកវ៉ើយ អ៊្លូក សែនណាវ៉ើយ

២. ចុះកន្ទុយអកពេន អេអើយ ថាហើយស្រែផ្កាំអើយ គ្រូអើយ ថាហើយស្រែកផ្កាំ អញគិតតាមឯង អឺអេអើយ អឺអើយ ហាអើយ ឯងត្រូវចងចាំអើយណាអ៊ើយ ឯងចេះចងចាំ គិតតាមឯង អឺអេអើយ អឺអើយ ហាអើយហី នៃឯងត្រូវចងចាំណាអ៊ើយ ហើយស្រែផ្កាំ ហ្អាអឺអើយ ឱណាមើលខ្មៅចែកផងណាអ៊ើយ មើលខ្មៅចែកផង ខ្លាចពួរវាដាច់អឺអេអើយ អឺអើយ ហាអើយ នៃខ្លាចរបូតចំណងខ្មៅអើយ នៃខ្លាចរបូតចំណង ខ្លាចពួរវាដាច់ អឺអេអើយ អឺអើយ ហាអើយ ខ្លាចរបូតចំណងណាអ៊ើយ មើលខ្មៅចែកផងអើយ ឱនៃខ្លាចវាស៊ីខ្សែណាអ៊ើយ នៃខ្លាចវាស៊ីខ្សែអើយ។

ប្របកោ

១. ហៃ អេអើយ ហាអឺងអើយ ហៃនៃអញ្ជើញមកលេង ថ្ងៃហ្អើយអ្នកកុំបើរកក្ដី ថ្ងៃអើយអ្នកកុំថាបើរកក្ដីព្រោះ អឺអញ្ជើញបើគ្រូថ្មី គ្រូហ្អើយមកលេង ឱ ទាំងអើយអស់អើយ ហាអឺង.......អើយ។

២. អេអើយ ហាអឺងអើយ ដ្បិតអឺខ្ញុំនៅឆ្ងាយ ព្រោះអឺអញ្ជើញអើយទាំងអស់ ថ្ងៃហ្អើយ អញ្ជើញមកទាំងអើយ អស់ ព្រោះអឺគ្រូស្រីទាំងគ្រូប្រុស គ្រូហ្អើយមកលេងសប្បាយ អឺ ហាអឺងអើយ។

៣. អេអើយ ហាអឺងអើយ គ្រូចង់បើបានសុខ(?) ថ្ងៃហ្អើយចង់បានខាងទូលាយ ថ្ងៃអើយចង់ខាងបើទូលាយ ព្រោះអឺគេរៀបឱដាក់ថ្វាយ គ្រូហ្អើយជមគ្រូឱទាំងអើយអស់ អឺ.......ហាអឺងអើយ។

៤. អេអើយ ហាអឺងអើយ អញ្ជើញទាំងគ្រូស្រី.....ថ្ងៃហ្អើយ អញ្ជើញទាំងគ្រូអឺប្រុស ថ្ងៃហ្អើយអញ្ជើញទាំង គ្រូប្រុស ព្រោះអឺអញ្ជើញ អឺ ទាំងអស់ គ្រូហ្អើយបណ្ដោះបើអាសន្នអើយ អឺ ហាអឺងអើយ។

កាច់ផ្កា

១. បងកាច់ផ្កាអឺ...អើយ..ហ្អើយ..អើយ ផ្កាអឺ ថ្ងៃអើយ ព្រោះអឺកាច់ផ្កាសាពិតាន..បងកាច់ឱ្យបាន ថ្ងៃអើយ..មិន ឱ្យបាក់មែក..ថ្ងៃអើយ ព្រោះអឺមិនឱ្យបាក់មែក។

២. បងកាច់ផ្កាអឺអើយ..ហ្អើយ..អើយ ផ្កាអឺ ថ្ងៃអើយព្រោះអឺ..កាច់ផ្កាត្រសេក..មិនឱ្យបាក់មែកព្រោះអឺឆ្នាំក្នែក អឺយកាច់ទៀត ថ្ងៃអើយ..ព្រោះអឺឆ្នាំក្នែកកាច់ទៀត។

៣. កាច់ផ្កាអឺ..អើយ ហ្អើយ..អើយ ផ្កាអឺ ថ្ងៃអើយព្រោះអឺ..កាច់ផ្កាទោសៀត..ឆ្នាំក្រោយកាច់ទៀតថ្ងៃអើយ ឱ្យសះឱ្យស្បើយ..ថ្ងៃអើយ ព្រោះអឺឱ្យសះអឺយឱ្យស្បើយ។

៤. ខ្ញុំកាច់ផ្កាអឺ អើយ..ហ្អើយ អើយ ផ្កាអឺ ថ្ងៃអើយ ព្រោះកាច់ផ្កាកន្ទ្រើយ ឱ្យសះអើយឱ្យស្បើយថ្ងៃអើយ ពីថ្ងៃ នេះទៅ ថ្ងៃអើយព្រោះអឺពីថ្ងៃនេះទៅ។

សេចក្តីបញ្ចប់

ក្នុងភូមិទាំង៥នេះ បើទោះជាបទខ្លះមានចំណងជើងដូចគ្នាក៏ពិតមែន តែបទភ្លេង និងទំនុកច្រៀង មានរបៀបលេងខុសគ្នាពីភូមិមួយទៅភូមិមួយ។ បទខ្លះមានចំណងជើងដូចគ្នា តែទំនុកច្រៀង និងបទភ្លេង ខុសគ្នា។ ឧទាហរណ៍ដូចជាបទ «ភ្ញាំង» នៅភូមិក្លុងលេងសម្រាប់មេមត់រាំធម្មតា តែនៅភូមិថ្នល់បាក់លេង សម្រាប់ថ្វាយគ្រូពេលចាប់ផ្តើម ហើយក៏អាចលេងសម្រាប់មេមត់រាំបានដែរ។ រីឯទំនុកច្រៀង និងបទភ្លេង គឺ ខុសគ្នា តែមានអត្ថន័យទាក់ទងនឹងគ្រូស្រដៀងគ្នា។ ដោយឡែក ទំនុកច្រៀងបទភាគច្រើនទាក់ទងនឹង ការ អង្វរករសុំឱ្យសះស្បើយពីជម្ងឺទាំងឡាយ។ ចំណែកបទភ្លេងមួយចំនួនទៀតពុំចាំទំនុកច្រៀងទេ ព្រោះអ្នក ភ្លេងខានលេងយូរពេក ឬពុំសូវនិយមលេង។ ក្នុងនោះបទខ្លះទៀតគឺពុំមានទំនុកសម្រាប់ច្រៀងទេ ដូចជាបទ «ប្រដាល់»។

ចំពោះមេក្រុមក្នុងវង់ភ្លេងតាមភូមិនីមួយៗ ក្រៅពីដឹកនាំក្រុមលេងតាមកម្មវិធីនានា គាត់មានតួនាទី សំខាន់មួយទៀតគឺផ្ទេរចំណេះដឹងទៅសមាជិកក្រុមថ្មី។ តាមក្រុមនីមួយៗ ការបំបែកជាក្រុមថ្មី ឬសមាជិក ដែលមានវ័យចាស់ចេញពីក្រុម គឺជារឿងធម្មតា ដូច្នេះហើយ នៅពេលអ្នកចាស់ទៅបាត់ គេអាចរើសអ្នកថ្មី មកបង្ហាត់បង្រៀន និងអាចចូលរួមប្រគុំក្នុងពិធីតែម្តង។

ក្រៅពីនេះ នៅមានបញ្ហាប្រឈមខ្លះៗទៀតដែរ នៅតាមភូមិទាំង៥ខាងលើ។ ជាក់ស្តែងនៅភូមិព្រះដាក់ វង់ភ្លេងមានបទភ្លេងចំនួន១២បទ តែមកដល់សព្វថ្ងៃ អ្នកភ្លេងអាចលេងស្ទាត់បានតែ១១បទ តែប៉ុណ្ណោះ។ ចំណែក១បទទៀតចាំតែចំណងជើង ពុំអាចលេងបានទេ ដ្បិតបទនេះមិនសូវនិយមលេងពេលមានពិធី លៀងមេមត់ម្តងៗ ធ្វើឱ្យអ្នកភ្លេងភ្លេចៗ ដូច្នេះ ក្រែងពួកគាត់អាចចងចាំឡើងវិញ យើងមានបំណងសាកល្បង យកបទដែលមានចំណងជើងដូចគ្នា ហើយបានអាត់សំឡេង និងចម្លងទំនុកច្រៀងរួច ទៅបង្ហាញវង់ភ្លេង ណាដែលពួកគាត់ភ្លេចទំនុកច្រៀង និងបទភ្លេង បទចម្រៀងនោះឡើងវិញ។

ក្រៅពីនោះ វង់ភ្លេងដែលប្រឈមបាត់បង់នៅពេលខាងមុខ គឺនៅភូមិទ្រៀកដែលមានទីតាំងនៅខាង ជើងប្រាសាទវត្តអធ្វារ ព្រោះសមាជិកវង់ភ្លេងនេះចាប់ផ្តើមបោះបង់អាជីពលេងភ្លេងមេមត់ ដោយចាប់យក របរផ្សេងៗ ដែលអាចរកប្រាក់បានច្រើន។ ដូច្នេះហើយពេលមានរវល់លេងម្តងៗ មេក្រុមតែងតែខ្ចីដៃវង់ភ្លេង ពីឃុំខ្នាស់ និងឃុំកណ្តែកទៅលេងជំនួសក្រុមចាស់របស់គាត់។ កត្តាប្រឈមផ្សេងទៀតគឺ អ្នកភ្លេងមួយចំនួន មានវ័យចាស់ទៅហើយពុំអាចលេងបាន ឬអាក់ខានផ្ទេរចំណេះទៅក្មេងៗ។ ម្យ៉ាងទៀត សព្វថ្ងៃ ក្មេងៗពុំសូវ ចាប់អារម្មណ៍រៀន និងប្រកបអាជីពជាអ្នកភ្លេងមេមត់ ឬអារក្សនេះទៀតទេ៕

សេចក្តីថ្លែងអំណរគុណ

ក្រុមការងារស្រាវជ្រាវសូមអរគុណចំពោះអ្នកភ្លេងទាំង៥ក្រុមដូចមានរៀបរាប់ឈ្មោះក្នុងសៀវភៅ នេះស្រាប់ ដែលបានយល់ព្រមចូលរួមក្នុងគម្រោងសិក្សាចងក្រងនេះដោយទឹកចិត្តរីករាយក្នុងបុព្វហេតុចែក

រំលែកចំណេះដឹង និងផ្សព្វផ្សាយអំពីមត៌កវប្បធម៌ ព្រមទាំងបានអនុញ្ញាតឱ្យអាត់សំឡេង និងកត់ត្រាទំនុកច្រៀងយ៉ាងពេញលេញរួចរាល់តាមដំណាក់កាលសម្រេចជាស្ថាពរ។ យើងក៏សូមអរគុណដល់លោក អាន រស្មី ដែលបានផ្តល់យោបល់លើកម្រងសំណួរ និងបង្ហាញតម្រុយរបៀបអាត់សម្លេងភ្លេងសម្រាប់ការផារថត និងការសម្ភាសន៍ប្រមូលព័ត៌មាន។ ជាពិសេសសូមអរគុណ អ្នកស្រី វ៉ា បុប្ផារី និង អ្នកស្រី ស៊ិន សុភា ដែលផ្តល់យោបល់លើការសរសេរទំនុកច្រៀង ដ្បិតដំបូងឡើយយើងស្ទាក់ស្ទើរខ្វះដៃរក្នុងការសម្រេចចិត្តលើរបៀបសរសេរទាក់ទងនឹងចម្រៀងដែលមានរបៀបសរសេររៀងៗខ្លួន។

ឯកសារពិគ្រោះ

វ៉ា បុប្ផារី, ទិត្យ ណារិទ្ធិ, ស៊ិន សុភា, សួង សុភ័ក្រ (២០១៧) ពិធីលៀងមេមត់ស្រុកអង្គរជ័យ ខេត្តកំពត, មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

សាម ច័ន្ទវីរៈ (២០០៩-១០) «ពិធីសុំទឹកភ្លៀង», បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៥, ទំ. ២០-២៣

ហ៊ួន សាវង (២០២០) «យាយម៉ៅ និងពិធីសុំទឹកភ្លៀងនៅភ្នំវល្លិ៍», បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១៥,ទំ១៥-២០.

អាន រស្មី (២០១១) លៀងអារក្សជោគភូមិសំបូរ, និក្ខេបបទបរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ

អាំង ជូលាន (២០០៥-២០០៦) «គ្រូកំណើត», បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១, ទំ.៤៣-៤៤

អាំង ជូលាន (២០០៨-២០០៩) «ទៀន», បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៤, ទំ.១៣-១៦

អាំង ជូលាន(២០០៨-២០០៩) «ភ្លេងទុបមុយ», បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ៤, ទំ.៣១-៣២

អ៊ូ គង្គា, តួច សុភៈ, សោ ចន្ទា, ឆាន់ សុភីនី (២០២០) «បញ្ចៀសចង្រៃឧត្បាត» បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១៥, ទំ.៣៣-៣៩

វត្តអារាមក្នុងតំបន់ការពារនៃឧទ្យានអង្គរ

អ៊ូ គង្គា

នៅឆ្នាំ១៩៩២ តំបន់អង្គរដែលមានផ្ទៃដីសរុប៤០១គីឡូម៉ែត្រក្រឡា ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ការនេះនាំតំបន់អង្គរខុសពីតំបន់ដទៃដោយសារ មានបញ្ញត្តិសម្រាប់គ្រប់គ្រងសម្បត្តិបេតិកភណ្ឌដែលចុះបញ្ជី។ ក្រៅពីប្រាសាទបុរាណ និងស្លាកស្នាមបុរាណវិទ្យា តំបន់អង្គរបច្ចុប្បន្នមានមនុស្សរស់នៅជាហូរហែ និងមានរចនាសម្ព័ន្ធសង្គមសម្រាប់គាំទ្រដល់ការរស់នៅរបស់ប្រជាជន។ ក្នុងនោះក៏មានវត្តអារាម ដែលត្រូវត្រួតពិនិត្យឱ្យគោរពតាមបញ្ញត្តិនៃការចុះបញ្ជី។ ជាទូទៅ វត្តអារាមទាំងនោះគោរពតាមបញ្ញត្តិនៃបេតិកភណ្ឌពិភពលោក ប៉ុន្តែវត្តខ្លះនៅតែមានការប្រព្រឹត្តខុសខ្លះដែរ ដោយបានសាងសង់ខុសពីគោលការណ៍សំណង់ស្ថាបត្យកម្មខ្មែរ និងសាងសង់ដោយមិនមានការអនុញ្ញាតជាដើម។ល។ តំបន់អង្គរសព្វថ្ងៃ បើគិតក្នុងក្របខណ្ឌនៃតំបន់ការពារទី១ និងទី២នៃឧទ្យានអង្គរមានវត្តចំនួន៣៥។[១] តែការគ្រប់គ្រងសំណង់ ឬបេតិកភណ្ឌតាមទីអារាមក្នុងខេត្តសៀមរាបពុំមែនត្រឹមតែ៣៥នេះទេ ដ្បិតសំណង់បេតិកភណ្ឌជាច្រើនទៀតមានវត្តមាននៅតាមបណ្ដាភូមិស្រុកនានាដែរ។ វត្តទាំងនោះខ្លះមានយូរហើយ វត្តខ្លះទើបកកើតឡើង តែមានទីតាំងនៅជាប់នឹងប្រាសាទបុរាណ (រូបលេខ១)។[២] អត្ថបទនេះនឹងពិនិត្យលើលក្ខណៈទូទៅរបស់វត្តនានា ឯកសារច្បាប់ដែលមានសព្វថ្ងៃ ការអភិរក្សស្ថាបត្យកម្ម តម្លៃបេតិកភណ្ឌ និងការវិវឌ្ឍន៍ថ្មីៗចំពោះវត្តអារាមពាក់ព័ន្ធវិស័យទេសចរណ៍សាសនា។

---

[១]រមណីយដ្ឋានសៀមរាប-អង្គរចែកតំបន់ការពារជា៥ ដូចមានចែងក្នុងព្រះរាជក្រឹត្យ ០០១ នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្ដីពីការកំណត់ និងការចាត់ចែង គ្រប់គ្រងតំបន់សៀមរាប-អង្គរ។

[២]តាមឯកសារកម្រងឯកសាររបស់ក្រសួងធម្មការ និងសាសនា វត្តក្នុងខេត្តសៀមរាបមានចំនួនសរុប៦២៧វត្ត ដែលទំនងជាគិតត្រឹមឆ្នាំ២០១០ (មិន ឃិន ២០១៣)។



រូបលេខ១. ទីតាំងវត្តខ្លះៗដែលនៅជាមួយប្រាសាទ

វត្តអារាមក្នុងរមណីយដ្ឋានអង្គរ

តាមរយៈការសិក្សាសិលាចារឹក និងសិល្បៈ យើងដឹងថាប្រាសាទបុរាណកសាងឡើងសម្រាប់តម្កល់ប្រតិមាក្នុងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ជាពិសេសព្រះពុទ្ធសាសនាមហាយាន។ ក្រោយមកព្រះពុទ្ធសាសនាថេរវាទ ដែលមានភាសាបាលីជាយានជ្រាបចូលសង្គមខ្មែរនៅចុងស.វ.ទី១៤នៃគ.ស.។ សិលាចារឹកដែលគេប្រទះឃើញនៅគោកស្វាយចេក (K.754) គឺជាសិលាចារឹកភាសាបាលីចាស់ជាងគេនៅស្រុកខ្មែរ ចារនៅគ.ស.១៣០៨និយាយអំពីព្រះរាជាព្រះបាទស្រីន្ទ្រវម៌្មបញ្ជាឱ្យសាងព្រះវិហារនៅស្រុកស្រីស្រីន្ទ្ររតនគ្រាម ហើយជីកស្រះ ត្រពាំងតូចធំ និងស្ថាបនាព្រះពុទ្ធរូបព្រះនាម«ស្រីស្រីន្ទ្រមហាទេវ» (Cœdès 1936)។[៣] មកដល់សព្វថ្ងៃ យើងពុំទាន់ដឹងថាព្រះវិហារដែលនិយាយក្នុងសិលាចារឹកនោះមានរូបរាងដូចម្ដេចទេ តែគេប្រទះឃើញសិលាចារឹកលើស្ទឹកសីមាវត្តព្រះសិរអារ្យ (K.930) និយាយពីប្រតិមា២អង្គព្រះនាម «ស្រីស្រីន្ទ្រសុគត» និង«ស្រីស្រីន្ទ្រត្រៃលោក្យមហានាថ» ដែលទំនងចារនៅពេលស្របាលគ្នានឹងសិលាចារឹកគោកស្វាយចេក (Cœdès 1953: 315)។ រូបរាងរបស់រចនាសសម្ព័ន្ធសំណង់ខឿន នៅវត្តព្រះសិរអារ្យអាចជួយឱ្យយើងពិចារណាទៅដល់រូបរាងព្រះវិហារដែលនិយាយក្នុងសិលាចារឹកគោកស្វាយចេកនោះ។

---

[៣] អត្ថបទនេះបកប្រែពីភាសាបារាំងមកជាភាសាខ្មែរ ដោយលោកគ្រូ អាំង ជូលាន ចុះផ្សាយក្នុងឧទ័យ លេខ៩ នាពេលក្រោយមក (សូមអាន អាំង ជូលាន ២០០៨)។

នៅសម័យកណ្តាល(ពីស.វ.ទី១៥ដល់ស.វ.ទី១៨នៃគ.ស.)មានរបត់មួយធំ ដ្បិតលែងមានការនិយមសង់ប្រាសាទថ្មធំៗតទៅទៀត តែមានការធ្វើសំណង់ដែលមានបាតរាងចតុកោណកែងមានសីមាតាមទិសដែលធ្វើនៅជាប់នឹងប្រាសាទបុរាណ (អាំង ជូលាន et al. ១៩៩៨: ៧៦)។ សំណង់រាងចតុកោណកែងនោះទំនងមានជញ្ជាំងឈើ ឬគ្មាន និងមានដំបូលប្រក់ក្បឿង ឬស្លឹក ដែលមានទីសម្រាប់តម្កល់ព្រះពុទ្ធរូបនៅចុងខាងលិចល្វែងនៃអគារ។ សំណង់ក្នុងទម្រង់នេះឃើញមានជាហូរហែទាំងក្នុង និងក្រៅតំបន់អង្គរ ពិសេសក្នុងក្រុងអង្គរធំដូចជា វត្តកងជុំ វត្តព្រះសិរអារ្យ វត្តតាំងតុ វត្តវិហារប្រាំពីរល្វែង និងវត្តទេពប្រណម្យ។ល។(សូមអាន Marchal 1918, អេង តុលា ២០១៩)។ ករណីខ្លះទៀត ប្រាសាទដែលសង់នៅសម័យបុរាណត្រូវកែប្រែ និងប្រើប្រាស់ជាបូជនីយដ្ឋានពុទ្ធសាសនាថេរវាទ ពោលគឺ គេកែប្រាសាទជាចេតិយ ហើយសង់ព្រះវិហារនៅខាងកើត (ឡុង ជារ៉េត et al. ១៩៩៦: ១៥-១៧)។ ម្យ៉ាងទៀត ព្រះពុទ្ធប្រតិមាសម័យកណ្តាលជាច្រើន ត្រូវគេប្រទះឃើញធ្លាក់ និងតម្កល់នៅតាមប្រាសាទដែលបង្ហាញពីការគោរពបូជាឥតដាច់ពីអតីតកាលមក (ឈាង សេរីវុឌ្ឍី et al. ១៩៩៦: ៥-១៩)។ ម៉្លោះហើយ វត្តអង្គរ វត្តបាគង វត្តអធ្វា វត្តចេតិយ វត្តព្រះឥន្ទកោសីយ៍ និងវត្តលលៃជាដើមទំនងជាវត្តដែលបន្តតាំងពីពេលនោះមក (រូបលេខ២)។[៤] ដូច្នេះការដែលយើងឃើញថាវត្តទាំងនេះតាំងទីជាមួយប្រាសាទបុរាណនោះពុំមានអ្វីចម្លែកឡើយ។

រូបលេខ២. ប្រាសាទព្រះឥន្ទកោសីយ៍ និងព្រះវិហារនៅខាងក្រោយ

[៤] សិលាចារឹកនៅប្រាសាទអង្គរវត្ត IMA27 ចារឹកថា នៅគ.ស. ១៦៧១ អ្នកសម្តេចព្រះមុនីកុសលមកសំពះព្រះនៅ «អង្គរវត្ត» ដែលព្រះឥន្ទ្រឱ្យព្រះពិស្ណុការចុះមកសាងទុក (Lewitz 1973a: 209-210)។ តែមុននោះបន្តិចមានសិលាចារឹកមួយទៀតនៅប្រាសាទអង្គរវត្ត IMA17 ចារឹកអំពីចៅជេត និងនាងសួសមានសទ្ធានាំញាតិការមក«ព្រះនគរវាត»នៅគ.ស.១៦៣២ (Lewitz 1973b: 164)។ សាន្តិ ភក្តី គាំ (២០០៨:១៦១) យល់ថាពាក្យ«ព្រះនគរវត្ត»ខាងលើអាចសំដៅលើស្រុកព្រះនគរទាំងមូល។ ទោះយ៉ាងណាពាក្យ«អង្គរវត្ត» ដែលក្លាយមកពី«នគរវត្ត»គឺមានន័យតែមួយ។ គំនិតយល់ថាប្រាសាទអង្គរវត្ត គឺជាទីស្ថានព្រះពុទ្ធសាសនាមានមុនស.វ.ទី១៧នេះទៀតផង (អាំង ជូលាន et al. ១៩៩៨: ៨៧)។

និយាយទាំងប៉ុន្មានខាងលើគឺមិនក្តោបទាំងអស់ទេ វត្តខ្លះនៅតំបន់អង្គរក៏ទើបមានព្រះសង្ឃមកគង់អាស្រ័យ ហើយយកសំណង់មានបាតរាងចតុកោណកែងនាសម័យកណ្តាលមកប្រើប្រាស់ជា«ឧបោសថាគារ» សម្រាប់វត្តនាប៉ុន្មានឆ្នាំមុនប៉ុណ្ណោះ ពោលគឺរវាងនៅទសវត្សរ៍១៩៩០។ យូរៗទៅក៏មានចលនាកកើតជាវត្តអារាមផុសផុលឡើងមកដល់សព្វថ្ងៃ។ ទន្ទឹមគ្នានេះ វត្តខ្លះទៀតកកើតឡើងនៅជិតប្រាសាទដែរ តែជាវត្តទើបតែកកើតថ្មីសន្ធាង។ ប្រការនេះគួរឱ្យលើកយកមកសិក្សាជាប្រធានបទមួយធំថា ហេតុម្តេចក៏គេនិយមរើសទីតាំងបង្កើតវត្តនៅជិតប្រាសាទ?[៩]

ការគ្រប់គ្រងបេតិកភណ្ឌវត្តអារាមក្នុងខេត្តសៀមរាប

សម្រាប់តំបន់អង្គរ និងខេត្តសៀមរាបទាំងមូល ប្រាសាទ ហេដ្ឋារចនាសម្ព័ន្ធបុរាណ ឬសំណង់នៅតាមវត្តអារាមដែលចាត់ចូលជាបេតិកភណ្ឌជាតិ ឬស្ថិតក្នុងក្របខណ្ឌតំបន់ការពារបេតិកភណ្ឌពិភពលោក ត្រូវឱ្យស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាធរជាតិអប្សរា។ ម្ល៉ោះហើយ ទោះជាវត្តទាំងនោះស្ថិតនៅក្រៅតំបន់ការពារទី១ និងទី២ ហើយក្តីក៏ចៀសមិនផុតពីការពិនិត្យបច្ចេកទេសនៃការសាងសង់ ឬកែប្រែរូបរាងរបស់បុរាណដ្ឋាន។ ករណីដោយឡែកខ្លះ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាបក៏ចូលរួមចំណែកថែរក្សាការពារបេតិកភណ្ឌជាតិក្នុងខេត្តសៀមរាបដែរ។

នៅក្នុងព្រះរាជក្រឹត្យលេខ នស ០០១ ស្តីពីការចាត់ចែង និងគ្រប់គ្រងរមណីយដ្ឋានអង្គរក៏មានចែងមាត្រាអំពីវត្តអារាមថា៖

ក- ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ (តំបន់ ១, ២, ៣, ៤, ៥)

- រក្សាទុកសហគមន៍សាសនាដែលមាន ហើយថែទាំវត្តអារាមចាស់ៗ។
- ហាមឃាត់គ្រប់សកម្មភាពសាងសង់ដែលធ្វើឱ្យខូចខាតផ្ទៃដី។
- ជំរុញលើកទឹកចិត្តគ្រប់សកម្មភាពបណ្តុះបណ្តាលបែបប្រពៃណី។

ខ- ចំពោះតំបន់ ១

- មិនអនុញ្ញាតអោយមានវត្តថ្មី ឬទីតាំងសាសនានៅក្នុងប្រាសាទនានា។
- ហាមការស្នាក់អាស្រ័យពេលយប់ ក្រៅពីបរិវេណវត្តនៅក្នុងអង្គរ វត្តក្នុងប្រាសាទបាគង និងវត្តក្នុងប្រាសាទលលៃ។

គ- ចំពោះតំបន់ ២

- ការបង្កើតវត្តថ្មីនៅតាមភូមិនានាត្រូវគោរពតាមបទបញ្ញត្តិនៃច្បាប់។

សំណង់សំខាន់ៗតាមវត្តមានដូចជា ព្រះវិហារ សាលាឆាន់ ឬសាលាបុណ្យ ធម្មសាលា ហោត្រៃ

[៩] បើតាមការស្រាវជ្រាវរបស់ ភូ សុជា ការរើសទីតាំងបង្កើតវត្តថ្មីគឺរើសយកទីដែលខ្ពស់ផុតពីទឹក ហើយគេចំណាំមើលសណ្ឋានរបស់ដើមឈើនៅពេលយប់ងងឹតស្ងាត់ដោយប្រៀបធៀបនឹងសត្វផ្សេងៗ (២០០១: ១០)។ ជាធម្មតា ប្រាសាទបុរាណតែងសង់លើគោកខ្ពស់ដែលពិតជាអំណោយផលដល់តម្រូវការទីទួលសម្រាប់សាងសង់ ប៉ុន្តែបើគ្រាន់តែខ្ពស់ផុតពីទឹកដូចជាពុំទាន់គ្រប់គ្រាន់។

សាលាបាលី (ពុទ្ធិកបឋមសិក្សា និងពុទ្ធិកវិទ្យាល័យ) កុដិ ទីប៉ាឆា ឬឈាបនដ្ឋាន រោងទូក ដងទង់ និងចេតិយជាដើម (ព្រាប ចាន់ម៉ារ៉ា ២០១៧)។ សំណង់ទាំងនេះសុទ្ធតែអាចចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌ ប្រសិនណាសំណង់នោះមានតម្លៃផ្នែក សិល្បៈ ប្រវត្តិសាស្ត្រ និងស្ថាបត្យកម្ម។ ចំពោះការកំណត់អាយុកាល របស់សំណង់ដែលចាត់ចូលជាសម្បត្តិបេតិកភណ្ឌ ដើមឡើយអាជ្ញាធរជាតិអប្សរាធ្លាប់បង្កើតសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដោយកំណត់រួមគ្នាថា សម្បត្តិ «បេតិកភណ្ឌសាសនា» ត្រូវមានអាយុចាប់ពី៥០ឆ្នាំឡើងគួរតែជួសជុល និងថែរក្សា (Khuon 2008: 134)។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ នាឱកាសប្រគល់សញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សម្តេចនាយករដ្ឋមន្ត្រីបានបញ្ជាក់កាន់តែច្បាស់ថែមទៀតថា «...អ្វីដែលបន្សល់ទុកលើសពី៥០ឆ្នាំទៅ គឺខិតខំរក្សា...»។[៦] ប្រសាសន៍ត្រង់នេះបានក្លាយជាគោលការណ៍សម្រាប់ការអនុវត្តក្នុងកិច្ចការអភិរក្ស។ ការសិក្សាសំណង់វត្តអារាមក្នុងប្រទេសកម្ពុជាផ្សព្វផ្សាយនាពេលថ្មីៗបានបង្ហាញថា ក្នុងខេត្តសៀមរាបមានព្រះវិហារចាស់ច្រើន (Guéret ២០១៧:១៥០-១៥៨)។ ដូច្នេះការចុះបញ្ជី និងសិក្សាលក្ខណៈស្ថាបត្យកម្ម សំណង់តាមវត្តនឹងជួយគាំទ្រដល់ការអភិរក្សបេតិកភណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព។

គិតមកដល់សព្វថ្ងៃ អាជ្ញាធរជាតិអប្សរា និងស្ថាប័នមួយចំនួនទៀតរួមគ្នាសម្រេចលទ្ធផលយ៉ាងសោមនស្ស ចំពោះការផ្តល់ប្រឹក្សាបច្ចេកទេស ឬជួសជុលអភិរក្សព្រះវិហារ និងសំណង់ដទៃទៀតតាមទីអារាមក្នុងឧទ្យានអង្គរ និងតាមដងស្ទឹងសៀមរាបដូចជា វត្តបាគង វត្តរាជបូណ៌ វត្តព្រះឥន្ទកោសីយ៍ វត្តព្រះព្រហ្មរ័ត្នជាដើម(រូបលេខ៣)[៧]។ល។ សូមជម្រាបថាភាគីវិស័យឯកជនក៏ជ្រោមជ្រែងកិច្ចការអភិរក្សនេះមិនតិចដែរ។ ជាក់ស្តែងនោះគឺវត្តរាជបូណ៌ ថវិកាសម្រាប់អនុវត្តគម្រោងជួសជុលព្រះវិហារមានមួយផ្នែកធំបានមកពីពុទ្ធបរិស័ទចំណុះជើងវត្ត។

រូបលេខ៣. កុដិវត្តព្រះព្រហ្មរ័ត្នជួសជុល រូបនៅឆ្នាំ២០២២ (ប្រភពៈក្រុមការងារវត្តអារាមនៃអាជ្ញាធរជាតិអប្សរា)

[៦] ប្រសាសន៍សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៅនាទីទី២៣:៤០៖ https://youtu.be/AbywQpoKoMU?t=1420 (៣១/០១/២០២៣)។

[៧] វត្តបាគង ជាវត្តដំបូងគេដែលបានជួសជុលគំនូរបុរាណ និងរចនាសម្ព័ន្ធសំណង់ព្រះវិហារ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុនស៊ីម៉ងត៍ HOLCIM (Chau 2011)។

ការបង្កើតយន្តការរាំងពុទ្ធចក្រ និងអាណាចក្រ

អាជ្ញាធរជាតិអប្សរាក្នុងនាមជាអ្នកសម្របសម្រួល បានធ្វើការជិតស្និទ្ធជាមួយព្រះសង្ឃ និងមន្ទីរធម្មការ និងសាសនាខេត្តសៀមរាប រហូតបង្កើតបានជា «ក្រុមប្រឹក្សាកិច្ចការវត្តអារាម» នៅឆ្នាំ២០១៣ និងក្រោយមកមានការផ្លាស់ប្តូរសមាជិកខ្លះ។ ក្រុមប្រឹក្សានេះបង្កើតឡើងក្នុងគោលដៅថែរក្សាបេតិកភណ្ឌសាសនាសម្របសម្រួលទំនាក់ទំនងជាមួយវត្តអារាម ទប់ស្កាត់ការសាងសង់ខុសច្បាប់ និងសកម្មភាពប៉ះពាល់ដល់បេតិកភណ្ឌក្នុងវត្តអារាម សម្រួលកិច្ចការដែលស្នើសុំដោយអាជ្ញាធរជាតិអប្សរា និងផ្តល់យោបល់ ឬអនុសាសន៍លើបញ្ហាទាក់ទងនឹងវត្តអារាម។[៨]

ក្រុមប្រឹក្សាកិច្ចការវត្តអារាម មានព្រះមេគណខេត្តសៀមរាប (គណៈមហានិកាយ) ជាព្រះប្រធាន និងព្រះមេគណគណៈធម្មយុត្តិកនិកាយជាព្រះប្រធានកិត្តិយស ហើយមានសមាសភាពដទៃទៀតមកពីអាជ្ញាធរជាតិអប្សរា, មន្ទីរធម្មការ និងសាសនាខេត្តសៀមរាប, អាចារ្យវត្ត និងព្រះសង្ឃតាមវត្តផ្សេងទៀត។ ម្ល៉ោះហើយ រាល់កិច្ចការពាក់ព័ន្ធនឹងវត្តអារាម ពិសេសការបណ្តុះបណ្តាល និងការសាងសង់សំណង់ផ្សេងៗក្នុងរមណីយដ្ឋានសៀមរាបអង្គរ ឬតាមបុរាណដ្ឋាននានាតែងមានកិច្ចសហការពុំលែងឡើយ (រូបលេខ២៤)។

រូបលេខ២៤៖ ការប្រគេនបណ្ណសរសើរចំពោះមន្ត្រីសង្ឃដែលបានជ្រោមជ្រែងការអភិរក្សប្រាសាទលលៃ
(ប្រភព៖ ហ៊ុំ រិទ្ធី)

[៨] សេចក្តីសម្រេចលេខ ១៣៣ សសរ របស់សាលាខេត្តសៀមរាបស្តីពីការបង្កើតក្រុមប្រឹក្សាកិច្ចការវត្តអារាម ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣។

អ្វីដែលគួរកត់សម្គាល់ខ្លាំងគឺនៅឆ្នាំ២០១៩ យន្តការនេះបានជួយសម្របសម្រួលដល់ការងារអភិរក្ស និងលើកតម្លៃប្រាសាទលលៃ តាមរយៈការនិមន្តព្រះសង្ឃមកគង់នៅបរិវេណខាងក្រៅឱ្យផុតពីខឿនប្រាសាទ និងលើកសំណង់នានាមកសាងសង់នៅក្រៅខឿនដែរ លើកលែងតែព្រះវិហារប៉ុណ្ណោះដែលរក្សានៅកន្លែងដើមដដែល។ មិនតែប៉ុណ្ណោះ ការងារនេះបានផ្តល់ឱកាសដល់ក្រុមបុរាណវិទូធ្វើកំណាយស្រាវជ្រាវដើម្បីស្វែងយល់រចនាសម្ព័ន្ធប្រាសាទលលៃ និងសិក្សាបន្ថែមទៀតលើការរកឃើញរបស់សាលាបារាំងចុងបូព៌ាដែលបានស្រាវជ្រាវនាពេលកន្លងមក (ជូ ជុន et al. ២០២១)។

វត្តអារាម៖ ទិសដៅទេសចរណ៍សាសនា និងជំនឿ

ទៅអនាគត វត្តអារាមទាំងនោះនឹងក្លាយជាទិសដៅទេសចរណ៍បន្ទាប់ពីប្រាសាទ។ ជាការកត់សម្គាល់ វត្តមួយចំនួនចាប់ផ្តើមមានទេសចរទស្សនាកម្សាន្ត ដោយមានការរៀបចំសម្របសម្រួលពីក្រុមហ៊ុនទេសចរណ៍ ដូចជាវត្តស្វាយរមៀត (កែវ រចនា ២០២២)។ អាជ្ញាធរជាតិអប្សរាធ្លាប់គិតគូរបំណងនេះជាយូរមកហើយ។ ផែនការនេះទើបតែបានកំណត់ច្បាស់ក្នុងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប២០២១-២០៣៥។[៩]

ក្នុងផែនការគឺបង្កើតឱ្យមានចរន្តទស្សនាតាមវត្តអារាមក្នុងក្រុងសៀមរាប និងសំណង់បេតិកភណ្ឌសម័យអាណានិគមនៅជុំវិញផ្សារចាស់(រូបលេខ៥)។[១០] គឺផែនការនេះទៀតសោតជាការបង្កើតផលិតផលទេសចរណ៍សម្រាប់ទេសចរដើរកម្សាន្តក្រៅពីទស្សនាប្រាសាទ។ យ៉ាងណាមិញ ការសិក្សាវាយតម្លៃផលប៉ះពាល់ពីវិស័យទេសចរណ៍លើវត្តអារាម និងសហគមន៍ជុំវិញ គឺជាកិច្ចការមួយសំខាន់មុននឹងចាប់ផ្តើមអនុវត្ត ដ្បិតវត្តអារាមគឺជាមណ្ឌលសាសនា និងមានព្រះសង្ឃគង់អាស្រ័យរក្សាសង្ឃវិន័យបានផ្ទាល់មុខមាត់ ទៅជាផលិតផលទេសចរណ៍។ ត្រង់ចំណុចនេះ ការសិក្សាស្ទាបស្ទង់មតិពីព្រះសង្ឃ និងសហគមន៍ចំណុះជើងវត្ត គឺជាប្រការដ៏ចាំបាច់ (APSARA 2013: 93)។ ក្នុងន័យនេះ ក្រមប្រតិបត្តិទេសចរណ៍តំបន់អង្គរគួរតែអភិវឌ្ឍបន្ថែម សម្រាប់អនុវត្តជាពិសេសចំពោះទេសចរណ៍តាមវត្តអារាម ក្នុងគោលបំណងបញ្ចៀសផលអវិជ្ជមានលើវប្បធម៌សង្គម និងសាសនា។[១១] វត្តព្រះព្រហ្មរ័ត្នគួរតែជាគោលដៅទី១សម្រាប់ដកបទពិសោធន៍ ដ្បិតទីតាំងនេះនៅជិតតំបន់ផ្សារចាស់ជាងគេ ហើយដែលមានទេសចរចេញចូលជាប្រចាំ។

---

[៩] រាជរដ្ឋាភិបាលកម្ពុជា ២០២១: ៣៣។

[១០] អាជ្ញាធរជាតិអប្សរា និងដៃគូផ្នែកស្រាវជ្រាវធ្លាប់ធ្វើក្រដាសផ្ទត់អំពីវត្តអារាមតាមដងស្ទឹងសៀមរាបដែលបង្ហាញពីប្រវត្តិខ្លីៗ និងទីតាំងរបស់វត្តចំនួន១២ (Roveda, Yem & Khieu 2007-2010)។

[១១] ក្រមប្រតិបត្តិអង្គរផ្សព្វផ្សាយឱ្យប្រើនៅឆ្នាំ២០១៥ ដើម្បីបញ្ចៀសផលអវិជ្ជមាន និងផលប៉ះពាល់តម្លៃលើបេតិកភណ្ឌអង្គរដែលកើតចេញពីផែនការគ្រប់គ្រងទេសចរណ៍អង្គរ (APSARA 2012)។



រូបលេខ២៩. ផែនទីបង្ហាញទីតាំងវត្តតាមដងស្ទឹងសៀមរាប

បន្ថែមលើនេះ ការបង្កើតឯកសារ ពន្យល់បកស្រាយ និងផ្សព្វផ្សាយពីតម្លៃបេតិកភណ្ឌសាសនា ដល់មគ្គុទ្ទេសក៍ និងភាគីពាក់ព័ន្ធជាពិសេសទេសចរដែលពុំទាន់ស្គាល់ពីវត្តអារាមគួរបញ្ជ្រាបជាបណ្តើរៗ។ ឧទាហរណ៍ដូចជា នៅរមណីយដ្ឋានហ្លួងព្រះបាង នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បាន អនុវត្តកម្មវិធីនេះរួចមកហើយ។ តាមការសិក្សាទេសចរទេស្សនានៅហ្លួងព្រះបាងមានហេតុផលសំខាន់៣គឺ វប្បធម៌ របៀបរស់នៅ និងវត្តអារាម (UNESCO 2004: 54)។[១២] សំណង់ស្ថាបត្យកម្ម និងវត្តបុរាណក្លាយជា គោលដៅទេសចរណ៍ និងជាប្រភពចំណូលយ៉ាងសំខាន់របស់ប្រទេសឡាវ។ ទន្ទឹមគ្នានេះ ទេសចរណ៍ក៏បង្ក ផលប៉ះពាល់ដល់សង្គមដែលទាមទារឱ្យមានការគ្រប់គ្រង និងវាយតម្លៃ។ ម្ល៉ោះហើយការរកឃើញផលអវិជ្ជ មាននឹងជួយឱ្យការគ្រប់គ្រងមានប្រសិទ្ធភាព។

ម្យ៉ាងទៀត ផលប្រយោជន៍ពីវិស័យទេសចរណ៍គួរត្រូវពន្យល់បន្ថែមសម្រាប់វត្តអារាម ហើយផល ប្រយោជន៍ទាំងនោះគួរគិតគូរដល់ការបង្កើតកម្មវិធីបណ្តុះបណ្តាលចំណេះដឹងព្រះពុទ្ធសាសនា និងសកម្មភាព សិល្បៈ ប្រពៃណី សាសនា ដែលស្របទៅនឹងព្រះរាជក្រឹត្យអំពីការចាត់ចែងគ្រប់គ្រងរមណីយដ្ឋានអង្គរ និង ជាការចូលរួមថែរក្សាមត៌កវប្បធម៌អរូបីនៅអង្គរ។ សំខាន់ជាងនេះទៅទៀតនោះគឺ ការបណ្តុះបណ្តាលជំនាញ ដល់ព្រះសង្ឃក៏នឹងជួយដល់ការអភិរក្សសំណង់បុរាណតាមរយៈការចូលរួម និងផ្តល់យោបល់នាពេលអនាគត់ ផងដែរ ហើយការចូលរួមពីពុទ្ធបរិស័ទចំណុះជើងវត្តផ្ទាល់ក្នុងការប្រឹក្សាយោបល់ចំពោះការអភិរក្ស គឺជា ការចាំបាច់បំផុត (រូបលេខ២៦)។

រូបលេខ២៦. ព្រះវិហារវត្តល្អក់ពេលកំពុងជួសជុលដោយពុទ្ធបរិស័ទចំណុះជើងវត្តក្នុងឆ្នាំ២០១៦

[១២] ចំពោះការយល់ឃើញរបស់ព្រះសង្ឃនៅហ្លួងព្រះបាងអំពីផលប៉ះពាល់នៃទេសចរណ៍ សូមអាន Suntikul 2008។

វិវឌ្ឍន៍ថ្មីៗនៃកិច្ចការពាក់ព័ន្ធវត្តអារាម

កន្លងមក ដោយសារមានការវាយសំណង់បេតិកភណ្ឌតាមវត្តក្នុងរាជធានី និងតាមបណ្តាខេត្តនានា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរួមគ្នានឹងក្រសួងធម្មការ និងសាសនាបានបង្កើតសារាចរអន្តរក្រសួងលេខ ០១ ស.រ.ច. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីទប់ស្កាត់ការបំផ្លាញសំណង់បុរាណ គំនូរបុរាណ និងវត្ថុបុរាណតាមវត្តនានា។ ក្រោយបន្តិចមកពុទ្ធចក្រ និងអាណាចក្របានចេញលិខិតដោយឡែកពីគ្នាពាក់ព័ន្ធនឹងបេតិកភណ្ឌតាមវត្តអារាម ពោលគឺរាល់សំណង់នៅតាមវត្ត។ គណៈសង្ឃនាយកបានចេញលិខិតលេខ ០៣២/២០ ស.ន.ក.ជ. ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ផ្សព្វផ្សាយទៅគ្រប់វត្តថា បើមានបំណងជួសជុលសំណង់បេតិកភណ្ឌពុទ្ធសាសនាត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុន។ បន្ទាប់មករាជរដ្ឋាភិបាលបានប្រកាសសារាចរលេខ០៨ ស.រ. ស្តីពីការទប់ស្កាត់ការរំលាយកម្ទេច និងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ (ជាតិ) នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ដោយបញ្ជាក់ច្បាស់ថា ចំពោះការជួសជុល កែប្រែ ឬវាយកម្ទេចចោលត្រូវសុំការពិនិត្យសម្រេចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរពាក់ព័ន្ធជាមុនសិន។ បច្ចុប្បន្ននីតិវិធីនេះកំពុងហុចផ្លែផ្កាជាបណ្តើរៗ។

ក្នុងពេលថ្មីនេះ ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណង់ និងចំនួនវត្តក្នុងឧទ្យានអង្គរ សេចក្តីជូនដំណឹងលេខ ៨៣៥ ស.ជ.ណ. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រង់ចំណុចលេខ៨ ដោយស្រង់ប្រសាសន៍សម្តេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា៖

> *«វត្តអារាមនៅតំបន់រមណីយដ្ឋានអង្គរចំនួន៣៥ (វត្តបុរាណ១៤ និងវត្តសាងសង់ក្រោយឆ្នាំ១៩៧៩ ចំនួន២១វត្ត គឺរក្សានៅដដែល និងមិនអនុញ្ញាតឱ្យសាងសង់វត្តអារាមព្រះពុទ្ធសាសនា ឬវិហារឥស្លាម វិហារគ្រិស្តសាសនា និងជំនឿសាសនា ផ្សេងៗនៅក្នុងតំបន់រមណីយដ្ឋានអង្គរបន្ថែមទៀត, ហាមមិនឱ្យសាងសង់ចេតិយ អាស្រម រូបសំណាក ឬបដិមាគោរពបូជាបន្ថែមទៀតឡើយ ព្រមទាំងមិនអនុញ្ញាតឱ្យយកសាកសពទៅបញ្ចុះ ឬបូជានៅក្នុងវត្តអារាមនៅក្នុងតំបន់រមណីយដ្ឋានអង្គរ លើកលែងតែចៅអធិការវត្ត គ្រូសូត្រស្តាំ គ្រូសូត្រឆ្វេង ដែលបានគង់នៅវត្តយូរណាស់មកហើយ។»*

មានន័យថា ចាប់ពីពេលនេះពុំអនុញ្ញាតឱ្យមានការបង្កើតវត្តបន្ថែមនៅក្នុងតំបន់ការពារឧទ្យានអង្គរទេ។ ប្រការខាងលើនេះផ្តោតសំខាន់តែវត្តអារាមក្នុងតំបន់ការពារទី១ និងទី២ ប៉ុន្តែដូចខ្ញុំបានជម្រាបពីខាងដើមថាវត្តដែលពុំស្ថិតក្នុងតំបន់ការពារទី១ និងទី២ក៏ចាំបាច់ត្រូវការគ្រប់គ្រង និងអភិរក្សដូចគ្នាគ្រាន់តែក្នុងកម្រិតផ្សេងគ្នាទៅតាមទីតាំងជាក់ស្តែងរបស់វត្ត ឬសំណង់បេតិកភណ្ឌទាំងនោះ។ ឧទាហរណ៍ វត្តចេតិយស្ថិតនៅក្រៅតំបន់ការពារឧទ្យានអង្គរ ប៉ុន្តែវត្តនេះស្ថិតនៅលើគោកប្រាសាទវត្តចេតិយទាំងមូល ព្រមទាំងមានព្រះវិហារចាស់ទៀតផង។ ហេតុនេះការពិនិត្យស្ថានភាពជាក់ស្តែង និងផលប៉ះពាល់គឺជាករណីចាំបាច់ខ្លាំងណាស់មុននឹងមានការសាងសង់ ជួសជុលអគារ ឬកែប្រែរូបរាងរបស់បុរាណដ្ឋាន។

ទោះជាយ៉ាងណាក្តី បញ្ហាខាងលើនេះ គួរពិភាក្សាពីថ្នាក់ជាតិដល់មូលដ្ឋានក៏ដូចជាបណ្តាចំណោមអ្នកស្រាវជ្រាវវិស័យបេតិកភណ្ឌ។ ដ្បិតនៅទីអារាមខ្លះចាប់ផ្តើមមានព្រះវិហារដល់ទៅ២ ដោយវត្តរក្សាទុកសំណង់វិហារចាស់ទុកជាបេតិកភណ្ឌ ព្រមទាំងបានជួសជុលផង។ ប៉ុន្តែពុំបានប្រើប្រាស់សំណង់ចាស់ទាំងនោះសម្រាប់សង្ឃកិច្ចទៀតនោះឡើយ។ ផ្ទុយទៅវិញ ព្រះសង្ឃ និងពុទ្ធបរិស័ទប្រើប្រាស់ព្រះវិហារដែលទើបសង់ថ្មីនោះទៅវិញ ដោយលើកឡើងពីគុណភាពសំណង់បេតិកភណ្ឌ។ ការអភិរក្សរូបរាង និងតម្លៃដើមរបស់សំណង់គួរតែដើរទន្ទឹមគ្នា (រូបលេខ៧)។

រូបលេខ៧. ព្រះសង្ឃធ្វើកិច្ចទាក់កក្នុងពិធីបំបួសនាគក្នុងព្រះវិហារវត្តពោធិ៍បន្ទាយជ័យ

សេចក្តីបញ្ចប់

សំណង់បេតិកភណ្ឌតាមវត្តអារាមនៅក្នុងខេត្តសៀមរាបមួយចំនួនទៀតនៅពុំទាន់ចុះបញ្ជី ឬសិក្សាសំណង់អគារបេតិកភណ្ឌនៅឡើយទេ គួបផ្សំនឹងវត្តមួយចំនួនតែងចង់បានសំណង់ថ្មីសម្រាប់ប្រើប្រាស់ក្នុងទីអារាម សំណង់បេតិកភណ្ឌទាំងនោះកំពុងតែស្ថិតនៅលើចន្លោះរវាងការអភិរក្ស និងការអភិវឌ្ឍន៍។ ម៉្យាងទៀត ការបន្តប្រើប្រាស់សំណង់សាសនាក្នុងន័យប្រពៃណី សាសនា គឺដូចយើងបានអភិរក្សលើកតម្លៃសំណង់បេតិកភណ្ឌទាំងនោះឱ្យនៅមានជីវិត។ ត្រង់នេះគឺថា ការអភិរក្សរូបរាង និងតម្លៃរបស់បេតិកភណ្ឌពុំអាចផ្តាច់ចេញពីគ្នាបានឡើយ។ នៅក្នុងខេត្តសៀមរាប ការគិតគូរយកចិត្តទុកដាក់លើកិច្ចការអភិរក្សសំណង់បុរាណនៅក្នុងបរិវេណវត្តអារាមកំពុងតែដំណើរការយ៉ាងរលូន ដោយមានអាជ្ញាធរជាតិអប្សរាជាអ្នកសម្របសម្រួល។

ការសំខាន់មួយទៀតគឺ ការកែប្រែបូជនីយដ្ឋានទៅជាទិសដៅទេសចរណ៍ គួរតែមានការពិភាក្សា និងវាយតម្លៃបន្ថែម ហើយត្រូវមានការចូលរួមពីព្រះសង្ឃ និងសហគមន៍ចំណុះជើងវត្ត ដើម្បីទទួលបាននូវយោបល់ និងកម្រិតផលប៉ះពាល់ឱ្យនៅតិច។

សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមអរគុណ លោក ស៊ឹម ប៊ុនធឿន បានជួយពិនិត្យ និងផ្តល់យោបល់លើសេចក្តីរបស់អត្ថបទ ហើយសូមអរគុណដល់ អ្នកនាង ម៉ៅ សេងយាន និងអ្នកនាង ហ៊ារ រិទ្ធាវ័ត្ន ដែលជួយពិនិត្យពាក្យពេចន៍។

ឯកសារពិគ្រោះ

កែវ រចនា (២០២២) «ទេសចរវត្តអារាមជាផលិតផលទេសចរណ៍មួយ ដែលភ្ញៀវទេសចរបរទេសមានការចាប់អារម្មណ៍ក្រៅពីប្រាសាទ», *Khmertimes* (https://www.khmertimeskh.com ១៨/ធ្នូ/២០២២)

ឈាង សេរីវុឌ្ឍី, ង៉ួន សុគន្ធា, អ៊ុក តុបតុស្សិដា, ជីង សៅគន្ធវារី, ខាន់ សំបូរ (១៩៩៦) សិល្បៈខ្មែរសម័យកណ្ដាល, និក្ខេបបទបរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ

ប៉ូ ប៉ុន, សៀង សុផានី, កែវ ចាន់សុផានី, និង អាន សីម៉ា (២០២១) «កំណាយស្រាវជ្រាវរចនាសម្ព័ន្ធសំណង់ក្រោមកុដិវត្តលលៃ «ប្រាសាទលលៃ», ព្រះនគរ, លេខ២៣, ទំ. ៧៥-១០៣

ព្រាប ចាន់ម៉ារ៉ា (២០១៧) ឧទ្រង្គសំណង់ប្រពៃណីខ្មែរភាគ១៖ សំណង់នៅតាមវត្ត, ភ្នំពេញ

ភូ សុជា (២០០១) ក្បួនខ្នាតខ្លះនៃសំណង់ក្នុងបរិវេណវត្តអារាម, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

មិន ឃិន (២០១៣) កម្រងឯកសារប្រវត្តិវត្តក្នុងខេត្តសៀមរាប, ក្រសួងធម្មការ និងសាសនា, ភ្នំពេញ

រាជរដ្ឋាភិបាលកម្ពុជា (២០២១) ផែនការមេសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥

សាន្តិ ភក្តីគាំ (២០០៨). «នគរវត្ត សៀមរាប ជាឈ្មោះមកពីណា? អ្នកណាដាក់?» សិក្សាចក្រ, លេខ១០, ទំ. ១៥៧-១៧១

ឡុង ឋារ៉េត, ជា ខេង, ឈុន ណាក់ (១៩៩៦) ពុទ្ធសាសនាថេរវាទសម័យកណ្ដាលនៅតំបន់អង្គរ, និក្ខេបបទបរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ

អេង តុលា (២០១៩) ពិចារណាអំពីរចនាសម្ព័ន្ធនៃឧបោសថាគារសម័យកណ្ដាល, និក្ខេបបទបរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ

អាំង ជូលាន, អេរិក ប្រូណូវិត្ស និង អាស៊ី ថមសុន (១៩៩៨) អង្គរ៖ អតីត បច្ចុប្បន្ន អនាគត, អាជ្ញាធរអប្សរា, ភ្នំពេញ

អាំង ជូលាន (២០០៨). «សិលាចារឹកភាសាបាលីចាស់ជាងគេនៅកម្ពុជា» ឧត្តម, លេខ៩, ទំ. ១១៥-១២៧

Guéret, Danielle & Guéret, Dominique-Pierre (២០១៧) វត្តអារាមនៅប្រទេសកម្ពុជា, Kam éditions

APSARA (2012) Angkor World Heritage Area: Tourism Management Plan

APSARA (2013) Angkor Heritage Management Framework

Chau, Sun Kerya (2011) "The Origin of the Restoration of the Vihara of Wat Bakong" *The Restoration of Wat Bakong Murals in Cambodia*, Vittorio Roveda (ed.), Holcim, Bangkok, p.13-14

Cœdès, Goerge (1953) *Inscription du Cambodge*, tome 5, Paris

Cœdès, Goerge (1936) "Etudes Cambodgiennes: XXXII. La Plus Ancienne Inscription en Pali du Cambodge" *BEFEO*, 36, p.14-21

Khuon, Khun-Neay (2008). "Annexure A - Site Management and Local Communities" Angkor: Heritage Values and Issue, p.131-138

Lewitz, Saveros (1973b). "VIII. Inscriptions Modernes d'Angkor 17, 18, 19, 20, 21, 22, 23, 24 et 25" *BEFEO*, 60, 1, pp.163-203

Lewitz, Saveros (1973a). "IX. Inscriptions Modernes d'Angkor 26, 27, 28, 29, 30, 31, 32, 33" *BEFEO,* 60.1, pp. 205-242

Marchal, Henri (1918) "Monuments Secondaires et Terrasses Bouddhiques d'Ańkor Thom", *BEFEO*.18, pp.1-40

Roveda, Vittorio, Sothon Yem, Chan Khieu (2007-2010) The Pagodas along the Siem Reap River: Tour of the Historical Pagodas of the Town of Siem Reap, APSARA (Leaflet)

Suntikul, Wantanee (2008). "The Impact of Tourism on the Monks of Luang Prabang", *16th ICOMOS General Assembly and International Symposium: 'Finding the spirit of place – between the tangible and the intangible' (29 sept - 4 oct 2008). Quebec, Canada.*

UNESCO (2004). IMPACT: The Effects of Tourism on Culture and the Environment in Asia and the Pacific: *Tourism and Heritage Site Management in Luang Prabang, Lao PDR*, Bangkok.